

ក្រាស្ជង់រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

Ministry of Land Management, Urban Planning, and Construction

កម្រង់

លិខិតបទដ្ឋានកតិយុត្តពាក់ព័ន្ធនឹង

កណៈកម្មការសុរិយោដី

ចង់ក្រាង់ដោយ: នាយកដ្ឋានកិច្ចការរិរាជដីធ្វី

២០២៣

មាតិកាឯកសារពាក់ព័ន្ធនឹងគណៈកម្មការសុរិយោដី

០១-អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី 1

០២-អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី 13

០៣-អនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ 15

០៤-អនុក្រឹត្យលេខ ១០០ អនក្រ.តត ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ 19

០៥-ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី 21

០៦-ប្រកាសលេខ ០៣២ ប្រក.ដនស/គសជ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ ស្តីពីការធ្វើប្រតិភូកម្មមុខងារជូនអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី 45

០៧-ប្រកាសអន្តរក្រសួងលេខ ០២ ប្រករ.០៣ ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី 47

០៨-ប្រកាសលេខ ២៥០ ដនស.ប្រក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ 49

០៩-សេចក្តីសម្រេចលេខ ៣៦ សសរ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការតែងតាំង សមាសភាពលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ 55

១០-សេចក្តីណែនាំលេខ ១៤៥៥ ដនស/គសជ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ 57

១១-សេចក្តីណែនាំរួមលេខ ០៥ សណន ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០៦ 71

១២-សេចក្តីកំណត់លេខ ១៧ ដនស/គសជ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៩ ស្តីពីរបៀបរបបកិច្ចប្រជុំ និងការពិនិត្យសម្រេចលើសំណុំរឿងវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ 73

១៣-សារាចរណែនាំលេខ ០១ ដនស/សរណន ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ ស្តីពី ការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងយន្តការគណៈកម្មការសុរិយោដី 77

១៤-សេចក្តីណែនាំបន្ថែមលេខ ១៧ ដនស/គសជ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការអនុវត្តប្រកាសលេខ ១១២ ដនស/ប្រក ស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី 81

១៥-សេចក្តីណែនាំ ០២៩ ដនស/គសជ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាល និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ..... 83

១៦-លិខិតលេខ ៦៣៥ ដនស/គសជ ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៧ អំពីការប្រគល់សិទ្ធិជូនឯកឧត្តមប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង ក្នុងការស៊ើបអង្កេត និងសម្រុះសម្រួលករណីវិវាទ ដែលគណៈកម្មការរដ្ឋបាលធ្វើការសម្រុះសម្រួលពុំបានជោគជ័យ..... 87

១៧-លិខិតលេខ ១០០៦ ដនស/គសជ ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យអនុវត្តសេចក្តីណែនាំ ០២៩ ដនស/គសជ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាល និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ..... 89

១៨-ទម្រង់បែបបទរបស់គណៈកម្មការសុរិយោដី 91

១៩-ទម្រង់បែបបទរបស់គណៈកម្មការរដ្ឋបាល..... 161

២០-កម្រងសំណួរ-ចម្លើយ ពាក់ព័ន្ធនឹងការងាររបស់គណៈកម្មការសុរិយោដី ឆ្នាំ២០០៣..... 177

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៤៧...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិះយោបល់

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០២

សំ រ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ ..

អនុក្រឹត្យនេះ មានគោលដៅកំណត់រចនាសម្ព័ន្ធ បេសកកម្ម និង មុខងារ របស់គណៈកម្មការសុរិយោដី ។

មាត្រា ២ ..

អនុក្រឹត្យនេះអនុវត្តចំពោះវិវាទ ដែលទាក់ទងនឹងអចលនវត្ថុដែលមិនទាន់បានចុះបញ្ជីសុរិយោដី ។ ក្នុងករណីនេះ គណៈកម្មការសុរិយោដីមានសិទ្ធិសំរេចមុនគេក្នុងការទទួលស្គាល់ភោគីស្របច្បាប់ ។

ជំពូកទី ២

រចនាសម្ព័ន្ធ និង បេសកកម្ម

មាត្រា ៣ ..

គណៈកម្មការសុរិយោដី ត្រូវមានបេសកកម្មដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី ដូចតទៅ :

១.-វិវាទដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ

២.-វិវាទ ដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យ និងដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល ។

មាត្រា ៤ ..

គណៈកម្មការសុរិយោដី មានរចនាសម្ព័ន្ធដូចតទៅ :

១.-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានអក្សរកាត់ថា គ.ស.ស.ខ មានទីតាំងនៅក្នុងការិ-យាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

២.-គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានអក្សរកាត់ថា គ.ស.ខ.ក មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

៣.-គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានអក្សរកាត់ថា គ.ស.ជ មានទីតាំងនៅក្នុងទីស្ថីការក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋាន ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។.

ជំពូកទី ៣

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ

មាត្រា ៥ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូបដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ហើយត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិក ។

ប្រធានគណៈកម្មការនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និង ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាដហុក ។

មាត្រា ៦ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅតំបន់វិនិច្ឆ័យ ។ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី ។

ជំពូកទី ៤

ការសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ

មាត្រា ៧ ..

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទំរង់បែបបទនៃពាក្យបណ្តឹង ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចុះបញ្ជី និងបើកសំណុំរឿងនៃរាល់វិវាទដែលបានទទួល ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ និងសាកសួរថ្នាតើគ្នវិវាទយល់ព្រមធ្វើការដោះស្រាយសម្រុះសម្រួលតាមនីតិវិធីនេះឬទេ ។

មាត្រា ៨ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវស៊ើបអង្កេតលើវិវាទ ។ ការស៊ើបអង្កេតរួមមាន ការបញ្ជាក់អំពីទីតាំងនៃក្បាលដី ដែលមានវិវាទ និងភាគីពាក់ព័ន្ធ និងអំពីកម្មវត្ថុនៃវិវាទ និងការប្រមូលឯកសារ ដែលមានចម្លើយរបស់សាក្សី និងពតិមានទាក់ទងនឹងក្បាលដីមានវិវាទ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវថតចម្លង និងបញ្ជាក់លើឯកសារចម្លងនោះ សំរាប់ទុកជាសំណុំរឿង និងប្រគល់ច្បាប់ដើមឱ្យភាគីវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកសាង និង បញ្ជូលឯកសារស៊ើបអង្កេតទៅក្នុងសំណុំរឿងវិវាទ ។

មាត្រា ៩ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវសម្រុះសម្រួលវិវាទក្រៅពីករណី ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

ការសម្រុះសម្រួលត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ១០ ..

បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើឃើញថា វិវាទមិនអាចត្រូវបានដោះស្រាយដោយសមធមិនៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញជ្នាល់របស់ប្រធាន ឬតាមសំណើរបស់ភាគីវិវាទទាំងសងខាង ចំពោះករណីដូចតទៅ :

(១) ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ ។

(២) ភាគីម្ខាងនៃវិវាទ គឺជាអាជ្ញាធរមានឋានៈខ្ពស់ ។

(៣) ករណីមានវិវាទពាក់ព័ន្ធនឹងជលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

(៤) វិវាទដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

មាត្រា ១១ ..

ប្រសិនបើការដោះស្រាយអាចសំរេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង បើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌមួយច្បាប់ ដើមច្រាប់ជើមដំណើរការ

អនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ជំពូកទី ៥

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

មាត្រា ១២ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចខាងក្រោម :

-អភិបាល ឬ អភិបាលរងខេត្ត ក្រុង ជាប្រធាន

-ប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ក្រុង ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងវៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង អាចអញ្ជើញតំណាងស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្ត ក្រុង ដែលពាក់ព័ន្ធឱ្យចូលរួមជាសមាជិកអាដហុក ។

មាត្រា ១៣ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានការកិច្ចសម្រុះសម្រួលវិវាទដូចមានចែងក្នុងមាត្រា ១០ និង មាត្រា ១១ វាក្យខ័ណ្ឌទី ២ នៃអនុក្រឹត្យនេះ ។

សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

មាត្រា ១៤ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពស៊ើបអង្កេត ។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលត្រូវតាំងដោយរដ្ឋមន្ត្រីក្រសួងវៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានមុខងារ ភារកិច្ចដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង រាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

-ធ្វើរបាយការណ៍ អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ,

-ធ្វើកំណត់ហេតុ អំពីដំណើរការសម្រុះសម្រួល និងធ្វើរបាយការណ៍អំពីលទ្ធផល នៃការសម្រុះសម្រួល

-បញ្ជូនកំណត់ហេតុ និងរបាយការណ៍ទាំងនេះ ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ក្នុងករណីការសម្រុះសម្រួលបានសំរេច ត្រូវផ្ញើលទ្ធផលនៃការសម្រុះសម្រួលទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ

-រៀបចំ និងតំកល់ទុកឯកសារ ។

ជំពូកទី ៦

ការសម្រុះសម្រួលនៅថ្នាក់ខេត្ត ក្រុង

មាត្រា ១៥ ..

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ពុំមានសិទ្ធិសំរេចលើករណីវិវាទណាមួយទេ ប៉ុន្តែអាចបញ្ចប់វិវាទបាន ក្នុងករណីភាគីវិវាទទាំងអស់ព្រមព្រៀងគ្នាជាឯកច្ឆន្ទ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងជលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង សំណុំរឿងវិវាទនេះ ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

មាត្រា ១៦ ..

ប្រសិនបើការសម្រុះសម្រួលអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវផ្ញើលទ្ធផលជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដី ដែលបានដោះស្រាយរួច ។

ប្រសិនបើការដោះស្រាយមិនអាចសំរេចបាន គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទ រួមជាមួយនឹងរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្រុះសម្រួល ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ជំពូកទី ៧
គណៈកម្មការសុរិយោដីថ្នាក់ជាតិ

មាត្រា ១៧ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមាសភាពដូចខាងក្រោម :

-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ជាប្រធាន
-រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ	ជាសមាជិក
-រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក

ឈ្មោះប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវតែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ឱ្យមកចូលរួមជាសមាជិកអាដហុក ។

មាត្រា ១៨ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសមត្ថកិច្ចចេញសេចក្តីសំរេចលើវិវាទដីភោគៈ ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម ឬគណៈកម្មការរដ្ឋបាលពុំអាចសម្រុះសម្រួលបានដូចមានចែងក្នុងមាត្រា ១៦ និងវិវាទដែលមានចែងក្នុងចំណុចទី ២ នៃមាត្រា ៣ នៃអនុក្រឹត្យនេះ ។

សមាំជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

មាត្រា ១៩ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានលេខាធិការដ្ឋានមួយ ជាសេនាធិការ និងជាអង្គភាពសើបអង្កេត ។

លេខាធិការដ្ឋាននេះ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលត្រូវ

តែងតាំងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មន្ត្រីបំរើការងារនៅលេខាធិការដ្ឋាន ជាមន្ត្រីមុខងារសាធារណៈ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមសំណើរបស់គណៈកម្មការសុរិយោដី ។

លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានតួនាទីដូចតទៅ :

-ទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់ពាក្យបណ្តឹងទាក់ទងនឹងវិវាទដីធ្លី

-ស៊ើបអង្កេតតាមការណែនាំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-រៀបចំការប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

-ធ្វើកំណត់ហេតុអំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការដោះស្រាយ

-បញ្ជូនកំណត់ហេតុ និងភស្តុតាងទាំងអស់ទៅតុលាការ នៅពេលមានការប្តឹងតវ៉ាលើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ

-រៀបចំ និងតំកល់ទុកឯកសារ ។

ជំពូកទី ៨

ការដោះស្រាយនៅថ្នាក់ជាតិ

មាត្រា ២០ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសំរេចទទួលស្គាល់ភោគីឬកម្មសិទ្ធិករស្របច្បាប់ ។

ប្រសិនបើភាគីវិវាទ មិនយល់ព្រមតាមសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទមានសិទ្ធិប្តឹងទៅតុលាការ ដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

មាត្រា ២១ ..

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ដែលស្ថិតក្នុងទម្លាប់វិវាទ ហើយប្រសិនបើយល់ឃើញថាចាំបាច់ អាចបញ្ជាឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ពីគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងរៀបចំបើកសវនាការមុនពេលធ្វើសេចក្តីសំរេចលើវិវាទ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវពិនិត្យដើម្បីបើកសវនាការអំពីវិវាទ តាមការស្នើសុំរបស់ភាគីណាមួយ ។

ក្នុងករណីដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើការពិគ្រោះយោបល់ជាមួយភាគីណាមួយ នោះភាគីផ្សេងៗទៀត មានសិទ្ធិទទួលបានការជូនដំណឹងជាមុន អំពីការពិគ្រោះយោបល់នេះ ដើម្បីមានវត្តមាននៅក្នុងការពិគ្រោះយោបល់ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិយល់ឃើញថាចាំបាច់ ។

មាត្រា ២២ ..

សេចក្តីសំរេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសំរេច ។

មាត្រា ២៣ ..

ភាគីវិវាទ មានសិទ្ធិស្នើឱ្យមានការពិនិត្យឡើងវិញផ្តែកច្បាប់ លើការសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដោយប្តឹងទៅតុលាការក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ចាប់ពីថ្ងៃទទួលបានសេចក្តីសំរេច ។

ប្រសិនបើតុលាការបញ្ជូនរឿងក្តីទៅគណៈកម្មការសុរិយោដីវិញ ដោយហេតុថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដី ត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

ភាគីដែលស្នើសុំការពិនិត្យឡើងវិញផ្តែកច្បាប់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្តឹង ទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ លេខាធិការដ្ឋាន ត្រូវធានាការពារសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីចំពោះតុលាការ ។

តុលាការ ត្រូវផ្តើច្បាប់ចម្លងនៃសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ មកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីចាត់ចែងដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីដី ។

ប្រសិនបើគ្មានបណ្តឹងក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ដូចបានកំណត់នៅក្នុងមាត្រានេះ នោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចាត់ទុកជាស្ថាពរ ។

ជំពូកទី ៩
ការចុះបញ្ជី

មាត្រា ២៤ ..

បន្ទាប់ពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសុពលភាពអាចអនុវត្តបាន គណៈកម្ម-ការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្តីសំរេចនោះ ទៅមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដើម្បីចាត់ចែងធ្វើការចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់ ។

ជំពូកទី ១០
បទប្បញ្ញត្តិវិធាល

មាត្រា ២៥ ..

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានជលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះ ត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ ។

ប្រសិនបើសមាជិករបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ថ្នាក់ជាតិ មានជលប្រយោជន៍នៅក្នុង វិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនេះ ។ ប្រសិនបើចាំបាច់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ក្នុងករណីដែលវិវាទពាក់ព័ន្ធនឹងជលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យធ្វើជាប្រធានអាដហុក ដើម្បីដោះស្រាយករណីវិវាទនេះ ។

មាត្រា ២៦ ..

ជនដែលត្រូវបានបញ្ជាក់ថាជាកម្មសិទ្ធិករ ឬភោគីស្របច្បាប់ នៃក្បាលដី ដែលមានវិវាទក្រោមនីតិវិធី ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវបង់ថ្លៃសេវានៃការចុះបញ្ជីក្បាលដី អនុលោមតាមមាត្រា ២៣០ នៃច្បាប់ភូមិបាល។

មាត្រា ២៧ ..

ភាគីវិវាទ ត្រូវបានជូនដំណឹងជាមុនក្នុងរយៈពេលមួយសមហេតុផល អំពីការប្រជុំដើម្បីសម្រុះសម្រួល ឬសំរេចលើវិវាទក្រោមអនុក្រឹត្យនេះ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីជួយខ្លួន ក្នុងពេលសម្រុះសម្រួលវិវាទនៅគ្រប់ថ្នាក់ ។

ភាគីវិវាទ មានសិទ្ធិចូលខ្លួនដោយខ្លួនឯង និងអាចរកជំនួយមនុស្ស ឬអង្គការណាមួយ ដើម្បីធ្វើជាតំណាងរបស់ខ្លួន ក្នុងពេលប្រជុំធ្វើសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដី ។

ភាគីវិវាទ មានសិទ្ធិបង្ហាញភស្តុតាងថ្មាល់មាត់ ឬឯកសារជាក់ស្តែងដែលទាក់ទងនឹងវិវាទ ដែលត្រូវចាត់ទុកជាចំណែកមួយនៃឯកសារផ្លូវការនៃវិវាទ ។

ការប្រជុំរបស់គណៈកម្មការសុរិយោដីត្រូវធ្វើឡើងជាសាធារណៈ ។

គណៈកម្មការសុរិយោដី ត្រូវរក្សាឯកសារផ្លូវការនៃវិវាទនីមួយៗ ដែលរួមមានឯកសារទាំងអស់ និងភស្តុតាងជាក់ស្តែងថ្មាល់មាត់ និងលាយលក្ខណ៍អក្សរ អំពីវិវាទ ។ ឯកសារផ្លូវការដែលទាក់ទងនឹងវិវាទ ត្រូវបានបើកឱ្យភាគីពាក់ព័ន្ធពិនិត្យ ។

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវអមដោយរបាយការណ៍ស្តីពីដំណើររឿង និងដំណើរការដោះស្រាយវិវាទ ដែលផ្អែកលើភស្តុតាងទាំងឡាយ ដែលអាចទុកចិត្តបាន និងត្រឹមត្រូវ ដែលជាផ្នែកនៃឯកសារផ្លូវការ ។

ច្បាប់ចម្លងនៃសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱ្យភាគីវិវាទនីមួយៗ ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ២៨ ..

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ជំពូកទី ១១

ប្រភពធនធាន

មាត្រា ២៩ ..

គណៈកម្មការសុរិយោដី មានថវិកាដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ៣០ ..

ប្រភពធនធាន និងថវិកា របស់គណៈកម្មការសុរិយោដី ត្រូវបានផ្តល់ដោយ :

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេសក្រៅ ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

ជំពូកទី ១២

អវសានប្បញ្ញត្តិ

មាត្រា ៣១ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣២ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣២
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៣៤...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការកែប្រែមាត្រា ៥ និង មាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ : មាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ត្រូវបានកែប្រែដូចខាងក្រោម :

មាត្រា ៥ ថ្មី : គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដឹកនាំដោយប្រធានមួយរូប ដែលជាអភិបាលស្រុក ខណ្ឌ និង អនុប្រធានមួយរូប ដែលជាប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាលស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានមន្ត្រីនៃការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងភូមិបាល ស្រុក ខណ្ឌ ជាសមាជិក ។

ប្រធានគណៈកម្មការសុរិយោដីនេះ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដី ឃុំ សង្កាត់ ភូមិ ដែលពាក់ព័ន្ធ ឬ/និងចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាជ្ញាធរ ។

មាត្រា ២៨ ថ្មី : - គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក ខណ្ឌ ។

- គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។
- គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន អភិបាលខេត្ត ក្រុងទាំងអស់ និងមន្ត្រី ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១២ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-ដូចមាត្រា ៣
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:០៤១.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋាន សុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ ១២១ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា ៩ និងមាត្រា ១៣ នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលមាត្រា ៦ មាត្រា ៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ស ម្រ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

បង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មាត្រា ២ .-

ផ្តល់តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មកស្ថិតនៅក្រោមនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី ២

តួនាទី និងភារកិច្ច

មាត្រា ៣ .-

នាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដែលជាសេនាធិការឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចខាងក្រោម÷

- ទទួលសំណុំរឿងពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងបណ្តឹងទាមទារផ្សេងៗទាក់ទងនឹងវិវាទដីធ្លី
- ធ្វើការស៊ើបអង្កេតតាមការណែនាំរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- តាមដាន ត្រួតពិនិត្យ និងធ្វើស្ថិតនូវរាល់ករណីវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដីដែលកើតមានឡើងទូទាំងប្រទេស រួមមានវិវាទដីធ្លីដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ និងវិវាទដីធ្លីដែលកើតមានក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបាននៅគណៈកម្មការរដ្ឋបាល
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកការគាំទ្រផ្នែកថវិកា និងបច្ចេកទេសនានាលើការងារដោះស្រាយវិវាទដីធ្លី
- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រដល់ការអនុវត្តការងារដោះស្រាយវិវាទដីធ្លី
- រៀបចំវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយវិធីសាស្ត្រដោះស្រាយវិវាទដីធ្លី
- លើកផែនការថវិកា និងផែនការសកម្មភាពរបស់នាយកដ្ឋាន និង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ។

មាត្រា ៤ .-

នាយកដ្ឋានកិច្ចការវិវាទដីធ្លី ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួនតាមការចាំបាច់។

មាត្រា ៥ ..

នាយកដ្ឋានកិច្ចការវិវាទដីធ្លី មានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី ៣

អវសានប្បញ្ញត្តិ

មាត្រា ៦ ..

មាត្រា ១៩ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តនៃគណៈកម្មការសុរិយោដី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៧ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ [illegible] ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០០ អនក្រ.ត.ត

ក្រសួង.ជ.ន.ស.
ចូល
លេខ ៩៤៨
ឆុតថ្ងៃ ៥.2.19
មញ្ញន

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ៤៧ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ៤៦៩ អនក្រ.តត ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១.-

កែសម្រួលសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចខាងក្រោម៖

១-ឯកឧត្តម	**ជា សុផារ៉ា**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
២-ឯកឧត្តមបណ្ឌិតសភាចារ្យ	**ហ៊ីង ថូរ៉ាក់ស៊ី**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣-ឯកឧត្តម	**អ៊ុត សំអន**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក

មាត្រា ២. _

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣. _

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ : ១១៤ សនស/ប្រក

ប្រកាស

ស្តីពី

គោលការណ៍ណែនាំ និង នីតិវិធី

របស់គណៈកម្មការសុរិយោដី

ជម្រាបជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងបង្គោលសុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យ លេខ ៤៨ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញប្រកាស លេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង តូនាទីភារកិច្ចរបស់បណ្តាការិយាល័យ ក្រោមឱ្យវាទ

- តាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

សំ រ រ ច

១. និយមន័យ

ប្រការ ១ :-

ប្រកាសនេះកំណត់នីតិវិធីនៃការដាក់ពាក្យប្តឹង ការសម្រុះសម្រួល និង ការសំរេចលើបញ្ហាវិវាទដីធ្លីដែលបានប្តឹងទៅគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ។

ប្រការ ២ :-

គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ (គសសខ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៤ និង មាត្រា ៥ នៃអនុក្រឹត្យ លេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (គសខក) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និង មាត្រា ១២ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ (គសជ) គឺជាគណៈកម្មការដែលបានបង្កើតឡើងដោយអនុលោមតាមមាត្រា៣ និងមាត្រា១៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

" គណៈកម្មការរដ្ឋបាល " គឺជាគណៈកម្មការដែលបានបង្កើតឡើងដើម្បីដឹកនាំការចុះបញ្ជីដីធ្លីជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ។ ភារកិច្ចមួយនៃគណៈកម្មការនេះ គឺធ្វើការដោះស្រាយវិវាទដីធ្លីដែលកើតមាននៅក្នុងអំឡុងពេលនៃការចុះបញ្ជី

មានលក្ខណៈជាប្រព័ន្ធស្របតាមមាត្រា ៣ នៃអនុក្រឹត្យ លេខ ៤៦ អនក្រ/បក ស្តីពីនីតិវិធីនៃការកសាងបង់សុរិយោដី និង ស្បៀវភៅគោលបញ្ជីដីធ្លី ។

" ដីដែលមិនទាន់បានចុះបញ្ជីសុរិយោដី " គឺជាក្បាលដីទាំងឡាយដែលមិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ឬ មានលក្ខណៈដាច់ដោយដុំស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ។

"បុគ្គល" រួមមាន រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

" ដើមបណ្តឹង" គឺជាជនដែលធ្វើការប្តឹងទាមទារអោយមានការដោះស្រាយវិវាទដោយអនុលោមតាមប្រកាសនេះ ។

" ចុងបណ្តឹង" គឺបុគ្គលដែលជំទាស់ទៅនឹងដើមបណ្តឹង ។

២. ការចាប់ផ្តើមដំណើរការដោះស្រាយវិវាទ

ប្រការ ៣ :-

បុគ្គលទាំងឡាយដែលទាមទារកម្មសិទ្ធិ (ឬ សិទ្ធិកម្មសិទ្ធិ) ឬភោគៈ (ឬ សិទ្ធិភោគៈ) លើដីមិនទាន់បានចុះបញ្ជីសុរិយោដី ហើយដីនោះមានបុគ្គលម្នាក់ ឬច្រើននាក់ផ្សេងទៀតបានទាមទារមួយផ្នែកឬទាំងមូលដែរ អាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរិយោដីថ្នាក់ស្រុក ឬ ខណ្ឌ ដែលដីនោះស្ថិតនៅ ។

ប្រការ ៤ :-

បុគ្គលដែលប្តឹងទាមទារធ្វើជាកម្មសិទ្ធិករ ឬ ភោគីនៃដីត្រូវដាក់ពាក្យបណ្តឹង លើកលែងតែក្នុងករណីដែលជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យបណ្តឹងក្នុងនាមជននោះបាន ។

ប្រការ ៥ :-

បណ្តឹងទាមទារ ត្រូវធ្វើតាមទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ១នៃប្រកាសនេះ ។ ដើមបណ្តឹង អាចទទួលយកទម្រង់បែបបទនៃពាក្យបណ្តឹងនេះពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចធ្វើទម្រង់បែបបទនៃពាក្យបណ្តឹងរបស់ខ្លួនបាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទនៃពាក្យបណ្តឹង ដូចមាន កំណត់នៅក្នុងឧបសម្ព័ន្ធទី ១ ។

ពាក្យបណ្តឹង ត្រូវបញ្ចូលពត៌មានស្តីពីដើមបណ្តឹងដូចតទៅ : ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ភេទ ឈ្មោះ សហព័ទ្ធ (ប្តី-ប្រពន្ធ) កូន ឃុំ ស្រុក ខេត្ត មុខរបរ អាស័យដ្ឋានបច្ចុប្បន្ន ទីតាំងជំរិវាទ សេចក្តីពណ៌នាពីវិវាទដោយមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ឯកសារពាក់ព័ន្ធនានា ឈ្មោះ និង អាស័យដ្ឋានរបស់ចុងបណ្តឹង ។ ដើមបណ្តឹងត្រូវផ្តល់រាល់ពត៌មានដូចបានតំរូវនៅក្នុងទម្រង់បែបបទបណ្តឹងហើយត្រូវចុះកាលបរិច្ឆេទ និង ចុះហត្ថលេខា ឬ ផ្តិតមេដៃលើពាក្យបណ្តឹងនោះ ។

ដើមបណ្តឹងត្រូវ ផ្តល់បែបបទបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន ០៤ ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំឯកសាររបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹងនោះដើមបណ្តឹងត្រូវផ្តល់ឯកសារពាក្យបណ្តឹងមួយច្បាប់ៗដល់ចុងបណ្តឹងម្នាក់ៗដែលមានឈ្មោះ ។

ប្រការ ៦ :-

នៅពេលទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបើកសំណុំរឿង ហើយត្រូវកំណត់លេខដើម្បី ជាការសំគាល់សំណុំរឿងវិវាទតាម ខេត្ត និងស្រុក ដែលជំរិវាទនោះស្ថិតនៅ ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវចុះលេខសំគាល់សំណុំរឿងវិវាទ ចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនៃពាក្យបណ្តឹងច្បាប់ដើម ហើយផ្តល់ឯកសារដែលបានចុះបញ្ជីមួយច្បាប់ទៅដើមបណ្តឹងវិញ ។ ឯកសារនេះគឺជាភស្តុតាងនៃការដាក់ ពាក្យបណ្តឹងរបស់ដើមបណ្តឹង ។

មន្ត្រីទទួលពាក្យបណ្តឹង ត្រូវថតចម្លងឯកសារនានាដែលបានភ្ជាប់មកជាមួយពាក្យបណ្តឹងហើយត្រូវបញ្ចូលឯកសារថតចម្លងទាំងនេះទៅក្នុងសំណុំរឿងផ្លូវការ ។ មន្ត្រីទទួលពាក្យបណ្តឹង ត្រូវបង្វិលឯកសារច្បាប់ដើមទៅអោយដើមបណ្តឹងវិញ ។

ប្រការ ៧ :-

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យបណ្តឹង គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបិទផ្សាយពាក្យបណ្តឹងនោះរួមជាមួយនិងសេចក្តីជូនដំណឹងអំពីបណ្តឹងរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដែលបញ្ជាក់ថាពាក្យបណ្តឹងនោះបានចុះបញ្ជីហើយ ។ សេចក្តីជូនដំណឹងពីបណ្តឹងត្រូវធ្វើឡើងតាមទម្រង់បែបបទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ២ ។ សេចក្តីជូនដំណឹងនោះ ត្រូវអញ្ជើញបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍នៅក្នុងជំរិវាទអោយឆ្លើយតបចំពោះពាក្យបណ្តឹងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយសេចក្តីជូនដំណឹង និងពាក្យបណ្តឹងនោះ ។

ពាក្យបណ្តឹង និង សេចក្តីជូនដំណឹងអំពីពាក្យបណ្តឹងមួយច្បាប់ត្រូវបិទផ្សាយនៅការិយាល័យរៀបចំដែនដី នគរូប-នីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ហើយសាធារណជនអាចចូលមើលបានដោយសេរីក្នុងអំឡុងពេលម៉ោងធ្វើការធម្មតា ។ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបមើលសេចក្តីជូនដំណឹងដែលបាន បិទផ្សាយនោះដើម្បីអោយដឹងថា តើខ្លួនមានផលប្រយោជន៍នៅក្នុងវិវាទនោះឬទេ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបិទសេចក្តីជូនដំណឹងមួយច្បាប់នៅលើទីតាំងដីដែលមានវិវាទ ។

ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹងអំពីការប្តឹងទាមទារនោះ តាមរយៈការផ្តល់ដល់ចុងបណ្តឹង នូវពាក្យបណ្តឹងដែលបំពេញរួចម្តាក់មួយច្បាប់ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបចំពោះបណ្តឹងទាមទារនោះ ហើយត្រូវជូនដំណឹងដល់ចុងបណ្តឹងអំពីសិទ្ធិចូលរួមប្រជុំជាមួយគណៈកម្មការសុរិយោដី ថ្នាក់ស្រុក ខណ្ឌ ដើម្បីពិគ្រោះយោបល់អំពីបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់អោយចុងបណ្តឹងនូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល ។

ប្រការ ៨ :-

ចុងបណ្តឹងដែលមានឈ្មោះក្នុងពាក្យបណ្តឹង អាចឆ្លើយតបចំពោះបណ្តឹងតាមរយៈការដាក់សំណុំបែបបទឆ្លើយតបចំពោះបណ្តឹងដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី ៤ ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានទទួលឯកសារចម្លងនៃពាក្យបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ចុងបណ្តឹងនូវឯកសារថតចម្លងមួយច្បាប់នៃពាក្យបណ្តឹង និង សេចក្តីសង្ខេបអំពីរបៀប សម្រុះសម្រួល ។

រាល់បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅក្នុងដីវិវាទនេះ ត្រូវដាក់បែបបទឆ្លើយតបចំពោះបណ្តឹងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីពេលដែលសេចក្តីជូនដំណឹងអំពីបណ្តឹងត្រូវបានបិទផ្សាយនៅការិយាល័យគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និង នៅលើទីតាំងដីវិវាទដោយគិតតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងមួយណាដែលបិទក្រោយគេ ។

ចុងបណ្តឹង អាចទទួលបានទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬអាចដាក់ទម្រង់បែបបទរបស់ខ្លួនផ្ទាល់បាន អោយតែទម្រង់បែបបទនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទម្រង់បែបបទដូចមាន កំណត់ក្នុងឧបសម្ព័ន្ធទី ៤ ។

ចុងបណ្តឹងនោះ ត្រូវផ្តល់ទម្រង់បែបបទឆ្លើយតបចំពោះបណ្តឹងដែលបំពេញរួចយ៉ាងហោចចំនួន០៤ច្បាប់ ដែលមួយច្បាប់សំរាប់រក្សាទុកក្នុងសំណុំរឿងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មួយច្បាប់សំរាប់បិទផ្សាយ មួយច្បាប់សំរាប់បញ្ជូនទៅអោយដើមបណ្តឹងវិញ និងមួយច្បាប់ទៀតសំរាប់ចុងបណ្តឹង ។ ក្នុងករណីមានចុងបណ្តឹង ឬដើមបណ្តឹងច្រើននាក់មានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះចុងបណ្តឹងត្រូវផ្តល់ឯកសារចម្លងឆ្លើយតបចំពោះបណ្តឹងដល់ចុងបណ្តឹង និង/ឬ ដើមបណ្តឹង ដែលមានឈ្មោះ ម្នាក់ៗមួយច្បាប់ ។

ចុងបណ្តឹង ត្រូវបង្ហាញឯកសារពាក់ព័ន្ធនៅពេលដាក់ពាក្យឆ្លើយតបចំពោះបណ្តឹង ។ មន្ត្រីទទួលពាក្យត្រូវថតចម្លងឯកសារដែលបានដាក់ភ្ជាប់មកជាមួយនោះ រួចហើយបង្វិលឯកសារច្បាប់ដើមទាំងនោះទៅអោយចុងបណ្តឹងវិញ ។

ពាក្យឆ្លើយតប និង ឯកសារដែលបានភ្ជាប់មកជាមួយនោះ ត្រូវបញ្ជូលទៅក្នុងសំណុំរឿងវិវាទផ្លូវការ ។

ប្រការ ៩ :-

គ្មានករណីណាមួយដែលដើមបណ្តឹង ឬ ចុងបណ្តឹងណាម្នាក់ត្រូវបានគេសុំ ឬតម្រូវអោយបង់ថ្លៃដាក់ពាក្យបណ្តឹង ឬពាក្យឆ្លើយតបឡើយ ។

៣ . ការស៊ើបអង្កេត

ប្រការ ១០ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចាត់មន្ត្រីសុរិយោដីចុះទៅធ្វើការស៊ើបអង្កេតបណ្តឹង ។ អ្នកស៊ើបអង្កេតត្រូវចុះទៅជួបភាគីទាំងអស់ កត់ត្រាសេចក្តីអះអាងរបស់ភាគី និងប្រមូលរាល់ពត៌មានទាក់ទងផ្សេងៗ និង ភស្តុតាងផ្សេងៗទាក់ទងនឹងវិវាទនោះ រួមទាំងពត៌មានដែលចាំបាច់ដើម្បីកំណត់ថា តើភាគីពាក់ព័ន្ធទាំងអស់ក្នុងវិវាទដីធ្លីនេះមានឈ្មោះនៅក្នុងសំណុំរឿងវិវាទដែលបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយឬនៅ ថាជាភាគីនៃវិវាទឬ អត់ ។ ការស៊ើបអង្កេតត្រូវចាប់ផ្តើមអោយបានឆាប់បំផុតតាមដែលអាចធ្វើទៅបានបន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យបណ្តឹង ។

ប្រការ ១១ :-

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវវាស់វែង និងកំណត់ព្រំដីដែលមានវិវាទ ស្របតាមនីតិវិធីដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។ ប្រសិនបើរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ មិនអាចបំពេញការ

ទទួលខុសត្រូវនេះបានដោយសារតែខ្លួនពុំមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នោះអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាល សុរិយោដីខេត្ត ក្រុង ។

ប្រការ ១២ :-

អ្នកស៊ើបអង្កេតមានសិទ្ធិជួបបុគ្គលណាម្នាក់ ឬ មានសិទ្ធិមើលឯកសារដែលកំណត់ថាចាំបាច់សំរាប់ការស៊ើបអង្កេតឱ្យបានពេញលេញ ។

បុគ្គលទាំងឡាយរួមទាំងសាក្សីរបស់ភាគី និង សាក្សីឯទៀតត្រូវជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើខ្លួនត្រូវបានស្នើសុំដោយអ្នកស៊ើបអង្កេត ហើយអ្នកស៊ើបអង្កេតត្រូវកំណត់ការប្រជុំតាមពេលវេលា និង ទីកន្លែងដែលងាយស្រួលចំពោះអ្នកពាក់ព័ន្ធ ទាំងឡាយ ។

ឯកសារច្បាប់ដើមទាំងឡាយត្រូវបង្វិលទៅអោយអ្នកដែលផ្តល់ឯកសារនោះវិញ ហើយច្បាប់ថតចម្លងនៃឯកសារនោះត្រូវរក្សាទុកនៅក្នុងកំណត់ហេតុផ្លូវការនៃវិវាទ ។

ប្រការ ១៣ :-

ភាគីវិវាទនីមួយៗ ត្រូវមានវត្តមានក្នុងពេលធ្វើការស៊ើបអង្កេតដល់ទីកន្លែង និងត្រូវចាំន់ស្មានសោហ៊ុយដែលទាក់ទងទៅនឹងការស៊ើបអង្កេតម្តងទៀតក្នុងករណីដែលមានភាគីណាមួយអវត្តមាន ។ បើអវត្តមានរបស់ភាគីមួយបង្កឡើងដោយសារទង្វើមិនសមរម្យរបស់ភាគីឯទៀត នោះភាគីដែលមានកំហុសត្រូវចេញសោហ៊ុយសំរាប់ថ្លៃការស៊ើបអង្កេតជាថ្មីនោះ។

ប្រការ ១៤ :-

ភាគីវិវាទ អាចផ្តល់ភស្តុតាង និងសាក្សីបាន ហើយរាល់ភស្តុតាង និងចម្លើយរបស់សាក្សីទាំងនោះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

អ្នកស៊ើបអង្កេត ត្រូវទទួលយក និង បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនូវរាល់ភស្តុតាងដែលត្រូវបានផ្តល់ដោយភាគី ឬ ដែលត្រូវបានប្រមូលក្នុងអំឡុងពេលធ្វើការស៊ើបអង្កេត ។ ភស្តុតាងទាំងនោះមានជាអាទិ៍ :

- ផែនទី ឬ កំណត់ហេតុអង្កេតវាស់វែង
- ឯកសារសំគាល់ការកាន់កាប់ដី
- រូបថត របស់ភាគីកាន់កាប់ដី ។ ល

- សំបុត្រស្គាមផ្សេងៗដែលបានផ្ញើដោយមានចុះអាស័យដ្ឋាននៃដីនោះ សំបុត្រកំណើត ឬ ប័ណ្ណគ្រួសារ ដែលបង្ហាញពីវត្តមានយូរអង្វែងនៅលើដីនោះ ឬស្បៀវភៅសម្រង់ស្ថិតិរបស់ប្រធានភូមិ
- ចម្លើយរបស់អ្នកជិតខាងថា តើនរណាដែលបានរស់នៅលើដីនោះ
- បង្កាន់ដៃទទួលប្រាក់ ឬ ឯកសារផ្សេងៗទាក់ទងទៅនឹងការទិញដី ឬ ការផ្ទេរសិទ្ធិនៃដីនោះ ។

ប្រការ ១៥ :-

អ្នកស៊ើបអង្កេត ត្រូវសម្ភាសន៍សាក្សីទាំងឡាយដែលផ្តល់ដោយភាគីវិវាទ ឬ ដែលអ្នកស៊ើបអង្កេតចាត់ទុកថាចាំបាច់ដើម្បីបញ្ជាក់អង្គហេតុនៃវិវាទ ។ សាក្សីនីមួយៗត្រូវធ្វើសម្បថ ថានឹងនិយាយតែការពិតហើយរាយការណ៍រាល់ព្រឹត្តិការណ៍ និង អង្គហេតុទាំងឡាយដែលសាក្សីយល់ និងជឿថាត្រឹមត្រូវ ។

អ្នកស៊ើបអង្កេត ត្រូវពិនិត្យសាក្សីនីមួយៗដើម្បីកំណត់អំពីភាពគួរអោយជឿបាននៅក្នុងចម្លើយរបស់សាក្សី តើសាក្សីដឹងកំរិតណា ការដឹងរបស់សាក្សីផ្អែកលើព្រឹត្តិការណ៍ទាំងឡាយដែលបានសង្កេតឃើញដោយខ្លួនឯងផ្ទាល់ ឬដោយគ្រាន់តែបានឮពីអ្នកណាម្នាក់ផ្សេងទៀត ។ ចម្លើយសាក្សី និង ការសម្ភាសន៍សាក្សីត្រូវទុកជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទ ។

ប្រការ ១៦ :-

អ្នកស៊ើបអង្កេត ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការស៊ើបអង្កេតដោយអនុលោមតាមទំរង់នៃស្តង់ដារដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥។ លទ្ធផលទាំងនេះត្រូវរួមបញ្ចូលនូវ ព្រំដីវិវាទ ផែនទី ឬ តំនូសតាងពាក់ព័ន្ធ សេចក្តីសង្ខេបអំពីចម្លើយរបស់សាក្សី និងចម្លើយលាយលក្ខណ៍អក្សរ សេចក្តីសង្ខេបនៃរាល់ឯកសារពាក់ព័ន្ធទៅនឹងជីវិវាទដែលមានការអះអាងដោយអ្នកស៊ើបអង្កេត ឬ ដែលបានទទួលពីភាគីវិវាទ។

៤. ការកំណត់អំពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ក្នុងការសម្រុះសម្រួលវិវាទ

ប្រការ ១៧ :-

បន្ទាប់ពីការស៊ើបអង្កេតត្រូវបានបញ្ចប់ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវកំណត់ថាតើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានសមត្ថកិច្ចធ្វើការសម្រុះសម្រួលវិវាទនោះដែរឬទេ ។

វិវាទទាំងឡាយត្រូវ សម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ លើកលែងតែប្រធានគណៈកម្ម-

ការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាវិវាទនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដោយសំអាងលើហេតុផលនានាដូចមានចែងនៅក្នុងប្រការ ១៨ នៃប្រកាសនេះ ឬ ដោយវិវាទនោះកើតឡើងដោយសារភាគីមួយ ឬច្រើនប្តឹងផ្អែកលើមូលដ្ឋានមិនច្បាស់លាស់ដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ។

ប្រការ ១៨ :-

ប្រសិនបើវិវាទមិនអាចដោះស្រាយបានដោយសមធម៌នៅថ្នាក់ស្រុក ខណ្ឌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដាក់សំណុំរឿងវិវាទនោះដោយផ្ទាល់ជូនទៅគណៈកម្មសុរិយោដីថ្នាក់ខេត្ត ក្រុង តាមការយល់ឃើញផ្ទាល់របស់ប្រធាន ឬ តាមសំណើរបស់ភាគីវិវាទទាំងសងខាងដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ/បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

ប្រសិនបើមានភាគីតែម្ខាង ស្នើអោយបញ្ជូនករណីវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង វិវាទនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងលើកលែងតែប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ យល់ឃើញថាសំណើនោះមិនសមហេតុផល។ ហេតុផលនៃការបដិសេធសំណើនោះរួមមានការកំណត់របស់ប្រធានគណៈកម្ម-ការដែលយល់ថាសំណើនោះធ្វើឡើងគ្រាន់តែដើម្បីឱ្យមានការយឺតយ៉ាវដល់ការដោះស្រាយវិវាទ ឬ បង្កអោយមានការលំបាកដល់ភាគីម្ខាងទៀត និងអាច មានហេតុផលផ្សេងទៀត ។

ប្រសិនបើប្រធានគណៈកម្មការ បដិសេធមិនបញ្ជូនវិវាទនោះដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង តាមសំណើរបស់ភាគីម្ខាង ប្រធានគណៈកម្មការត្រូវពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធសំណើនោះ ហើយការពន្យល់នេះត្រូវតែជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទនោះ ។ ការសម្រុះសម្រួលដែលតម្រូវឱ្យមានការបញ្ជូនករណីវិវាទ ទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង រួមមាន :

- ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
- ភាគីម្ខាងនៃវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់
- ករណីមានវិវាទពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការថ្នាក់ស្រុក ខណ្ឌ
- វិវាទពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ។

ក្នុងករណីណាក៏ដោយ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មិនមានសិទ្ធិអំណាចសម្រុះសម្រួលវិវាទដែលទាក់ទងទៅ នឹងដីសាធារណៈរបស់រដ្ឋឡើយ ។

ប្រការ ១៩ :-

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវច្រានចោលបណ្តឹងទាមទារណាដែលមិនត្រឹមត្រូវ ឬ គ្មានមូលដ្ឋាន ឬ ដែលធ្វើឡើងដើម្បីយារយី ឬ បំភិតបំភ័យភាគីម្ខាង ។ ការច្រានចោលបណ្តឹងមិនមែនជាប្រការគួរលើកទឹកចិត្តអោយធ្វើនោះទេលើកលែងតែក្នុងករណីចាំបាច់ដើម្បីរារាំងភាពអយុត្តិធម៌តែប៉ុណ្ណោះ។

បណ្តឹងមិនត្រឹមត្រូវ គឺបណ្តឹងដែលខ្វះមូលដ្ឋានអង្គហេតុសមហេតុផលឬទាក់ទងទៅនឹងវិវាទដែលស្ថិតនៅក្រៅវង់សមត្ថកិច្ចនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ លក្ខខណ្ឌនៃបណ្តឹងដែលមិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ មានជាអាទិ៍ :

- សាក្សី ឬ ភស្តុតាងរបស់ភាគីម្ខាង បង្ហាញថាមានលក្ខណៈក្លែងបន្លំ ឬ ខុស ដូចជា សាក្សីរបស់ភាគីម្ខាងដកពាក្យចម្លើយរបស់ខ្លួនវិញ ឬ ផ្តល់ចម្លើយដែលប្រឆាំងដោយត្រង់ទៅនឹងការទាមទាររបស់ភាគីម្ខាង
- ការស៊ើបអង្កេត និងពត៌មានផ្សេងទៀតដែលភាគីស្នើឡើងមិនបង្ហាញភស្តុតាងណាមួយដែលគាំទ្រដល់ការទាមទាររបស់ភាគីដូចមានក្នុងពាក្យបណ្តឹង ។

ក្នុងករណីបណ្តឹងត្រូវបានច្រានចោល ភាគីអាចប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីណាមួយដែលធ្វើការទាមទារដោយគ្មានមូលដ្ឋាន ឬ មិនមានលក្ខណៈច្បាប់ ត្រូវចេញសោហ៊ុយថ្លៃដំណើរការវិវាទដែលបានចំណាយមកដល់ពេលនោះ និង ត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដោយអនុលោមតាមច្បាប់ភូមិបាល ២០០១ និង ច្បាប់ផ្សេងៗទៀត ។ ត្រូវរារាំងមិនអោយភាគីដែលដាក់ពាក្យបណ្តឹងមិនត្រឹមត្រូវ ប្តឹងទាមទារជាថ្មីម្តងទៀត ។

ភាគីណាដែលបង្ហាញភស្តុតាងក្លែងបន្លំ ត្រូវដកចេញពីដំណើរការវិវាទ ហើយភស្តុតាងត្រូវដកចេញពីកំណត់ហេតុផ្លូវការនៃវិវាទ និងត្រូវទទួលទោសព្រហ្មទណ្ឌបន្ថែមទៀតដូចមានចែងនៅក្នុងច្បាប់ភូមិបាល ២០០១ និងច្បាប់ផ្សេងៗទៀត។ ភាគីណាដែលត្រូវបានរកឃើញថា បានធ្វើការក្លែងបន្លំភស្តុតាង ឬឯកសារអាចទទួលទោសព្រហ្មទណ្ឌដូចមានចែងនៅក្នុងច្បាប់ភូមិបាល ឆ្នាំ ២០០១ និង ច្បាប់ផ្សេងៗទៀត។

៥. ការសម្រុះសម្រួលរបស់គណៈកម្មការ សុរិយោដីថ្នាក់ស្រុក ខណ្ឌ

ប្រការ ២០ :-

បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត មិនតិចជាង ៣០ ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងពីបណ្តឹងត្រូវបានបិទផ្សាយដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដី

ថ្នាក់ស្រុក ខណ្ឌដើម្បីសំរេចលើដំណើរការសម្រុះសម្រួលវិវាទ ។ កិច្ចប្រជុំត្រូវធ្វើឡើងនៅលើដីវិវាទ ឬកន្លែងដែលនៅជិតដីវិវាទតាមដែលអាចធ្វើទៅបាន ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញតំណាងអាជ្ញាធរដែនដីស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ និង/ឬ ចាស់ព្រឹទ្ធាចារ្យនៅក្នុងមូលដ្ឋានឱ្យចូលរួមជាសមាជិកអាជ្ញាធរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវអញ្ជើញភាគីវិវាទមកចូលរួមការប្រជុំរដ្ឋបាលយ៉ាងហោច ៥ ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃប្រជុំនេះ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវផ្តល់ដល់ភាគីទាំងអស់នូវសេចក្តីសង្ខេបអំពីរបៀបសម្រុះសម្រួល និងត្រូវពន្យល់អំពីពត៌មាននេះដល់ភាគីទាំងអស់ ។

នៅពេលប្រជុំរដ្ឋបាលនេះ ភាគីត្រូវជូនដំណឹងដល់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អំពីការស្នើសុំរបស់ខ្លួនឱ្យបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍នានា និង ធ្វើការព្រមព្រៀងជាឯកច្ឆ័ន្ទលើសមាសភាពអ្នកសម្រុះសម្រួលដូចមានចែងក្នុង ប្រការ ២២ នៃប្រកាសនេះ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលវិវាទ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយ និង កំណត់ពេលវេលាសំរាប់ការសម្រុះសម្រួលវិវាទ។

ប្រការ ២១ :-

ប្រសិនបើ មានសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវតែងតាំងសមាជិកថ្មីជំនួសវិញ។

ប្រសិនបើ មានវិវាទអំពីផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ វិវាទនោះត្រូវដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ភាគីអាចប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការត្រូវសំរេចថាតើ សមាជិករូបនោះមានវិវាទអំពីផលប្រយោជន៍ដែលរារាំងមិនឱ្យសមាជិករូបនោះចូលរួមនៅក្នុងការដោះស្រាយវិវាទ ឬទេ ។ វិវាទអំពីផលប្រយោជន៍ដែលចោទប្រកាន់ចំពោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវដោះស្រាយតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ ១៨ នៃប្រកាសនេះ ។

ប្រការ ២២ :-

ភាគីវិវាទ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជ្ញាកុក និងសមាជិកអចិន្ត្រៃយ៍នៃគណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នៅក្នុងលក្ខខណ្ឌតែមួយគត់គឺភាគីទាំងអស់ព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរក្នុងការប្រើអ្នកសម្រុះសម្រួលជាក់លាក់នោះ ។

ក្នុងករណីភាគីវិវាទមិនអាចព្រមព្រៀងគ្នាលើសមាសភាពអ្នកសម្រុះសម្រួលជាក់លាក់ណាមួយមកពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវចាត់តាំងអ្នកសម្រុះសម្រួលចេញពីសមាជិកអាជ្ញាកុក និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣ រូប ដែលមានម្នាក់ជាប្រធាន ត្រូវសម្រុះសម្រួលវិវាទ ។

សមាជិកទាំងឡាយនៃក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវមានសមាជិកម្នាក់ដែលបានទទួលការបណ្តុះបណ្តាល ឬមានបទពិសោធន៍នៅក្នុងការសម្រុះសម្រួលវិវាទ និង មានសមាជិកម្នាក់ជាអ្នកដឹងអំពីស្ថានភាព និងសភាពការណ៍នៅក្នុង មូលដ្ឋាន។

ប្រសិនបើ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ កំណត់ថាគ្មានសមាជិកណាម្នាក់នៃសមាជិកក្រុមអ្នកសម្រុះសម្រួលមានបទពិសោធន៍ ឬ ការបណ្តុះបណ្តាលនៅក្នុងដំណើរការសម្រុះសម្រួលទេនោះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ចាត់តាំងអ្នកសម្រុះសម្រួលដែលបានទទួលការបណ្តុះបណ្តាលអោយចូលរួមនៅក្នុងក្រុមអ្នកសម្រុះសម្រួល។

ប្រការ ២៣ :-

ភាគីវិវាទអាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្តាល់ឱ្យជួយខ្លួននៅគ្រប់ថ្នាក់នៃដំណើរការសម្រុះសម្រួល។ បុគ្គលរូបនេះហៅថាអ្នកជំនួយការភាគី ឬអ្នកជំនួយការមិនអាចតំណាងឱ្យភាគីបានទេ ប៉ុន្តែអាចផ្តល់យោបល់ដល់ភាគីវិវាទបាន ។ អ្នកជំនួយការភាគី អាចបំភ្លឺយោបល់របស់ភាគី និងអាចចូលរួមនៅក្នុងកិច្ចប្រជុំទាំងឡាយជាមួយអ្នក

សម្រុះសម្រួល និងជាមួយភាគីបាន ប៉ុន្តែមិនអាចនិយាយជំនួសភាគីទៅកាន់អ្នកសម្រុះសម្រួល ឬ ភាគីផ្សេងទៀតបានទេ ឬ មិនអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបានឡើយ ។

ប្រសិនបើអ្នកជំនួយការភាគីនោះបំពានវិធាននៃដំណើរការវិវាទ ក្រុមអ្នកសម្រុះសម្រួលត្រូវផ្តល់ការក្រើនរំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកជំនួយការនោះ ។ ប្រសិនបើអ្នកជំនួយការនោះបន្តបំពានទៀតក្រុមអ្នកសម្រុះសម្រួលត្រូវហាមឃាត់អ្នកជំនួយការនោះមិនឱ្យចូលរួមនៅក្នុងដំណើរការវិវាទតទៅទៀតឡើយ ។ ប្រសិនបើអ្នកជំនួយការត្រូវបានរារាំង ដំណើរការសម្រុះសម្រួលត្រូវផ្អាកមួយរយៈរហូតដល់ភាគីវិវាទជ្រើសរើសអ្នកជំនួយការថ្មីបាន ឬ ព្រមព្រៀងបន្តដំណើរការដោយពុំចាំបាច់មានអ្នកជំនួយការ ។ អ្នកសម្រុះសម្រួលត្រូវផ្តល់អោយភាគីម្ខាងៗនូវឱកាសគ្រប់គ្រាន់ដើម្បីពិគ្រោះយោបល់ជាមួយអ្នកជំនួយការដែលត្រូវបានហាមឃាត់នៅខាងក្រៅកន្លែងធ្វើការសម្រុះសម្រួល ។

ប្រការ ២៤ :-

អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទាំងឡាយរួមគ្នា ឬ ដាច់ដោយឡែកពីគ្នាប្រសិនបើមានការស្នើសុំដើម្បីពិភាក្សាពីបញ្ហារបស់ភាគី ពន្យល់ករណីវិវាទដល់ភាគីវិវាទដោយផ្អែកលើភស្តុតាង និងពិគ្រោះអំពីលទ្ធភាពដំណោះ-ស្រាយនានាដែលអាចមានចំពោះវិវាទ ។ ការពិគ្រោះត្រូវធ្វើឡើងដោយរក្សាការសំងាត់ក្នុងចំណោមភាគីវិវាទអ្នកជំនួយការរបស់ភាគី និង អ្នកសម្រុះសម្រួលហើយមិនត្រូវយកការពិគ្រោះនេះទៅធ្វើជាផ្នែកមួយនៃកំណត់ហេតុផ្លូវការនៃវិវាទឡើយ ។

អ្នកសម្រុះសម្រួល អាចស្នើដំណោះស្រាយដោយផ្អែកលើការយល់ដឹងរបស់ខ្លួនអំពីបំណងរបស់ភាគីវិវាទលើភស្តុតាងដែលមាន និងផ្អែកលើច្បាប់ពាក់ព័ន្ធប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវបង្ខំឱ្យអនុវត្តតាមសំណើរបស់ខ្លួន ឬ មិនត្រូវធ្វើសេចក្តីសំរេចលើ វិវាទនោះឡើយ ។ មានតែភាគីវិវាទទេដែលមានសិទ្ធិសំរេច ឬបដិសេធដំណោះស្រាយបាន ។

ប្រការ ២៥ :-

អ្នកសម្រុះសម្រួលត្រូវវិភាគភស្តុតាង ដែលប្រមូលបាននៅក្នុងពេលស៊ើបអង្កេតដើម្បីយល់អោយបានពេញលេញអំពីស្ថានភាពនៃវិវាទ ប៉ុន្តែអ្នកសម្រុះសម្រួលមិនត្រូវវាយតំលៃភស្តុតាងក្នុងសមត្ថភាពជាផ្លូវការណាមួយឡើយ ។

អ្នកសម្រុះសម្រួលអាចផ្តល់យោបល់ដល់ភាគីវិវាទ អំពីរបៀបបកស្រាយភស្តុតាងវិវាទ ឬ តំលៃនៃភស្តុតាងអាចត្រូវបានបកស្រាយយ៉ាងណា ប៉ុន្តែយោបល់ទាំងនោះពុំមានតំលៃខាងផ្លូវច្បាប់ និង មិនអាចក្លាយជាលំអានសំរាប់អនុវត្តនៅក្នុងដំណើរការសម្រុះសម្រួល ឬ ការវិនិច្ឆ័យណាមួយឡើយ ។

ការវាយតម្លៃភស្តុតាង អាចបញ្ចូលជាផ្នែកមួយនៃរបាយការណ៍សម្រុះសម្រួលដែលត្រូវបញ្ចូលទៅក្នុងកំណត់ហេតុផ្លូវការ នៃវិវាទ ។

ប្រការ ២៦ :-

ប្រសិនបើភាគីទាំងឡាយ អាចឈានដល់ការព្រមព្រៀងក្នុងពេលសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ អ្នកសម្រុះសម្រួលត្រូវបំពេញបែបបទបញ្ចប់វិវាទដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី ៦ ដែលមានរៀបរាប់អំពីដំណើរការដំណោះស្រាយដោយបញ្ជាក់ច្បាស់លាស់ពីការព្រមព្រៀងដោះស្រាយនោះ ។ រាល់ឯកសារឬផែនទីនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយនោះត្រូវតម្កល់ជាមួយបែបបទបញ្ចប់វិវាទ ។

អ្នកសម្រុះសម្រួល ត្រូវអានដំណោះស្រាយព្រមព្រៀងអោយភាគីទាំងអស់ស្តាប់ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើកិច្ចព្រមព្រៀងតែក្នុងករណីដែលភាគីនោះយល់ព្រមលើរាល់ចំណុចនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងនឹងមានសុពលភាពក្នុងករណីដែលភាគីវិវាទទាំងអស់បានព្រមព្រៀង និងបានចុះហត្ថលេខា ឬ បានផ្តិតមេដៃ ។ ភាគីវិវាទត្រូវចុះហត្ថលេខា ឬផ្តិតមេដៃលើបែបបទបញ្ចប់រឿងក្តីរួចតម្កល់បែបបទនោះនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ។ មន្ត្រីទទួលទម្រង់បែបបទបញ្ចប់រឿងក្តីត្រូវចុះហត្ថលេខា និង បោះត្រាផ្លូវការលើទម្រង់បែបបទនេះហើយត្រូវផ្តល់ដល់ភាគីវិវាទនីមួយៗនូវឯកសារថតចម្លងនៃបែបបទនេះ ។ ច្បាប់ថតចម្លងនៃបែបបទបញ្ចប់រឿងក្តីនេះគឺជាភស្តុតាងនៃការដាក់តម្កល់កិច្ចដំណោះស្រាយ។

រាល់ឯកសារទាក់ទងទៅនឹងលទ្ធផលនៃការដោះស្រាយវិវាទរួមទាំងបែបបទបញ្ចប់រឿងក្តី សេចក្តីពណ៌នានៃកិច្ចដំណោះស្រាយ និង ផែនទី ឬ គំនូសតាងនានាដែលអាចបំភ្លឺកិច្ចដំណោះស្រាយ ត្រូវបិទផ្សាយជាសាធារណៈដែលមានរយៈពេលមិនតិចជាង ១៤ ថ្ងៃ ។ បុគ្គលណាក៏ដោយក៏អាចបញ្ចេញមតិលើឯកសារបញ្ចប់រឿងក្តីនេះក្នុងអំឡុងពេលប្រកាសផ្សាយជាសាធារណៈ ។

ក្រុមអ្នកសម្រុះសម្រួល ត្រូវរាយការណ៍អំពីកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ បន្ទាប់មកការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះ ។

ប្រការ ២៧ :-

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវបញ្ជាក់អំពីដំណោះស្រាយជាមួយភាគីវិវាទ និងត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួចនោះនៅពេលទទួលបានការបញ្ជាក់ថាដំណោះស្រាយបានសំរេចដោយស្ម័គ្រចិត្ត និង ថាភាគីវិវាទយល់ពីកិច្ចព្រមព្រៀង ។

ប្រការ ២៨ :-

ប្រសិនបើភាគីមិនអាចឈានដល់ដំណោះស្រាយ ក្រុមអ្នកសម្រុះសម្រួលត្រូវរៀបចំរបាយការណ៍ស្តីពីដំណើរការសម្រុះសម្រួលអនុលោមតាមបែបបទស្តង់ដារដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៧ ។ របាយការណ៍ត្រូវរួមបញ្ចូលពត៌មានជាមូលដ្ឋានស្តីពីភាគីវិវាទ សេចក្តីសង្ខេបជំហររបស់ភាគីវិវាទនិងសេចក្តីសង្ខេបអំពីដំណើរការសម្រុះសម្រួល។ របាយការណ៍នេះត្រូវក្លាយជាផ្នែកមួយនៃកំណត់ហេតុសាធារណៈផ្លូវការនៃវិវាទ និង ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

៦. ការសម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង

ប្រការ ២៩ :-

ករណីសម្រុះសម្រួលជំហានដំបូង រួមមានវិវាទដែលត្រូវបានបញ្ជូនទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីធ្វើការសម្រុះសម្រួលដោយផ្ទាល់ដោយអនុលោមតាមប្រការ១៨ និងប្រការ២១ នៃប្រកាសនេះ ។ ករណីសម្រុះ-សម្រួលជំហានដំបូង ត្រូវបានបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញនៃវិវាទទៅអោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ប្រការ ៣០ :-

ករណីសម្រុះសម្រួលជំហានទី២ រួមមានវិវាទដែលដោះស្រាយមិនបានសំរេចនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ ករណីសម្រុះសម្រួលជំហានទី ២ត្រូវបញ្ជូនអមជាមួយកំណត់ហេតុផ្លូវការពេញលេញ និងរបាយការណ៍សម្រុះ-សម្រួលទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ប្រការ ៣១ :-

ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសំរាប់ការសម្រុះសម្រួលជំហានដំបូង ឬ ការសម្រុះសម្រួលជំហានទី២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងភាគីវិវាទ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងរបស់អាជ្ញាធរដែនដី ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬមន្ទីរជុំវិញខេត្តក្រុងពាក់ព័ន្ធនានាអោយចូលរួមជាសមាជិកអាជីវកុដើម្បីសម្រុះសម្រួលវិវាទ ។ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និង ការជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ប្រសិនបើមាន ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដោះស្រាយរាល់វិវាទអំពីផលប្រយោជន៍ និងកំណត់អ្នកសម្រុះសម្រួលសំរាប់វិវាទនោះ ។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីវិវាទ និងកំណត់ពេលវេលាសំរាប់អោយភាគីបង្ហាញភស្តុតាងបន្ថែមនានា និង ពេលវេលាសំរាប់សម្រុះសម្រួលវិវាទ ។

ប្រការ ៣២ :-

ប្រសិនបើសមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងមានផលប្រយោជន៍ក្នុងវិវាទសមាជិករូបនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទនោះហើយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគី អាចដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិកគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងណាម្នាក់រួមទាំងប្រធានគណៈកម្មការដោយផ្អែកលើមូលដ្ឋាននៃវិវាទអំពីផលប្រយោជន៍របស់សមាជិក ។ សមាជិកដទៃទៀតនៃគណៈកម្មការ ត្រូវសំរេចថាតើសមាជិកដែលត្រូវជំទាស់អំពីវិវាទផលប្រយោជន៍នោះត្រូវរារាំងមិនឱ្យសាមីខ្លួនចូលរួមក្នុង ការដោះស្រាយវិវាទឬទេ ។

ប្រការ ៣៣ :-

ភាគីទាំងឡាយ អាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជីវកុ និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នៅក្នុងលក្ខខណ្ឌតែមួយគឺ ភាគីវិវាទទាំងអស់ព្រមព្រៀងជាលាយលក្ខណ៍អក្សរចំពោះការប្រើប្រាស់អ្នកសម្រុះសម្រួលនោះ ។ ក្នុងករណីភាគីវិវាទទាំងអស់មិនព្រមព្រៀងលើសមាសភាពអ្នកសម្រុះសម្រួលណាមួយដែលមកពីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង នោះប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវចាត់តាំងក្រុមអ្នកសម្រុះសម្រួលក្នុងចំណោមសមាជិកអាជីវកុ និង សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មការ ។

ក្រុមអ្នកសម្រុះសម្រួលមានសមាជិក ៣រូប ដែលមានម្នាក់ជាប្រធានត្រូវសម្រុះសម្រួលវិវាទ ។ ក្រុមអ្នកសម្រុះសម្រួល យ៉ាងហោចណាស់ត្រូវរួមបញ្ចូលសមាជិកមួយរូបជាអ្នកបានទទួលការបណ្តុះបណ្តាល ឬ មានបទពិសោធន៍ក្នុងការសម្រុះសម្រួលវិវាទ និង សមាជិកមួយរូបជាអ្នកដឹងពីស្ថានភាព និង សភាពការណ៍នៅក្នុងមូលដ្ឋាន ។

ប្រការ ៣៤ :-

អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលនៅលើទីតាំងដី ឬ នៅជិតដីវិវាទ លើកលែងតែមានហេតុផលបញ្ជាក់ថាមានការគំរាមកំហែងដល់សន្តិសុខរបស់មន្ត្រីគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ក្នុងករណីអសន្តិសុខដំណើរការសម្រុះសម្រួលវិវាទត្រូវធ្វើឡើងនៅទីកន្លែងដែលមានសន្តិសុខដែលនៅជិតដីវិវាទបំផុត ។

នីតិវិធីរដ្ឋបាលសំរាប់សម្រុះសម្រួលរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រការ ៣៥ :-

នីតិវិធីរដ្ឋបាលនៃដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយសំរាប់កិច្ចដំណោះស្រាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុង ប្រការ២៦ នៃប្រកាសនេះ ។

អ្នកសម្រុះសម្រួល ត្រូវបញ្ជូនកិច្ចដំណោះស្រាយរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ដើម្បីចុះបញ្ជីក្បាលដី ។

ប្រការ ៣៦ :-

នីតិវិធីរដ្ឋបាលសំរាប់បញ្ជាក់អំពីកិច្ចដំណោះស្រាយដែលសំរេចបាននៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ ២៧ នៃប្រកាសនេះ។

ប្រការ ៣៧ :-

នីតិវិធីរដ្ឋបាលសំរាប់ការធ្វើរបាយការណ៍សម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវដូចគ្នានឹងនីតិវិធីទាំងឡាយនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដែលមានចែងលំអិតនៅក្នុងប្រការ២៨ នៃ ប្រកាសនេះ ។

៧. ដំណើរការដោះស្រាយវិវាទរបស់ គណៈកម្មការសុរិយោដីថ្នាក់ជាតិ

ប្រការ ៣៨ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ មានសិទ្ធិសំរេចវិវាទទាំងឡាយដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ហើយដែលមិនអាចដោះស្រាយបានដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង និងរាល់វិវាទដែលកើតមាននៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបានដោយគណៈកម្មការរដ្ឋបាល ។

លើកលែងតែក្នុងករណីបន្ទាន់ដូចមានពណ៌នាក្នុងប្រការ៣៩នៃប្រកាសនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិមិនត្រូវពិនិត្យករណីទាំងឡាយក្នុងឋានៈជាក្រុមអ្នកសម្រុះសម្រួលជំហានដំបូងចំពោះករណីវិវាទណាមួយឡើយ ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនូវករណីវិវាទអមជាមួយកំណត់ហេតុផ្លូវការទាំងមូល និងរបាយការណ៍សម្រុះសម្រួលដែលសង្ខេបដំណើរការវិវាទដែលបានធ្វើនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ នៅគណៈកម្មការរដ្ឋបាលតាមករណីជាក់ស្តែង ។

ប្រការ ៣៩ :-

ក្នុងករណីវិវាទដែលតម្រូវឱ្យមានការសំរេច ឬ ដំណើរការដោះស្រាយជាបន្ទាន់ ដូចជាករណី មានការគំរាមកំហែង ឬការភ័យខ្លាចសមហេតុផលកើតឡើងពីការបង្កអគ្គីភ័យ ការប្រើកំលាំង ឬ ការបំភិតបំភ័យ ភាគីវិវាទអាចស្នើទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិអោយចាត់វិធានការបណ្តោះអាសន្នដើម្បីការពារផលប្រយោជន៍របស់ភាគីនៅពេលដែលវិវាទកំពុងធ្វើការដោះស្រាយ។ ក្នុងស្ថានភាពនេះ ភាគីអាចប្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ ជាតិឱ្យចេញសេចក្តីសំរេចបណ្តោះអាសន្ន ដើម្បីធ្វើអោយស្ថានការណ៍មានស្ថេរភាពរហូតដល់មានការស៊ើបអង្កេត និង សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សេចក្តីសំរេចណ្តោះអាសន្នត្រូវមានខ្លឹមសារជាការរក្សាស្ថានភាពដដែល ។

ប្រការ ៤០ :-

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវកោះប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមតម្រូវការដើម្បីដោះស្រាយវិវាទ ។

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័នពាក់ព័ន្ធអោយចូលរួមជាសមាជិកអាជ្ញាកដើម្បីដោះស្រាយវិវាទ ។ ប្រធានគប្បីយកចិត្តទុកដាក់បញ្ចូលស្ត្រីជាសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

ប្រការ ៤១ :-

បន្ទាប់ពីត្រួតពិនិត្យមើលកំណត់ហេតុផ្លូវការនៃវិវាទ ឬ នៅពេលផ្សេងទៀតក្នុងអំឡុងពេលធ្វើការពិនិត្យវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចសំរេចធ្វើការសម្រុះសម្រួលវិវាទបន្ថែមទៀត ។

នៅក្នុងស្ថានភាពនេះនីតិវិធីរដ្ឋបាលដើម្បីសម្រុះសម្រួលនៅថ្នាក់ជាតិត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈ-កម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដូចមានចែងលំអិតក្នុងប្រការ ២៤ នៃប្រកាសនេះ ។

ប្រសិនបើការសម្រុះសម្រួលមិនបានសំរេច ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវកំណត់កាលបរិច្ឆេទសំរាប់ការធ្វើសវនាការដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

ភាគីអាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឱ្យបញ្ជូនក្រុមអ្នកវិនិច្ឆ័យចល័តទៅកាន់ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងករណីដែលគ្មានការព្រមព្រៀងគ្នារវាងភាគី ទីកន្លែងធ្វើសវនាការត្រូវស្ថិតនៅជិតដីវិវាទបំផុត ។ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ គូវិវាទត្រូវកំណត់ពេលវេលាដើម្បីចុះទៅពិនិត្យមើលទីតាំងដីវិវាទ ឬ ព្រមព្រៀងលើកលែងការស៊ើបអង្កេតបន្ថែមទៀតបាន ។

ប្រការ ៤២ :-

ប្រសិនបើ សមាជិកណាម្នាក់នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានផលប្រយោជន៍នៅក្នុងវិវាទ សមាជិកនោះត្រូវដកខ្លួនចេញពីការដោះស្រាយវិវាទ ហើយប្រសិនបើចាំបាច់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អាចតែងតាំងសមាជិកថ្មីជំនួសវិញ ។

ភាគីអាច ដាក់ពាក្យបណ្តឹងជំទាស់ជាលាយលក្ខណ៍អក្សរចំពោះការចូលរួមរបស់សមាជិករួមទាំងប្រធានគណៈកម្ម-ការសុរិយោដីថ្នាក់ជាតិដោយផ្អែកលើវិវាទអំពីផលប្រយោជន៍របស់សមាជិកនោះ ។ សមាជិកដទៃទៀតនៃ គណៈកម្មការត្រូវសំរេចថា តើសមាជិកដែលត្រូវជំទាស់អំពីវិវាទអំពីផលប្រយោជន៍នោះត្រូវរារាំងមិនអោយចូលរួមក្នុងការដោះស្រាយវិវាទ ឬ ទេ ។

ប្រការ ៤៣ :-

រាល់កិច្ចប្រជុំ ឬសវនាការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិចាត់វិធានការផ្លូវការទាក់ទងទៅនឹងវិវាទត្រូវបើកចំហជាសាធារណៈ ។

សេចក្តីជូនដំណឹងជាមុនអំពីរាល់កិច្ចប្រជុំ ឬ សវនាការដែលជាការចាត់វិធានការផ្លូវការត្រូវជូនដល់សាធារណជន និង ប្រព័ន្ធសារពត៌មាន ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរក្សាទុកកំណត់ហេតុនៃដំណើរការរឿងវិវាទទាំងអស់របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយបុគ្គលណាក៏មានសិទ្ធិមើលកំណត់ហេតុទាំងនោះទោះបីបុគ្គលនោះមាន ឬគ្មានផលប្រយោជន៍នៅក្នុងវិវាទនោះក្តី ។

ប្រការ ៤៤ :-

លើកលែង តែការប្រជុំសំរាប់ការសម្រុះសម្រួលដែលអាចធ្វើឡើងជាមួយភាគីវិវាទដោយឡែកពីគ្នា គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអញ្ជើញភាគីដែលមានផលប្រយោជន៍ទាំងអស់ឱ្យចូលរួមរាល់កិច្ចប្រជុំ និងសវនាការទាក់ទងទៅនឹងវិវាទរបស់ពួកគេ ។ សេចក្តីអញ្ជើញ ត្រូវបញ្ជូនទៅអោយភាគី យ៉ាងហោច ១៥ ថ្ងៃនៃថ្ងៃធ្វើការមុនពេលបើកកិច្ចប្រជុំ ឬ សវនាការ ។

ប្រការ ៤៥ :-

ភាគី អាចជ្រើសរើសបុគ្គលម្នាក់តាមជំរើសរបស់ខ្លួនផ្ទាល់ អោយតំណាងខ្លួននៅក្នុងរាល់ដំណើរការ នៃរឿងវិវាទ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បុគ្គលនេះហៅថាអ្នកការពារក្តី អាចផ្តល់ការណែនាំ ឬអាចតំណាងភាគីបាន។ អ្នកការពារក្តីអាចបញ្ជាក់ពីចម្លើយរបស់ភាគី និងអាចចូលរួមកិច្ចប្រជុំជាមួយគណៈកម្មការសុរិយោដីថ្នាក់ជាតិហើយតាម ការយល់ព្រមរបស់ភាគីអាចនិយាយ និងអាចធ្វើសេចក្តីសំរេចក្នុងនាមភាគីបាន ។ ទោះបីជាយ៉ាងណាក្តីបើគ្មានការយល់ ព្រមជាលាយលក្ខណ៍អក្សរជាក់លាក់របស់ភាគីទេនោះ អ្នកការពារក្តីមិនអាចដោះស្រាយវិវាទក្នុងនាមភាគីបានឡើយ។

ប្រសិនបើ អ្នកការពារក្តីបំពានវិធាននៃដំណើរការរឿងវិវាទ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវផ្តល់ការក្រើន រំលឹក និងការព្រមានជាឯកជនម្តងដល់អ្នកការពារក្តី ។ ប្រសិនបើ អ្នកការពារក្តីនៅតែបន្តបំពានទៀតគណៈកម្មការ សុរិយោដីថ្នាក់ជាតិ ត្រូវហាមឃាត់អ្នកការពារក្តីនោះមិនឱ្យចូលរួមក្នុងដំណើរដោះស្រាយវិវាទទៀតឡើយ ។ ប្រសិនបើ អ្នកការពារក្តីត្រូវបានហាមឃាត់មិនឱ្យចូលរួម ដំណើរការរឿងវិវាទនោះត្រូវផ្អាក រហូតដល់ភាគីជ្រើសរើសអ្នកការពារក្តី ថ្មីបានឬយល់ព្រមឱ្យបន្តដំណើរការដោយមិនមានអ្នកការពារក្តី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្តល់ឱកាសគ្រប់ គ្រាន់ដល់ភាគីដើម្បីពិគ្រោះយោបល់ជាមួយអ្នកការពារក្តីដែលត្រូវបានហាមឃាត់អោយនៅក្រៅកន្លែងដោះស្រាយ ។

ប្រការ ៤៦ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចធ្វើសវនាការវិវាទជាក្រុមវិនិច្ឆ័យ ឬ អាចតែងតាំងសមាជិកតែម្នាក់ ឬមន្ត្រី សវនា ការតែមួយរូបឱ្យធ្វើសវនាការបាន ។

រាល់សវនាការ សក្ខីកម្មផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ។

គណៈកម្មការសុរិយោដីថ្នាក់ ជាតិ មិនត្រូវបានតម្រូវអោយគោរពតាមវិធានភស្តុតាង ឬនីតិវិធីផ្លូវការទេ ប៉ុន្តែ ត្រូវធានាឱ្យភាគីទាំងអស់មានឱកាសបង្ហាញសក្ខីកម្ម និង ភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និង សមធម៌ ។

ភាគីនីមួយ។មានសិទ្ធិបង្ហាញសាក្សី និងបដិសេធភស្តុតាង ឬសាក្សីដែលផ្តល់ដោយភាគីផ្សេងទៀត ។ បុគ្គលដែល ផ្តល់សក្ខីកម្មអាចត្រូវបានតម្រូវអោយឆ្លើយនឹងសំនួរបញ្ជាក់អំពីសក្ខីកម្មនោះ ។

ប្រការ ៤៧ :-

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវស្តាប់ភស្តុតាងវិវាទ និង ត្រួតពិនិត្យឯកសារផ្លូវការនៃវិវាទដែលបាន ប្រមូលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ឬ ដោយគណៈកម្មការ រដ្ឋបាល ហើយត្រូវចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពអនុវត្តដោយផ្អែកលើរបាយការណ៍នេះ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចេញសេចក្តីសំរេចនៅពេលធ្វើការសរុបសន្និដ្ឋានការពិភាក្សារបស់ខ្លួនហើយ ត្រូវធ្វើកំណត់សំគាល់សេចក្តីសន្និដ្ឋានខាងផ្លូវច្បាប់ និង មូលដ្ឋានអង្គហេតុនៃសេចក្តីសំរេចរបស់ខ្លួន ។ សេចក្តីសំរេចស្ថាពរត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ចុះហត្ថលេខាដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវផ្ញើអោយភាគីទាំងឡាយតាមរយៈសំបុត្រប្រៃសណីយ៍ និងត្រូវបើកចំហសំរាប់ការពិនិត្យមើលជាសាធារណៈដល់បុគ្គលណាក៏ដោយទោះបីមាន ឬ គ្មានផលប្រយោជន៍នៅក្នុងរឿងវិវាទនោះក្តី ។

សេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ត្រូវអមជាមួយសេចក្តីជូនដំណឹងដែលជំរាបភាគីវិវាទអំពីសិទ្ធិរបស់ពួកគេក្នុងការប្តឹងតវ៉ាទៅតុលាការឱ្យពិនិត្យមើលឡើងវិញផ្នែកច្បាប់ ចំពោះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយត្រូវផ្តល់ពត៌មានអំពីរបៀបប្តឹងទៅតុលាការផង ។

ប្រការ ៤៨ :-

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក្លាយជាសេចក្តីសំរេចស្ថាពរនៅក្រោយ រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចនោះត្រូវបានបញ្ជូនទៅដល់ភាគីវិវាទទាំងអស់ លើកលែងតែករណីមានការប្តឹងទៅតុលាការ ឬមានការស្នើសុំ ឱ្យធ្វើការពិនិត្យឡើងវិញដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ អនុលោមតាមប្រការ ៤៩ នៃប្រកាសនេះ។

ប្រសិនបើគ្មានការប្តឹងតវ៉ាទៅតុលាការ ឬ គ្មានការស្នើសុំអោយធ្វើសវនាការឡើងវិញត្រូវបានធ្វើឡើងតាមពេលវេលាត្រឹមត្រូវទេលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបញ្ជូនសេចក្តីសំរេចនោះទៅការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ។ បន្ទាប់មក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវចាប់ផ្តើមអនុវត្តនីតិវិធីចុះបញ្ជីក្បាលដីដែលត្រូវបានសំរេចនោះ។

ប្រការ ៤៩ :-

ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេ លើកលែងតែមានសម្លេងយល់ព្រមពីសមាជិក ៣ រូប នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលមានកស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការ ។

សំណើសុំធ្វើសវនាការឡើងវិញ ត្រូវដាក់ជូនជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សរត្រូវបានបញ្ជូនទៅដល់ភាគី ហើយត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនោះដោយត្រូវអមដោយពត៌-មាននិងគំនូសតាងចាំបាច់នានា ។

ការធ្វើសវនាការឡើងវិញ ត្រូវអនុលោមតាមសេចក្តីជូនដំណឹង និង លក្ខខណ្ឌតម្រូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

ប្រសិនបើមានការបដិសេធចំពោះសំណើសុំអោយមានសវនាការឡើងវិញ គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនទៅដល់ភាគីវិវាទលើកលែងតែភាគីម្ខាងនៃគូវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការតាមពេលវេលាត្រឹមត្រូវ ។

ប្រការ ៥០ :-

ភាគីណាក៍ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។

ភាគីណាមួយដែលធ្វើបណ្តឹងទៅតុលាការ ត្រូវដាក់តម្កល់ឯកសារថតចម្លងមួយច្បាប់នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

លេខាធិការដ្ឋាន ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

៨. បទឧប្បញ្ញត្តិរដ្ឋបាល

ប្រការ ៥១ :-

ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីបណ្តឹងដែលបានទទួល និង ចំណាត់ការដែលបានធ្វើដោយគណៈកម្មការចំពោះបណ្តឹងនីមួយៗ ដែលគណៈកម្មការបានធ្វើ ។

គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ។

គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើរបាយការណ៍ប្រចាំខែទៅ រាជរដ្ឋាភិបាល ។

របាយការណ៍របស់គណៈកម្មការសុរិយោដី ត្រូវបើកចំហ និង អនុញ្ញាតឱ្យសាធារណជនមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា ។

ប្រការ ៥២ :-

គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ ត្រូវរក្សាទុកកំណត់ហេតុផ្លូវការនៃវិវាទនីមួយៗដែលបានប្តឹងនៅគណៈកម្មការនោះ ។

កំណត់ហេតុផ្លូវការ ត្រូវរួមបញ្ចូលរាល់ឯកសារទាំងអស់ សេចក្តីអះអាងកស្តុតាងផ្សេងៗ និងរបាយការណ៍ផ្សេងៗ ទាក់ទងទៅនឹងវិវាទ ។

ឯកសារផ្លូវការត្រូវបើកចំហជាសាធារណៈ និង អនុញ្ញាតឱ្យសាធារណជនចូលមើលដោយសេរីក្នុងពេលម៉ោងធ្វើការធម្មតា។

បុគ្គលទាំងឡាយដែលចង់ពិនិត្យមើលឯកសារ ត្រូវទៅមើលនៅការិយាល័យគណៈកម្មការសុរិយោដីនោះ និងត្រូវចុះហត្ថលេខាលើស្បៀវភៅក្បៀវ ។

នៅកន្លែងដែលមានសម្ភារៈបរិក្ខារថតចម្លង បុគ្គលទាំងឡាយអាចថតចម្លងឯកសារបាន ។

ប្រការ ៥៣ :-

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និង ប្រធានការិយាល័យវៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាលស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី



អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ៥៣
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ : ០៣៧ ប្រក.ដនស/គសជ

ប្រកាស
ស្តីពី
ការធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដី រាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១០៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- បានឃើញអនុក្រឹត្យលេខ ៣៨អនក្រ.បក. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៨៧អនក្របក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ ចឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

- បានឃើញប្រកាសលេខ ១១២ជនស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី
- បានឃើញប្រកាសអន្តរក្រសួងលេខ ០២ប្រក.ប.០៣. ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី
- បានឃើញសេចក្តីណែនាំរួមលេខ ០៥សណន. ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៦ ស្តីពីការអនុវត្តន៍អនុក្រឹត្យលេខ ៣៤អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៦
- យោងសេចក្តីជូនដំណឹងលេខ ១៦៧៤ សជណ.ខុស. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

ប្រការ១ : ត្រូវបានធ្វើប្រតិភូកម្មមុខងារជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី ។

ប្រការ២ : បទប្បញ្ញតិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ គណៈកម្មការសុរិយោដីរាជធានី ខេត្ត ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី ៥៧ ៥

អ៊ឹម ឈុនលឹម

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
-សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ
-សមាជិកគណៈកម្មការសុរិយោដីរាជធានី ខេត្ត
-ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពជុំវិញក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ដូចប្រការ ៣
-រាជកិច្ច
-ក្រុមការងារគេហទំព័រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ៥៤ ប្រក្ន. ០៣ រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ ឧត្ថិក ឆ្នាំ ២០០៣

ប្រកាសរវន្តរក្រសួង
ស្តីពី
ការកំណត់តារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដី
ពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៨៩/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធមិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ/បក. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-តាមការចាំបាច់របស់ក្រសួងយុត្តិធមិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សំ រ រ ច

ប្រការ១ : វិវាទដីធ្លីទាំងឡាយត្រូវបានបែងចែកទៅតាមសមត្ថកិច្ចនីមួយៗដូចតទៅ ÷

-វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចហើយ គឺដីធ្លីដែលមានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដី ត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ

-វិវាទដីធ្លីដែលមិនទាន់បានចុះបញ្ជីសុរិយោដី គឺដីធ្លីដែលពុំទាន់មានប័ណ្ណសំគាល់សិទ្ធិគ្រប់ប្រភេទចេញដោយរដ្ឋបាលសុរិយោដីត្រូវស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ។

ប្រការ២ : តុលាការគ្រប់ខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រការ៣ : បណ្តឹងវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដែលជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ហើយត្រូវបានតុលាការគ្រប់ថ្នាក់ទទួល និងកំពុងចាត់ការមុនថ្ងៃចេញប្រកាសនេះ តុលាការត្រូវចាត់ការបន្តរហូតចប់សព្វគ្រប់ជាស្ថាពរ ។

ប្រការ៤ : វិវាទអំពីកិច្ចសន្យាពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដីដូចជា វិវាទអំពីការបែងចែកមរតក និងវិវាទអំពីកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ជាដើម ជាសមត្ថកិច្ចរបស់តុលាការ ។

ប្រការ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៦ : តុលាការគ្រប់ថ្នាក់ អគ្គាធិការដ្ឋាន នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានរដ្ឋបាលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីគ្រប់ថ្នាក់មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌

រដ្ឋមន្ត្រី
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

កន្លែងទទួល

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៦ " ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ: ២៤០ ដនស.ប្រក

ថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំវក ព.ស.២៤៦០
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា គ.ស. ២០១៦

ប្រកាស
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការវិវាទដីធ្លីចំណុះអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ ២.-

ប្រកាសនេះមានគោលដៅ ដូចខាងក្រោម÷

- បង្កើតឲ្យមានការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បែងចែកតួនាទី និងភារកិច្ចការិយាល័យនីមួយៗ ដើម្បីធានាប្រសិទ្ធភាព និងប្រសិទ្ធផលការងារ។

ប្រការ ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ជំពូកទី ២

ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី

ប្រការ ៤.-

នាយកដ្ឋានកិច្ចការវិវាទដីធ្លីមានការិយាល័យចំណុះចំនួន ៤ (បួន) ដូចខាងក្រោម÷

- ការិយាល័យកិច្ចការទូទៅ
- ការិយាល័យកិច្ចការគណៈកម្មការសុរិយោដី
- ការិយាល័យកិច្ចការវិវាទដីធ្លី
- ការិយាល័យផ្សព្វផ្សាយ និងសហប្រតិបត្តិការ

អង្គការលេខានៃនាយកដ្ឋានកិច្ចការវិវាទដីធ្លី ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៥ .-

ការិយាល័យកិច្ចការទូទៅ មានតួនាទី និងភារកិច្ចដូចតទៅ÷

- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋាន

- កសាង និងរៀបចំលិខិតបទដ្ឋាននានារបស់នាយកដ្ឋាន និងចរាចរលិខិតទៅគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ
- ទទួលសំណុំរឿងវិវាទដីធ្លីដែលបញ្ជូនមកពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត និងបណ្តឹងទាមទារផ្សេងៗទាក់ទងនឹងវិវាទដីធ្លី ព្រមទាំងឯកសារនានាដែលបញ្ជូនមកពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធ្វើកំណត់ហេតុ និងរបាយការណ៍រាល់កិច្ចប្រជុំនានាពាក់ព័ន្ធនឹងការងាររដ្ឋបាលទូទៅរបស់នាយកដ្ឋាន
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌសម្ភារៈរបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ និងរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៦ ៖

ការិយាល័យកិច្ចការគណៈកម្មការសុរិយោដី មានតួនាទី និងភារកិច្ចដូចតទៅ÷

- ពិនិត្យ សិក្សា និងលើកយោបល់លើសំណុំរឿងវិវាទដីធ្លី និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី
- រៀបចំរបាយការណ៍លើសំណុំរឿងនីមួយៗ ដោយមានការសិក្សាលម្អិតលើអង្គហេតុ អង្គច្បាប់ ការសន្និដ្ឋាន និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច
- សុំគោលការណ៍ និងលើកផែនការចុះស៊ើបអង្កេតលើករណីវិវាទដីធ្លីនីមួយៗក្នុងយន្តការគណៈកម្មការសុរិយោដី
- ចុះស៊ើបអង្កេតតាមការណែនាំរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ
- លើកផែនការសម្រាប់ការដោះស្រាយសំណុំរឿងវិវាទដីធ្លី ទាំងការដោះស្រាយដោយការសម្រុះសម្រួល និងការបើកសវនាការសម្រេច
- លើកផែនការការងារ និងចុះធ្វើការតាមដាន និងត្រួតពិនិត្យការអនុវត្តការងារដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ក្រោមជាតិ
- ជាលេខាធិការសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- ធ្វើកំណត់ហេតុ និងរបាយការណ៍រាល់កិច្ចប្រជុំដោះស្រាយលើសំណុំរឿងវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- រៀបចំឯកសារបញ្ជូនសំណុំរឿងវិវាទដីធ្លី និងភស្តុតាងទាំងអស់ នៅពេលមានបណ្តឹងតវ៉ាលើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទៅតុលាការ
- ប្រមូលចងក្រង និងបញ្ចូលទិន្នន័យស្ថិតិករណីវិវាទ និងសំណុំរឿងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដីដែលកើតមានទូទាំងប្រទេស រួមមានវិវាទដីធ្លីដែលកើតមាននៅក្រៅតំបន់វិនិច្ឆ័យ និង

វិវាទដីធ្លីនៅក្នុងតំបន់វិនិច្ឆ័យដែលមិនអាចដោះស្រាយបាននៅគណៈកម្មការរដ្ឋបាល ក្នុងប្រព័ន្ធកុំព្យូទ័រ

- តាមដានត្រួតពិនិត្យការអនុវត្តច្បាប់ បទបញ្ជា និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងវិវាទដីធ្លីដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការងារជូនថ្នាក់ដឹកនាំ
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៧.-

ការិយាល័យកិច្ចការវិវាទដីធ្លី មានតួនាទី និងភារកិច្ចដូចតទៅ÷

- ពិនិត្យ សិក្សា និងលើកយោបល់លើពាក្យបណ្តឹង និងឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងវិវាទដីធ្លីដែលអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្របញ្ជូនមក
- ចុះអង្កេតស្រាវជ្រាវលើករណីវិវាទដីធ្លីតាមការណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះអង្កេតស្រាវជ្រាវជូនថ្នាក់ដឹកនាំ
- ពិនិត្យតាមដាន និងបញ្ចូលទិន្នន័យស្ថិតិករណីវិវាទដីធ្លីដែលកើតមានទូទាំងប្រទេស និងបណ្តឹងចូលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងប្រព័ន្ធកុំព្យូទ័រ
- តាមដានវឌ្ឍនភាពករណីវិវាទដែលប្តឹងចូលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៨.-

ការិយាល័យផ្សព្វផ្សាយ និងសហប្រតិបត្តិការ មានតួនាទី និងភារកិច្ចដូចតទៅ÷

- លើកដែនការ អប់រំ ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់សមាសភាពពាក់ព័ន្ធ និងប្រជាពលរដ្ឋឱ្យយល់ដឹងអំពីបញ្ហាវិវាទដីធ្លី វិធីសាស្ត្រក្នុងការបង្ការ ទប់ស្កាត់វិវាទដីធ្លី និងអំពីនីតិវិធីនៃការដោះស្រាយវិវាទដីធ្លី
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ ដើម្បីប្រមូលចងក្រងនូវមតិយោបល់ និងបទពិសោធន៍នានាពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនឹងវិវាទដីធ្លី ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទដីធ្លី

- ចងក្រង បោះពុម្ពឯកសារលិខិតបទដ្ឋាន និងខិតប័ណ្ណពាក់ព័ន្ធនឹងការងារវិវាទដីធ្លី ដើម្បីបម្រើការងារផ្សព្វផ្សាយដល់ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងដល់សាធារណជន
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកការគាំទ្រផ្នែកថវិកា និងបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនល្បឿនក្នុងការដោះស្រាយវិវាទដីធ្លី
- ជំរុញ និងលើកទឹកចិត្តដល់គ្រប់មជ្ឈដ្ឋានសាធារណៈទាំងអស់ រួមមានសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាលនានាឱ្យចូលរួមផ្តល់ព័ត៌មាន និងអនុសាសន៍នានា សំដៅបង្ការ ទប់ស្កាត់នូវរាល់បញ្ហាអសកម្មនានាដែលនាំឱ្យកើតមានវិវាទដីធ្លី
- ទំនាក់ទំនងសាធារណៈ និងការងារយេនឌ័រ
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- ធ្វើរបាយការណ៍វឌ្ឍនភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៩.-

ការិយាល័យនីមួយៗចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ដឹកនាំដោយប្រធាន ០១ រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ជំពូកទី ៤
អវសានប្បញ្ញត្តិ

ប្រការ ១០.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១១.-

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុជាវ៉ា

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ..... ចុះថ្ងៃទី ខែ គ.ស. ២០១៦

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការវិវាទដីធ្លី

នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

<u>អង្គការលេខនៃនាយកដ្ឋានកិច្ចការវិវាទដីធ្លី</u>





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៦ ស.ស.រ

សេចក្តីសំរេច
ស្តីពី
ការតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-បានឃើញអនុក្រឹត្យលេខ ៣១២ អនក្រ.តត ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

សម្រេច

ប្រការ១ : ត្រូវបានតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចមានរាយនាមខាងក្រោម :

១. លោក **ឆុឌ្ឍី វណ្ណារ៉ា** អនុប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន

២. លោក **អេ ប៊ុនច្បើន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចកិច្ចការវិនិយោគនិងទំនាក់ទំនងអន្តរជាតិនៃអគ្គ នាយកដ្ឋានរដ្ឋបាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាអនុប្រធាន

ប្រការ២ : លេខាធិការដ្ឋាន នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ មានបេសកកម្មអនុវត្តភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

ប្រការ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ៥ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មការសុរិយោដីថ្នាក់ជាតិ
- រាជធានី សាលាខេត្ត
- គណៈកម្មការសុរិយោដីរាជធានី ខេត្ត
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ ៦៤៥ ដនស/គសជ

សេចក្តីណែនាំ
ស្តីពី
នីតិវិធីសវនាការ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អនុលោមតាមអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការកំណត់អំពីនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចតទៅ :

I.ការចាប់ផ្តើមនៃករណីវិវាទ

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិទទួលករណីវិវាទពីគណៈកម្មការសុរិយោដីខេត្ត ក្រុង និងគណៈកម្មការរដ្ឋ-បាលដែលធ្វើការសម្រុះសម្រួលមិនបានជោគជ័យ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរៀបចំទម្រង់បែបបទបញ្ជាក់ពីការទទួលសំណុំរឿងវិវាទដែលបានបញ្ជូនមក ហើយទំរង់បែបបទនេះត្រូវបានរក្សាទុកក្នុងសំណុំរឿងវិវាទ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចុះលេខសំណុំរឿងវិវាទ ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យមើលឡើងវិញនូវសំណុំរឿងវិវាទផ្លូវការ ហើយធ្វើកំណត់បង្ហាញឱ្យបានឆាប់បំផុតជូនទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ កំណត់បង្ហាញនេះធ្វើការសំគាល់ថា តើសំណុំរឿងវិវាទមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ឬទេ ហើយថាតើតំរូវឱ្យមានការស៊ើបអង្កេតបន្ថែមដែរ ឬទេ ។

៣-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ប្រសិនបើយល់ថាជាការចាំបាច់ ។ នៅដំណាក់កាលណាមួយនៃដំណើរការវិនិច្ឆ័យមុននឹងធ្វើសេចក្តីសំរេច គណៈកម្មការ

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659- 215 660 , Fax : (855) 023 215 277, e-mail : im. c lim @ Camnet Com Kh

សុរិយោដីថ្នាក់ជាតិអាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀតបាន ។ ការស៊ើបអង្កេតនេះគឺត្រូវធ្វើឡើងដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើការបង្គាប់ផ្សេងទៀតដែលចាំបាច់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីរៀបចំសំណុំរឿងវិវាទឱ្យមានលក្ខណៈពេញលេញ និងត្រប់ត្រាន់ ។

II.ការរៀបចំដំណើរការករណីវិវាទ

នៅពេលសំណុំរឿងវិវាទមានលក្ខណៈពេញលេញនិងត្រប់ត្រាន់ហើយនោះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបញ្ជូនសំណុំរឿងនេះទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើការពិនិត្យ ។ ក្រោយពីការពិនិត្យរួច ហើយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចកំណត់ ÷

១-ចំពោះសំណុំរឿងវិវាទដែលចាំបាច់ត្រូវមានការពិភាក្សាផ្ទៃក្នុង ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកអាជ្ញាកណ្តាល (សមាជិកចំពោះកិច្ច) ចូលរួម ។ ការពិភាក្សាផ្ទៃក្នុងនេះជាការពិគ្រោះយោបល់ដើម្បីសំរេចបន្តករណីវិវាទ ឬ ត្រូវច្រានចោលករណីវិវាទតែប៉ុណ្ណោះ ដោយពុំចាំបាច់មានការជូនដំណឹងដល់សាធារណៈជន និងប្រពន្ធ័ផ្សព្វផ្សាយឡើយ ។

២-ចំពោះសំណុំរឿងវិវាទដែលមានពាក្យបណ្តឹងមិនត្រឹមត្រូវឬគ្មានមូលដ្ឋាន ដែលធ្វើឡើងគ្រាន់តែដើម្បីយារយីឬបំភិតបំភ័យភាគីវិវាទម្ខាង ឬមិនស្ថិតក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ទោះស្ថិតក្នុងដំណាក់កាលកំពុងដំណើរការក្នុងនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏ដោយ ប្រធានគណៈកម្មការសុរិ-យោដីថ្នាក់ជាតិ ត្រូវសំរេចច្រានចោលសំណុំរឿងវិវាទនោះ ។

៣-ចំពោះសំណុំរឿងវិវាទដែលមានលក្ខណៈពេញលេញ និងត្រប់ត្រាន់ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចបង្គាប់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីកំណត់អំពីទីកន្លែង និងពេលវេលាដែលនឹងត្រូវរៀបចំសវនាការនៃសំណុំរឿងវិវាទនោះ។ បន្ទាប់ពីបានទទួលរបាយការណ៍អំពីពេលវេលានិងទីកន្លែងច្បាស់លាស់ដែលត្រូវរៀបចំសវនាការ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសំរេចបើកសវនាការលើសំណុំរឿងវិវាទនេះ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការសម្រុះសម្រួលវិវាទបន្ថែមទៀតតាមសំណើរបស់ភាគីវិវាទ ឬតាមការយល់ឃើញរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។ នីតិវិធីរដ្ឋបាលនៃការសម្រុះ-សម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈកម្មការសុរិយោដីស្រុក ខណ្ឌដែរ ។ នៅពេលដំណើរការនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទអាចបដិសេធការចូលរួមរបស់ប្រធាន ឬ សមាជិក រូបណាដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ ។ ប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ត្រូវដកខ្លួនចេញពីការដោះស្រាយករណីវិវាទនោះ ហើយរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងប្រធានអាដហុក (ប្រធានចំពោះកិច្ច) ឬសមាជិកថ្មីជំនួសវិញ ។ ក្នុងកំលុងពេលនៃដំណើរការនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិរហូតដល់ពេលធ្វើសេចក្តីសំរេចលើវិវាទ ភាគីវិវាទនីមួយៗ ឬ តំណាងអាចផ្តល់ឯកសារជា ភស្តុតាង ឬសាក្សីបន្ថែមទៀតក្រៅពីភស្តុតាង និងសាក្សីដែលបានផ្តល់ពីពេលមុន ។

III. ការជូនដំណឹង និងពេលវេលានៃសវនាការ

ក-ការជូនដំណឹង

ការជូនដំណឹងអំពីសវនាការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ច្បាស់លាស់ អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកសវនាការ ។ លិខិតជូនដំណឹងត្រូវប្រគល់ឱ្យដល់ដៃដើមបណ្តឹង ឬតំណាង និង ចុងបណ្តឹង ឬ តំណាង យ៉ាងហោច ១៥ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃបើកសវនាការ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួល និងអ្នកប្រគល់លិខិតជូនដំណឹងនោះ ។ ក្នុងករណីភាគីវិវាទណាមួយបដិសេធមិនទទួល ឬ អវត្តមានពីលំនៅដ្ឋានដោយគ្មានមូលហេតុសមស្រប អ្នកប្រគល់លិខិតត្រូវចារលើខ្នងលិខិតបញ្ជាក់ពីមូលហេតុ។

ខ-ពេលវេលាសវនាការ

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបើកសវនាការចាប់ពីម៉ោង ០៨ : ៣០នាទី ព្រឹក ដល់ម៉ោង ១១ : ៣០ នាទីនៃថ្ងៃធ្វើការ ។ ក្នុងករណីចាំបាច់សវនាការអាចធ្វើនៅម៉ោងផ្សេងពីការកំណត់នេះ ឬអាចបន្តទៅទៀតបាន ។ ការបើកសវនាការអាចដោះស្រាយបណ្តឹងច្រើនករណីបាន ។

គ-ការបង្ហាញខ្លួននៅពេលសវនាការ

១-ប្រសិនបើភាគីដើមបណ្តឹង ឬ តំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវចេញសេចក្តីសំរេចបញ្ចាក់ពីការបញ្ឈប់ដំណើរការដោះស្រាយ ។

២-ប្រសិនបើភាគីចុងបណ្តឹង ឬតំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវសំរេចករណីវិវាទនេះដោយអវត្តមានចុងបណ្តឹង ឬតំណាង។

៣-បើភាគីដើមបណ្តឹង ឬ/និងចុងបណ្តឹង ស្លាប់មុនពេលសវនាការ អ្នកតំណាងស្របច្បាប់របស់ភាគីនោះអាចចូលរួមក្នុងសវនាការបាន ។

៤-សាក្សីគ្រប់រូបត្រូវមកបង្ហាញខ្លួនចំពោះមុខប្រធានសវនាការតាមការអញ្ជើញ ។

IV.**អំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ**

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាដំណើរការនៃការប្រជុំរវាងភាគីវិវាទ (ឬតំណាង) និងសាក្សី ជាមួយនឹងក្រុមវិនិច្ឆ័យ ឬប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬសមាជិកតែម្នាក់ ឬ មន្ត្រីសវនាការ ដែលរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីសំរេចទទួលស្គាល់ភោគីស្របច្បាប់ចំពោះដីវិវាទដែលមិនទាន់ចុះបញ្ជីសុរិយោដី ។ សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើឡើងជាសាធារណៈ ។

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចដឹកនាំដោយ :

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ១ រូប ជាប្រធានសវនាការ ឬ

-សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-មន្ត្រីសវនាការតែ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-ក្រុមវិនិច្ឆ័យមានសមាសភាព ប្រធាន និងសមាជិកមួយរូប ឬសមាជិកទាំងអស់ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលដឹកនាំដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាប្រធានក្រុមវិនិច្ឆ័យ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចរៀបចំឱ្យមានជាសវនាការចល័ត ឬ អចល័ត :

- **<u>សវនាការចល័ត</u>**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចសំរេចឱ្យមានការធ្វើសវនាការចល័តតាមសំណូមពររបស់ភាគីវិវាទបាន ។ សវនាការចល័តត្រូវធ្វើឡើងនៅលើ ឬជិតទីតាំងដីទំនាស់ ឬកន្លែងណាមួយដែលភាគីវិវាទសំណូមពរ សវនាការចល័តអាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

-<u>សវនាការអចល័ត</u>

សវនាការអចល័តធ្វើឡើងដោយការសំរេចរបស់ប្រធានគណៈកម្មការថ្នាក់ជាតិ ឬ/និងតាមសំណូមពររបស់ភាគីវិវាទ ។ សវនាការអចល័តត្រូវធ្វើនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ សវនាការអចល័ត អាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបើកសវនាការរបស់ខ្លួន តាមរបៀបដូចខាងក្រោម:

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើសវនាការជាក្រុមវិនិច្ឆ័យ ឬ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិតែម្នាក់ ឬ មន្ត្រីសវនាការតែ១រូប ដែលតែងតាំងជាប្រធានសវនាការ ។

២-សវនាការត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ប្រធានសវនាការ ។ ប្រធានសវនាការអាចជាប្រធាន ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការ ដែលចាត់តាំងដោយប្រធានគណៈកម្មការសុរិ-យោដីថ្នាក់ជាតិ។

៣-ក្នុងពេលសវនាការ ប្រធានសវនាការ ត្រូវមានលេខាធិការសវនាការជាជំនួយការ ដែលជាមន្ត្រីលេខា-ធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

V.ដំណើរការនៃការរៀបចំសវនាការ

របៀបរៀបចំសវនាការត្រូវធ្វើតាមការណែនាំដូចខាងក្រោម :

ក-<u>លេខាធិការសវនាការ</u>

លេខាធិការសវនាការមានភារៈកិច្ចដូចតទៅ ÷

-ពិនិត្យ ឬស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងបណ្តឹង ឬតំណាង និងសាក្សី

-អានបទបញ្ជាផ្ទៃក្នុងនៃសវនាការ

-នាំភាគីវិវាទ និងសាក្សីទៅស្បថ

-ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលលេខាធិការសវនាការស្រែកថា "ប្រធានសវនាការ"

-រាយការណ៍ពី វត្តមាន អវត្តមាន អំពីភាគីវិវាទពាក់ព័ន្ធ ជូនប្រធានសវនាការ

-រាយការណ៍ដោយសង្ខេបនូវដំណើររឿងរបស់ករណីវិវាទ

-ត្រូវសរសេរ ឬកត់ត្រាកំណត់ហេតុសវនាការ ។ កំណត់ហេតុសវនាការត្រូវមានហត្ថលេខាអ្នកកត់ត្រា ភាគីវិវាទ និង សាក្សី ។

-អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការស្នើសុំពីប្រធានសវនាការ ។

ខ-<u>ប្រធានសវនាការ</u>

-ប្រធានសវនាការត្រូវអង្គុយតាមកន្លែងដែលបានរៀបចំទុក ។

-ប្រធានសវនាការអង្គុយចំកណ្តាល

-សមាជិកអង្គុយអមសងខាង

-លេខាធិការសវនាការត្រូវអង្គុយនៅតុផ្សេងដែលស្ថិតនៅខាងស្តាំដៃប្រធានសវនាការ

ក្រោយពីបានអង្គុយតាមកន្លែងកំណត់រួចមកប្រធានសវនាការត្រូវប្រកាសថា " យើងសូមបើកសវនាការ " រួចត្រូវបន្តសេចក្តីតាមលំដាប់ដូចតទៅ ÷

១-សវនាការនេះត្រូវបានធ្វើឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងមូល ឬដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ ដោយសមាជិកតែម្នាក់ ឬដោយមន្ត្រីសវនាការតែមួយរូប ដោយបង្ហាញអំពីឈ្មោះ និងឋានៈរបស់ប្រធានសវនាការ ឬ/និង សមាជិកសវនាការ ព្រមទាំងលេខាធិការសវនាការ លេខសំណុំរឿងករណីវិវាទ ឈ្មោះភាគីវិវាទ ទីតាំងដីវិវាទ និងកម្មវត្ថុនៃវិវាទ ។

ឧទាហរណ៍ : ថ្ងៃនេះគណៈកម្មការសុរិយោដីថ្នាក់ជាតិ បើកសវនាការជំនុំជំរះសំណុំរឿងលេខ ..... ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....ស្ថិតនៅភូមិ.....ឃុំ.....ស្រុក.....ខេត្ត..... រវាងដើមបណ្តឹងឈ្មោះ.....ឬតំណាងឈ្មោះ.....និងចុងបណ្តឹងឈ្មោះ.....ឬតំណាងឈ្មោះ..... ។

២-មូលហេតុនៃការរៀបចំសវនាការ (ដោយហេតុថាករណីវិវាទនេះបានធ្វើការសម្រុះសម្រួល ប៉ុន្តែភាគីវិវាទមិនអាចឈានដល់ការព្រមព្រៀងនៅគណៈកម្មការសុរិយោដីខេត្តក្រុង... ឬគណៈកម្មការរដ្ឋបាលក្នុងតំបន់វិនិច្ឆ័យនៃ ខេត្ត ក្រុងណាមួយ)។

៣-ប្រធានសួរទៅកាន់លេខាធិការសវនាការថា តើសេចក្តីជូនដំណឹងអំពីសវនាការត្រូវបានផ្តល់ឱ្យភាគីវិវាទទាំងអស់ត្រឹមត្រូវតាមនីតិវិធីដែរឬទេ ? បើសិនជាភាគីវិវាទណាមួយអវត្តមាន តើភាគីវិវាទនោះបានស្នើសុំឱ្យពន្យាពេលសវនាការដែរឬទេ ? បើសិនជាភាគីវិវាទមិនបានធ្វើការស្នើសុំទេ ប្រធានសវនាការអាចធ្វើការសំរេចថា តើត្រូវកំណត់ពេលសវនាការនៅលើកក្រោយ ឬ ធ្វើសវនាការនៅពេលនេះតែម្តង ។ សវនាការមិនអាចដំណើរការដោយអវត្តមានភាគីវិវាទណាមួយឡើយ លើកលែងតែការអវត្តមាននោះគ្មានមូលហេតុ ឬមានមូលហេតុមិនសមស្រប។

៤-ប្រធានត្រូវឱ្យភាគីវិវាទក្រោកឈរម្នាក់ម្តងៗដើម្បីបង្ហាញអំពីអត្តសញ្ញាណ ហើយត្រូវសួរទៅដើមបណ្តឹងថា (តើលោក ឬលោកស្រីនៅតែបន្តប្តឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្តឹងខាងលើ ឬមានការកែប្រែឬទេ ?) ប្រសិនបើដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានសវនាការត្រូវបន្តដំណើរការសវនាការ ។

៥-ប្រធានសួរទៅកាន់ភាគីវិវាទថា តើពួកគេមានអ្នកការពារក្តីដែរឬទេ ? បើមានប្រធានត្រូវឱ្យអ្នកការពារក្តីនោះក្រោកឈរឡើង ហើយបង្ហាញអំពីអត្តសញ្ញាណរបស់ខ្លួន។

៦-ប្រធានសួរទៅកាន់ភាគីវិវាទថាតើមានសាក្សីដែរឬទេ ? តើមានសាក្សីផ្សេងទៀតដែរឬទេ ? បន្ទាប់មកប្រធាន ត្រូវឱ្យសាក្សីទាំងអស់ក្រោកឈរឡើងដើម្បីបង្ហាញអំពីអត្តសញ្ញាណ ។

៧-ប្រធានសួរទៅលេខាធិការសវនាការថា តើសាក្សីទាំងអស់ដែលមានវត្តមាននេះបានធ្វើការស្បថស្បែរ ហើយឬនៅ ? បើមិនទាន់បានស្បថទេ លេខាធិការសវនាការត្រូវនាំសាក្សីទាំងនោះទៅស្បថ ។

៨-ប្រធានសួរទៅកាន់ភាគីវិវាទថាតើមានវត្ថុតាង ឬឯកសារ ដើម្បីផ្តល់ជាភស្តុតាងបន្ថែមផ្សេងទៀត ជូនសវនាការដែរឬទេ ? ប្រធានត្រូវឱ្យភាគីវិវាទបង្ហាញឯកសារ និងវត្ថុតាងទាំងនោះភ្លាមប្រសិនបើមាន ។ បើភស្តុតាងទាំងនោះទាក់ទងទៅនឹងករណីវិវាទពិតប្រាកដ ប្រធានត្រូវឱ្យលេខាធិការសវនាការថតចំលងជាបន្ទាន់ដើម្បីបញ្ចូលក្នុងសំណុំរឿងវិវាទ ។

៩-ប្រធានត្រូវប្រកាសប្រាប់ឱ្យសាក្សីទាំងអស់ថយទៅបន្ទប់រង់ចាំ ឬនៅកន្លែងណាមួយជិតនោះ ប៉ុន្តែមិនអាចស្តាប់ ឮការជជែកដេញដោលក្នុងសវនាការបានឡើយ ។

១០-ប្រធានបង្គាប់ឱ្យលេខាធិការសវនាការអានរបាយការណ៍សង្ខេបអំពីករណីវិវាទ ។ ខ្លឹមសាររបាយការណ៍មានជាអាទិ៍ ប្រវត្តិករណីដ៏ទំនាស់ ការរកឃើញរបស់អ្នកស៊ើបអង្កេត ជំហរ និងអកប្បកិរិយារបស់ភាគីវិវាទនៅពេលសម្រុះសម្រួល និង សេចក្តីសន្និដ្ឋានរបស់អ្នកសម្រុះសម្រួល ។

១១-ប្រធានបង្គាប់ជាបន្តបន្ទាប់ឱ្យភាគីដើមបណ្តឹង ឬតំណាង និងភាគីចុងបណ្តឹង ឬតំណាង បង្ហាញអំពីគំនិតនិងយោបល់លើករណីវិវាទ ។ ទន្ទឹមនោះប្រធាន ឬ/ និង សមាជិកអាចសួរភាគីវិវាទ ឬតំណាង ហើយភាគីវិវាទ ឬ តំណាងអាចតាំងសំណួរទៅភាគីវិវាទម្ខាងទៀត ឬតំណាងតាមរយៈប្រធានសវនាការ ។

១២-ប្រធាន និង/ឬ សមាជិក អាចសួរសាក្សីរបស់ភាគីដើមបណ្តឹង និង សាក្សីរបស់ភាគីចុងបណ្តឹងឱ្យបំភ្លឺនូវចំណុចមួយចំនួនដែលពាក់ពន្ធ ហើយភាគីវិវាទ ឬ តំណាង អាចតាំងសំណួរទៅសាក្សីរបស់ភាគីវិវាទម្ខាងទៀតតាមរយៈប្រធានសវនាការ ។

១៣-សាក្សីដែលឆ្លើយរួចហើយអាចអង្គុយក្នុងបន្ទប់សវនាការ ឬ អាចចាកចេញពីបន្ទប់សវនាការបាន ។

១៤-ប្រធានត្រូវសួរបញ្ជាក់ថាតើនៅមានសាក្សីណាដែលមិនទាន់ត្រូវបានអញ្ជើញមកបំភ្លឺដែរឬទេ ?

១៥-នៅពេលដែលភាគីវិវាទ ឬតំណាង និងសាក្សី បញ្ចប់សក្តីកម្ម ប្រធានបង្គាប់ឱ្យភាគីវិវាទ ឬតំណាងបង្ហាញអំពីជំហររបស់ភាគីវិវាទចំពោះករណីវិវាទ ។

១៦-ក្រោយពីបានដំណើរការតាមលំដាប់រួចហើយ ប្រធាន និងសមាជិក(ករណីសវនាការធ្វើជាក្រុម) ឬប្រធាន (ករណីសវនាការធ្វើឡើងដោយប្រធាន ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការតែម្នាក់) ត្រូវថយទៅពិចារណាករណី នោះនៅបន្ទប់ដែលបានរៀបចំដោយឡែក ។

១៧-ក្រោយពេលពិចារណាប្រធានត្រូវធ្វើការប្រកាសថា ÷

-សវនាការនឹងធ្វើការសំរេចលើករណីវិវាទនាពេលនេះតែម្តង ឬ

-សវនាការមិនអាចធ្វើការសំរេចលើករណីវិវាទ នាពេលនេះបានឡើយដោយហេតុថា ប្រធានសវនាការត្រូវការ ពេលវេលាបន្ថែមទៀតដើម្បីពិចារណា ។ សេចក្តីសំរេចនឹងត្រូវផ្ញើជូនភាគីវិវាទនៅពេលក្រោយ ។ ភាគីវិវាទ មានសិទ្ធិប្តឹងទៅតុលាការក្នុងករណីដែលពុំសុខចិត្តនឹងការសំរេច ឬ អាចស្នើសុំធ្វើសវនាការសារជាថ្មីនៅពេលដែលភាគីវិវាទមានភស្តុតាងថ្មីធំដុំដាក់ជូនមកគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងរយៈពេល

៣០ថ្ងៃ ចាប់ពីថ្ងៃដែលបានទទួលសេចក្តីសំរេចនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

១៨-ការធ្វើសវនាការឡើងវិញត្រូវអនុវត្តនីតិវិធីសវនាការដូចពេលមុនដែរ ។ ប្រសិនបើគណៈកម្មការសុរិយោដីថ្នាក់ជាតិបដិសេធចំពោះសំណើសុំឱ្យមានសវនាការឡើងវិញនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធនេះដល់ភាគីវិវាទ ។ នៅក្នុងករណីនេះ សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធ ត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាង នៃភាគីវិវាទ ជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹង ពីការបដិសេធចំពោះសំណើនោះ។

១៩-ប្រធានធ្វើការពន្យល់ឡើតថា នៅពេលដែលសេចក្តីសំរេចនោះចូលជាស្ថាពរហើយ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងផ្ញើសេចក្តីសំរេចនោះទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីចាត់ការតាមនីតិវិធីនៃការចុះបញ្ជីសុរិយោដី ។

២០-នៅចុងបញ្ចប់នៃសវនាការប្រធានត្រូវប្រកាសថា " បិទសវនាការ " ។

VI.របៀបនៃការធ្វើសេចក្តីសំរេច

១- សេចក្តីសំរេចទៅលើករណីវិវាទណាមួយរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវសំរេចដោយ ÷

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ ១ រូប

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ១រូប ហើយសេចក្តីសំរេចត្រូវធ្វើឡើងដោយសំឡេងជាឯកច្ឆន ។ ក្នុងករណីមិនឯកភាពគ្នា ប្រធានមានឧត្តមានុភាព ។

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ២រូប ហើយសេចក្តីសំរេចត្រូវធ្វើឡើងដោយសំឡេងភាគច្រើន ។ ក្នុងករណីមិនអាចរកសំឡេងភាគច្រើនបាន ប្រធានមានឧត្តមានុភាព ។

២-សេចក្តីសំរេចទាំងអស់ ត្រូវធ្វើតាមទំរង់បែបបទរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

VII.របៀបនៃការសំរេចក្នុងការធ្វើសវនាការឡើងវិញ

១-សំណើសុំឱ្យមានសវនាការឡើងវិញត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងកំលុងពេល ៣០ថ្ងៃ បន្ទាប់ពីភាគីវិវាទបានទទួលសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ សំណើសុំឱ្យមាន

សវនាការឡើងវិញត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់នូវព័តិមាន ភស្តុតាងថ្មីធំដុំ និងគំនូសតាងចាំបាច់នានា ។

២-ការធ្វើសវនាការឡើងវិញពុំអាចធ្វើបានទេលើកលែងតែមានសំឡេងយល់ព្រមពីសមាជិកទាំងអស់នៃគណៈ-កម្មការសុរិយោដីថ្នាក់ជាតិ នៅពេលដែលភស្តុតាងថ្មីធំដុំត្រូវបានដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៣-ការធ្វើសវនាការឡើងវិញត្រូវអនុលោមទៅតាមសេចក្តីជូនដំណឹង និងលក្ខខណ្ឌតំរូវផ្នែកនីតិវិធីដូចសវនាការដើមដែរ ។

៤-ក្នុងករណីបណ្តឹងសុំធ្វើសវនាការឡើងវិញត្រូវបានបដិសេធ នោះគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវជូនដំណឹងដល់ភាគីវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការបដិសេធនេះ។ នៅក្នុងករណីនេះ សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងក្លាយជាស្ថាពរក្រោយបញ្ចប់រយៈពេល៣០ថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងពីការបដិសេធត្រូវបានបញ្ជូនដល់ភាគីវិវាទ លើកលែងតែភាគីម្ខាងនៃភាគីវិវាទជូនដំណឹងអំពីការប្តឹងជំទាស់ទៅតុលាការក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីការបដិសេធចំពោះសំណើនោះ ។

VIII.**បណ្តឹងជំទាស់ទៅតុលាការ**

១-ភាគីវិវាទណាក៏ដោយអាចប្តឹងទៅតុលាការដោយរួមគ្នា ឬជាបុគ្គលអំពីសេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ បណ្តឹងជំទាស់ត្រូវដាក់ជូនទៅតុលាការ ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីសេចក្តីសំរេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ ។ ភាគីវិវាទណាមួយដែលធ្វើបណ្តឹងទៅតុលាការត្រូវដាក់តំកល់ឯកសារថតចំលងមួយច្បាប់ នៃបណ្តឹងជំទាស់នៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីភាគីនោះបានទទួលសេចក្តីសំរេចពីគណៈ-កម្មការសុរិយោដីថ្នាក់ជាតិ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវធ្វើសេចក្តីបញ្ជាក់ជាបន្ទាន់នូវរបាយការណ៍ផ្លូវការដើម្បីបញ្ជូនទៅតុលាការ ។

៣-ក្នុងករណី តុលាការបញ្ជូនករណីវិវាទមកគណៈកម្មការសុរិយោដីថ្នាក់ជាតិវិញដោយហេតុថា គណៈកម្មការសុរិយោដី មិនបានអនុវត្តតាមនីតិវិធីសមស្រប ឬដោយមានវិវាទផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលសមរម្យ ឬ ដោយអនុវត្តហួសពីសមត្ថកិច្ចរបស់ខ្លួន នោះគណៈកម្មការសុរិយោដីត្រូវចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ ។

IX. បទបញ្ជាផ្ទៃក្នុងពេលសវនាការ

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខ ក្នុងបន្ទប់សវនាការ ជនគ្រប់រូប ដែលមានវត្តមាន ក្នុងបន្ទប់សវនាការត្រូវគោរព និងអនុវត្តបទបញ្ជាដូចតទៅ ÷

១-ហាមជក់បារីក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេច

២-ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់សវនាការ ឬកន្លែងប្រជុំសម្រេចដូចជា

-ការដើរឆ្លងកាត់ ឬដើរចេញ-ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត

-ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ មាន សម្លេងទូរស័ព្ទ ឬសម្លេង ឧបករណ៍ផ្សេងៗជាដើម ។

៣-ហាមយកក្មេងអាយុក្រោម ១៨ ឆ្នាំ ចូលក្នុងបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីប្រធានសវនាការ ។

៤-ហាមយកអាវុធគ្រប់ប្រភេទ ជាតិផ្ទុះ សារធាតុពុល និងវត្ថុបង្កគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងបន្ទប់ សវនាការ ។

៥-ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានសវនាការ ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

X. នីតិវិធី និងខ្លឹមសារនៃសម្បថ

ភាគី និងសាក្សីត្រូវធ្វើសម្បថ និងឆ្លើយបំភ្លឺជូនប្រធានសវនាការ ។ ក្នុងករណីភាគី និងសាក្សីឆ្លើយកុហក ឬបំផ្លើសពីការពិតនឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។

នីតិវិធីនៃការធ្វើសម្បថ និងខ្លឹមសារ នៃសម្បថមានដូចខាង ក្រោម ÷

<u>១-នីតិវិធីនៃសម្បថ</u>

សម្បថត្រូវធ្វើឡើងដូចខាងក្រោម ÷

-សម្បថរបស់ភាគី និងសាក្សីត្រូវធ្វើមុនពេលសាកសួរ ឬការឆ្លើយបំភ្លឺ ។

-មុនពេលធ្វើសម្បថ លេខាធិការសវនាការត្រូវពន្យល់អំពីគោលបំណងនៃសម្បថ និងប្រាប់ឱ្យដឹងជាមុន អំពីទុក្ខទោស នៃការក្លែងបន្លំពាក្យសម្បថ ។

-នៅពេលធ្វើសម្បថ ភាគី និងសាក្សីត្រូវក្រោកឈរឡើងហើយត្រូវធ្វើការស្មិងស្មាធ៍

-លេខាធិការសវនាការត្រូវឱ្យភាគី និងសាក្សី អានលិខិតសម្បថ ហើយត្រូវឱ្យចុះហត្ថលេខាលើលិខិតនោះផង។ នៅពេលដែលភាគី និងសាក្សីមិនអាចអានលិខិតសម្បថបានទេ លេខាធិការសវនាការត្រូវអានសម្បថនោះរួចឱ្យភាគី និងសាក្សីថាតាម បន្ទាប់មកឱ្យភាគី និងសាក្សីផ្តិតមេដៃលើលិខិតសម្បថនេះ ។

<u>២-ខ្លឹមសារនៃពាក្យសម្បថ</u>

ពាក្យសម្បថត្រូវមានខ្លឹមសារដូចខាងក្រោម :

សម្បថ

យើងទាំងអស់គ្នា សូមស្បថចំពោះមុខព្រះអង្គដងកើ លោកយាយទេពដងកើ ទេព្តាថៃរក្សាព្រះមហាស្វេតច្ឆត្រ លោកមេទ័ពសេះសរក្សាក្នុងរាជវាំង ព្រះអង្គវិហារសូគ្រ ព្រះអង្គគោកធ្លក ព្រះនាងចេក ព្រះនាងចម សូមលោកអញ្ជើញលោកតាព្រះចៅ លោកតាដំបងក្រញូង លោកតាក្រហមក លោកតាក្បាលប្រាំបីរក្សាក្បាលជ្រោយ បើយើងខ្ញុំសច្ចានេះមិនស្មោះត្រង់ មានចិត្តវៀចវេរ សូមឱ្យព្រះអង្គដាក់ទោសតាមពាក្យសម្បថដូចខាងក្រោមនេះ

-បើយើងខ្ញុំនៅផ្ទះឱ្យធ្លាក់ពីលើផ្ទះ ឬរអិលដួលស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំជិះទូកកប៉ាល់សូមឱ្យធ្លាក់ទឹកលង់ស្លាប់ប្រាំបីរយជាតិ បើយើងខ្ញុំស្លាប់ទៅជាខ្មោចសូមឱ្យស៊ីខ្ទុះឈាម ឬ បែលនៅក្នុង ខ្ទះភ្លើងប្រាំបីរយជាតិ បើកើតមកជាមនុស្ស សូមឱ្យជួបតែក្រខ្វះខាតគ្រប់ប្រាំបីរយជាតិ និងសូមឱ្យបារមីគ្រប់ព្រះអង្គបរាមុខ និងវាយបំបាក់កគ្រប់ប្រាំបីរយជាតិ ។

-បើយើងខ្ញុំមានការទៀងត្រង់ សូមវត្ថុសក្តិសិទ្ធិគ្រប់ទិសទី និងទេព្តារក្សាទិសទាំងប្រាំបី ជួយឱ្យយើងខ្ញុំទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ បើខ្ញុំស្លាប់ពីជាតិនេះ អន្ទោលទៅកើតក្នុងភពធំ ឬភពតូចណាក្តីសូមបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានបញ្ញាស្មារតីឆ្លាតវៃ កុំឱ្យស្គាល់សេចក្តីក្រលំបាក ជម្ងឺដង្កាត់ជារៀងរាល់ជាតិ រហូតដល់បានសម្រេចព្រះនិព្វានជាឋានបរមសុខនោះហោង ។

យើងខ្ញុំសូមស្បថថា និងបរិយាយការពិតដោយយោលទៅតាមមនសិការ មិនលាក់រឿងអ្វីទាំងអស់ និងមិនបន្ថែមបន្ថយរឿងអ្វីឡើយ ។

ដោយករណីនេះ ជានីតិវិធីថ្មីដំបូងពុំធ្លាប់បានអនុវត្តកន្លងមកនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើការកែសំរួលក្នុងពេលកំពុងអនុវត្ត ឬ អាចអនុវត្តដោយពុំតម្រូវតាមនីតិវិធីមួយចំនួនជាបណ្តោះអាសន្ននិងជំនួសដោយនីតិវិធីដែលពុំមានចែង តែជាការចាំបាច់ដើម្បីច្បៀសវាងការកកស្ទះការងារ។ សេចក្តីណែនាំនេះអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ SV SP

អ៊ឹម ឈុនលឹម

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន
-គ្រប់សាលាខេត្តក្រុង
-គ្រប់គណៈកម្មការសុរិយោដីខេត្ត ក្រុង
-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
-មន្ទីរជំនាសស.ខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៥ សណន

សេចក្តីណែនាំរួម
ស្តីពី
ការអនុវត្តន៍អនុក្រឹត្យលេខ ៣៤អនក្រ.បក
ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦

ក្នុងគោលបំណងរួមជំរុញការងាររបស់គណៈកម្មការសុរិយោដីគ្រប់ថ្នាក់សំដៅកាត់បន្ថយ និងដោះស្រាយបញ្ហាប៉ះទំនាស់ដីធ្លី ពិសេសនៅថ្នាក់ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃនិងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្វើការណែនាំដល់អាជ្ញាធរដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ក្នុងការអនុវត្តអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦ ដូចខាងក្រោម :

១-អភិបាលស្រុក ខណ្ឌក្នុងមុខតំណែង ត្រូវទទួលភារកិច្ចជាប្រធានគណៈកម្មការសុរិយោដី ស្រុក ខណ្ឌ ក្នុងវង់សមត្ថកិច្ចរបស់ខ្លួន ។ ចំពោះស្រុក ខណ្ឌដែលពុំទាន់តែងតាំងអភិបាល អភិបាលរងដែលទទួលបន្ទុកជីកនាំការងាររួម មានភារកិច្ចជីកនាំគណៈកម្មការសុរិយោដីស្រុក ខណ្ឌនោះ ។ អភិបាលស្រុក ខណ្ឌ ដែលជាប់បេសកកម្មក្រៅប្រទេស ឬអវត្តមានរយៈពេលយូរ ត្រូវផ្ទេរសិទ្ធិជូនអភិបាលរង ០១ រូប ទទួលបន្ទុកជីកនាំបន្តគណៈកម្មការសុរិយោដី ស្រុក ខណ្ឌនោះ ។ អភិបាលរងស្រុក ខណ្ឌដែលបានទទួលសិទ្ធិជីកនាំការងារនេះ ត្រូវរាយការណ៍អំពីលទ្ធផលការងារជូនប្រធានគណៈកម្មការសុរិយោដីស្រុក ខណ្ឌ ពេលមានវត្តមាននៅអង្គភាពវិញ ។

២-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌក្នុងមុខតំណែង ត្រូវទទួលភារកិច្ចជាអនុប្រធានគណៈកម្មការសុរិយោដី ស្រុក ខណ្ឌ ។ ចំពោះការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដែលពុំទាន់មានប្រធានការិយាល័យ ប្រធានគណៈកម្មការសុរិយោដីស្រុក ខ័ណ្ឌត្រូវលើកសំណើជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិក្នុងការតែងតាំងបណ្តោះអាសន្នអនុប្រធានគណៈកម្មការសុរិយោដីស្រុក ខណ្ឌនោះ ។

៣- គណៈកម្មការសុរិយោដីស្រុក ខណ្ឌ ត្រូវសិក្សាស្រាវជ្រាវស្វែងយល់ច្បាប់ និងបទដ្ឋានគតិយុត្ត នានាក្នុងការអនុវត្តន៍អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ប្រកាសលេខ១១២ ដនស.ប្រក.ចុះថ្ងៃទី ២១ខែ សីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំនីតិវិធីរបស់គណៈកម្មការសុរិយោដី និងប្រកាសរួមលេខ ០២ ប្រករ/០៣ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធ នឹងរឿងវិវាទដីធ្លី ។

អាជ្ញាធរដែនដី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ឆ្នាំ សុខា

ឧស្សរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលឹម

ចម្លងជូន :

-ក្រសួងព្រះបរមរាជវាំង
-ទីស្តីគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត ក្រុង
-គ្រប់មន្ទីរ ដនសស.ខេត្ត ក្រុង
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
គណៈកម្មការសុរិយោដីថ្នាក់ជាតិ
លេខ : ១៤៧ ដនស/គសជ

សេចក្តីកំណត់
ស្តីពី
របៀបរបបកិច្ចប្រជុំ និង ការពិនិត្យសម្រេច
លើសំណុំរឿងវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

*** ● ***

ដើម្បីបំពេញការកិច្ចក្នុងការពិនិត្យលើសំណុំរឿងវិវាទដីធ្លីឱ្យកាន់តែមានប្រសិទ្ធភាព មានគណនេយ្យភាព និងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤ គណៈកម្មការសុរិយោដីថ្នាក់ជាតិសូមធ្វើការកំណត់នីតិវិធីនៃការចាត់ចែងការងាររបស់លេខាធិការដ្ឋាន នៅពេលបានទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដី ឬពីគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម :

១-ការសិក្សាលើសំណុំរឿងវិវាទ ដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ :

ក្រោយពីបានទទួលសំណុំរឿងវិវាទពីគណៈកម្មការសុរិយោដី ឬពីគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវពិនិត្យ សិក្សា និងលើកយោបល់ជូនទៅប្រធានគណៈកម្មការផ្តាល់ដូចតទៅ :

ក-សំណុំរឿងបញ្ជូនមកពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត

សំណុំរឿងដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោមជាតិ អនុវត្តពុំបានត្រឹមត្រូវតាមនីតិវិធី លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវលើកយោបល់ស្នើសុំបញ្ជូនសំណុំរឿងត្រឡប់ទៅគណៈកម្មការសុរិយោដីសាបិញ្ជ ដើម្បីឱ្យអនុវត្តត្រឹមត្រូវតាមនីតិវិធី ។

-សំណុំរឿងដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោមជាតិ ស៊ើបអង្កេតមិនបានពេញលេញ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចលើកយោបល់ស្នើសុំចុះធ្វើការស៊ើបអង្កេតផ្តាល់ ឬអាចស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ក្រោមជាតិស៊ើបអង្កេតបន្ថែមលើចំណុចជាក់លាក់ណាមួយដែលលេខាធិការដ្ឋានយល់ថាចាំបាច់ ។

-សំណុំរឿងដែលអាចមានលទ្ធភាពសម្រុះសម្រួលបាន អាចលើកយោបល់ស្នើសុំចុះធ្វើការសម្រុះសម្រួលបន្ថែម ។

-សំណុំរឿងដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ឬបណ្តឹងដូចបានកំណត់ក្នុងប្រការ ១៩ នៃប្រកាសលេខ ១១២ ដនស/ប្រក. ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ត្រូវលើកយោបល់ស្នើសុំច្រានចោល ឬតម្កល់សំណុំរឿងទុកមិនចាត់ការ ។

ខ-សំណុំរឿងបញ្ជូនមកពីគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត

-សំណុំរឿងដែលគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត អនុវត្តពុំបានត្រប់ត្រាន់តាមនីតិវិធី ដូចជាគ្មានពាក្យបណ្តឹង

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ ចឹងត្រពែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

ឬពាក្យបណ្តឹងមិនច្បាស់លាស់ ឬគ្មានការស៊ើបអង្កេត ឬគ្មានការសម្រុះសម្រួល លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវលើកយោបល់ស្នើសុំបញ្ជូនសំណុំរឿងទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តវិញ ដើម្បីធ្វើការស៊ើបអង្កេត សម្រុះសម្រួល ក្នុងនាមគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចបានកំណត់ក្នុងលិខិតលេខ ៦៣៤ ដនស/គសជ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៧។

-សំណុំរឿងដែលគណៈកម្មការរដ្ឋបាលរាជធានី ខេត្តបញ្ជូនមក ហើយអាចមានលទ្ធភាពសម្រុះសម្រួលបានត្រូវលើកយោបល់ស្នើសុំចុះធ្វើការសម្រុះសម្រួលបន្ថែម។

-សំណុំរឿងដែលគណៈកម្មការរដ្ឋបាលរាជធានី ខេត្តបញ្ជូនមក មិនស្ថិតក្នុងសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីឬបណ្តឹងដូចបានកំណត់ក្នុងប្រការ ១៩ នៃប្រកាសលេខ ១១២ ដនស/ប្រក. ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវលើកយោបល់ស្នើសុំ ច្រានចោល ឬតម្កល់សំណុំរឿងទុកមិនចាត់ការ។

<u>២-របៀបនៃការពិនិត្យ និងផ្តល់យោបល់លើសំណុំរឿងវិវាទ</u> :

រាល់សំណុំរឿងវិវាទដែលលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យឃើញថា បានអនុវត្តត្រឹមត្រូវតាមនីតិវិធី ការស៊ើបអង្កេតមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងពុំអាចសម្រុះសម្រួលបន្ថែមទៀតបាន លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើរបាយការណ៍អំពីសំណុំរឿងវិវាទ ដោយធ្វើការសន្និដ្ឋានអង្គហេតុ អង្គច្បាប់ និងលើកយោបល់ជូនសមាជិក និងប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីពិនិត្យ និងផ្តល់មតិណែនាំតាមពីររបៀបគឺ :

-ការពិនិត្យ និងផ្តល់យោបល់ជាក់លាក់ ដោយមិនចាំបាច់បើកកិច្ចប្រជុំ

-ការពិនិត្យ និងផ្តល់យោបល់ ដោយមានសំណើឱ្យបើកកិច្ចប្រជុំ

ក- ការពិនិត្យ និងផ្តល់យោបល់ជាក់លាក់ ដោយមិនចាំបាច់បើកកិច្ចប្រជុំ:

ការពិនិត្យ និងផ្តល់យោបល់ជាក់លាក់ដោយមិនចាំបាច់បើកកិច្ចប្រជុំរួមរវាងប្រធាន និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាការពិនិត្យ និងផ្តល់យោបល់ជាក់លាក់តាមរយៈចំណារឯកភាព ឬមិនឯកភាព ឬយោបល់បន្ថែមលើយោបល់របស់លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិដែលបានស្នើឡើង។ ការផ្តល់យោបល់បែបនេះ អនុវត្តតែចំពោះសំណុំរឿងដែលមានទ្រង់ទ្រាយតូច ដូចជាដីទំនាស់មានទំហំតូច ទំនាស់ព្រំប្រទល់ដី ទំនាស់មិនមានភាពស្មុគស្មាញ ឬមិនជាប់ពាក់ព័ន្ធនឹងភាគីច្រើននាក់...។ ក្នុងករណីនេះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវដាក់របាយការណ៍សំណុំរឿងវិវាទជូនគ្រប់សមាជិក និងប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ការពិនិត្យ និងផ្តល់យោបល់របស់សមាជិកនីមួយៗ ត្រូវមានរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលរបាយការណ៍សំណុំរឿងវិវាទ។ ក្រោយទទួលបានយោបល់ពីសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ លេខាធិការដ្ឋានត្រូវសង្ខេបមតិយោបល់ជូនប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីពិនិត្យសម្រេច។

ករណីគ្មានចំណារតបលើរបាយការណ៍សំណុំរឿងវិវាទដែលបានដាក់ជូនក្នុងរយៈពេលកំណត់ខាងលើ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវស្នើសុំយោបល់ជាលើកទី២ ដោយបន្តរយៈពេល ៥ថ្ងៃថែមទៀត។ ផុតរយៈពេលកំណត់លើកទី២នេះ ត្រូវសន្មតថាសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិនោះបានឯកភាពតាមយោបល់របស់លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

ខ-ការពិនិត្យ និងផ្តល់យោបល់ ដោយមានសំណើឱ្យបើកកិច្ចប្រជុំ :

ការពិនិត្យ និងផ្តល់យោបល់ដោយមានសំណើឱ្យបើកកិច្ចប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមការអញ្ជើញ របស់ប្រធាន ត្រូវអនុវត្តចំពោះសំណុំរឿងវិវាទណាដែលមានទ្រង់ទ្រាយធំ ស្រូចស្រាល់ ស្មុគ្រស្មាញ ពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ច្រើនគ្រួសារ និង/ឬសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការរំលោភបំពានយកដីរដ្ឋ ឬវិវាទដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងធន់ធ្ងរដល់ផលប្រយោជន៍នៃភាគីម្ខាងទៀត...។ របាយការណ៍សំណុំរឿងវិវាទដែលត្រូវដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំត្រូវផ្ញើជូនប្រធាន និងសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ព្រមទាំងសមាសភាពពាក់ព័ន្ធផ្សេងទៀត ដែលត្រូវចូលរួមប្រជុំឱ្យបានយ៉ាងតិច ៥ (ប្រាំ) ថ្ងៃ មុនបើកការប្រជុំ ។

ការពិនិត្យ និងផ្តល់យោបល់ជាក់លាក់ដោយមិនចាំបាច់បើកកិច្ចប្រជុំ ឬការពិនិត្យ និងផ្តល់យោបល់ដោយមានសំណើឱ្យបើកកិច្ចប្រជុំ ជាកិច្ចការផ្ទៃក្នុងរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្នុងការពិនិត្យ ផ្តល់យោបល់លើសំណុំរឿងវិវាទ និងដើម្បីចាត់តាំងមន្ត្រីវិនិច្ឆ័យ ឬមន្ត្រីសវនាការ ។ ចំពោះនីតិវិធីបន្តសំរាប់រៀបចំបើកសវនាការ ត្រូវអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងសេចក្តីណែនាំលេខ ១៤៥៥ ដនស/គសជ ចុះថ្ងៃ ទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៥ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៣-អំពីរបបប្រជុំ

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវរៀបចំកិច្ចប្រជុំរៀងរាល់ ៣ (បី)ខែម្តង ។ ក្នុងកិច្ចប្រជុំនេះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវរាយការណ៍អំពីសភាពការណ៍ទូទៅពាក់ព័ន្ធនឹងវិវាទដីធ្លី លទ្ធផលនៃការដោះស្រាយវិវាទដីធ្លី បញ្ហាប្រឈមផ្សេងៗ និងលើកអនុសាសន៍ជូនគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ក្នុងការបំពេញការងារឱ្យបានកាន់តែល្អប្រសើរ ។

លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវទទួលខុសត្រូវក្នុងការរៀបចំរាល់កិច្ចប្រជុំគណៈកម្មការសុរិយោដីថ្នាក់ជាតិ លើខ្លឹមសារ ពេលវេលា ទីកន្លែង និងសមាសភាពពាក់ព័ន្ធដែលត្រូវចូលរួម ។

ប្រធាន និងសមាជិកនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តតាមសេចក្តីកំណត់នេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើជានិរ្ជំពេញ ថ្ងៃទី ២៦ ខែ ឧសា ឆ្នាំ ២០០៥

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលឹម

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត
-គណៈកម្មការរដ្ឋបាលរាជធានី ខេត្ត
" ដើម្បីជូនជ្រាប "
-លេខាធិការដ្ឋាន គណៈកម្មការសុរិយោដីថ្នាក់ជាតិ
ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
គណៈកម្មការសុរិយោដីថ្នាក់ជាតិ
លេខ : ០១ ដនស/សរណន

សារាចរណែនាំ
ស្តីពី
ការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លី
របស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងយន្តការគណៈកម្មការសុរិយោដី

អនុលោមតាមលិខិតលេខ ១៦៧៤សជណ.ឧស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងប្រកាសលេខ ០៣២ប្រក.ដនស/គសជ. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១០ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការធ្វើប្រតិភូកម្មមុខងារជូនដល់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី។ គណៈកម្មការសុរិយោដីថ្នាក់ជាតិសូមធ្វើការណែនាំអំពីការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេចដូចតទៅ :

១-បន្ទាប់ពីបានទទួលសំណុំរឿងវិវាទដីធ្លីដែលដោះស្រាយដោយការសម្រុះសម្រួលមិនបានជោគជ័យនៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ក៏ដូចជាសំណុំរឿងវិវាទដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និងសំណុំរឿងវិវាទបញ្ជូនពីគណៈកម្មការសុរិយោដីថ្នាក់ជាតិរួចមក គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវពិនិត្យសំណុំរឿងវិវាទទាំងមូលដើម្បីឱ្យច្បាស់ថា តើគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ បានអនុវត្តត្រឹមត្រូវពេញលេញតាមនីតិវិធីហើយឬនៅ? ក្នុងករណីគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ អនុវត្តពុំត្រឹមត្រូវតាមនីតិវិធីទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យអនុវត្តនីតិវិធីឡើងវិញ។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ ចឹងត្រពែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ

ចំពោះសំណុំរឿងវិវាទដែលស៊ើបអង្កេតមិនបានពេញលេញ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវចាត់មន្ត្រីលេខាធិការដ្ឋានចុះស៊ើបអង្កេតបន្ថែមឱ្យបានពេញលេញ។

២-ចំពោះសំណុំរឿងវិវាទដែលបានអនុវត្តត្រឹមត្រូវតាមនីតិវិធីរួចហើយ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវព្យាយាមអញ្ជើញភាគីវិវាទឱ្យចូលរួមធ្វើការសម្រុះសម្រួលយ៉ាងតិច ៣ (បី)លើក ឬអាចលើសពីនេះតាមការយល់ឃើញរបស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ក្នុងគោលបំណងបញ្ចប់វិវាទជាឯកច្ឆន្ទនៅក្នុងសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត និងស្របតាមនីតិវិធីដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ៤៧អនក្រ.បក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ និង ប្រកាសលេខ ១១២ដនស.ប្រក. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២។

៣-ប្រសិនបើភាគីវិវាទទាំងអស់ពុំព្រមព្រៀងគ្នាបញ្ចប់វិវាទជាឯកច្ឆន្ទតាមការសម្រុះសម្រួលដូចបានចែងខាងលើទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវបើកកិច្ចប្រជុំដើម្បីធ្វើសេចក្តីសម្រេចចំពោះសំណុំរឿងវិវាទ ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេត និងសេចក្តីសន្និដ្ឋានរបស់លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ។

៤-សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើជាលាយល័ក្ខអក្សរ និងត្រូវមានសេចក្តីសង្ខេបអំពីករណីវិវាទ និងហេតុផលលំអិតនៃការធ្វើសេចក្តីសម្រេចទទួលស្គាល់ភោគីត្រឹមត្រូវតាមច្បាប់ (ឧបសម្ព័ន្ធទី២៣) ។ លេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវធ្វើសេចក្តីប្រកាស និងប្រគល់សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ជូនដល់ភាគីវិវាទ ។

៥-ករណីភាគីវិវាទមិនសុខចិត្តចំពោះការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ភាគីមានសិទ្ធិស្នើសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិ បើកសវនាការសម្រេចលើករណីវិវាទនោះឡើងវិញក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃដែលបានទទួលសេចក្តីសម្រេច ឬថ្ងៃដែលបានជូនដំណឹងអំពីសេចក្តីសម្រេចនោះ។ ភាគីដែលស្នើសុំឱ្យបើកសវនាការសម្រេចឡើងវិញត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដាក់ទៅលេខាធិការគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដែលបានចេញសេចក្តីសម្រេចនោះ (ឧបសម្ព័ន្ធទី២៤) ។

៦-បន្ទាប់ពីបានទទួលសំណើសុំឱ្យបើកសវនាការសម្រេចឡើងវិញរួចហើយ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវរៀបចំបញ្ជូនសំណើ និងភ្ជាប់ជាមួយនូវសំណុំរឿងវិវាទទៅគណៈកម្មការ

សុរិយោដីថ្នាក់ជាតិ យ៉ាងយូរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃទទួលបានសំណើនេះ។ ប្រសិនបើគ្មានការស្នើសុំឱ្យបើកសវនាការសម្រេចឡើងវិញក្នុងរយៈពេលកំណត់ខាងលើនេះ សេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ត្រូវចាត់ទុកជាសេចក្តីសម្រេចស្ថាពរ។

៧-ទទួលបានសារាចរណែនាំនេះ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត មានភារកិច្ចចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលិម

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងយុត្តិធម៌
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គណៈកម្មការសុរិយោដីរាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ ៖ ..១៧..... ជនស\គសជ

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែ ឆ្នូ ឆ្នាំ ២០១០

សេចក្តីណែនាំបន្ថែម
ស្តីពី
ការអនុវត្តប្រកាសលេខ ១១២ ជនស/ប្រក ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី

បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ជាតិរួមជាមួយនឹងដៃគូអភិវឌ្ឍន៍គឺ អង្គការ GTZ ប្រចាំក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើការសិក្សាវាយតម្លៃលើការងារដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីកន្លងមកឃើញថា មានចំណុចខ្វះខាតមួយចំនួនក្នុងនីតិវិធីនៃការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការសុរិយោដីនៅឡើយ ហើយការខ្វះខាតនេះគណៈកម្មការសុរិយោដីថ្នាក់ជាតិកំពុងសិក្សាដើម្បីបំពេញបន្ថែមជាបន្តបន្ទាប់។

ចំពោះមុខ ក្នុងគោលបំណងសម្រួលដល់ការអនុវត្តនីតិវិធីឲ្យកាន់តែមានប្រសិទ្ធភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិសូមណែនាំដូចខាងក្រោម ៖

១-ករណីវិវាទពហុភាគី

-កម្មវត្ថុនៃបណ្តឹងទាមទារដីធ្លីធ្វើឡើងដើម្បីបំរើផលប្រយោជន៍សាធារណៈ ដែលករណីនេះភាគីវិវាទមានសិទ្ធិអាចជ្រើសរើសក្នុងចំណោមភាគីពាក់ព័ន្ធនឹងវិវាទនូវតំណាងផ្ទេរសិទ្ធិម្នាក់ ឬច្រើននាក ដើម្បីដាក់ពាក្យបណ្តឹង និងដំណើរការដោះស្រាយតាមនីតិវិធីរបស់គណៈកម្មការសុរិយោដី។

-កម្មវត្ថុនៃបណ្តឹងទាមទារដីធ្លីធ្វើឡើងដើម្បីបំរើផលប្រយោជន៍ឯកជនម្នាក់ៗ ករណីនេះភាគីវិវាទនីមួយៗត្រូវដាក់ពាក្យបណ្តឹងដោយផ្ទាល់ ដូចនីតិវិធីរបស់គណៈកម្មការសុរិយោដីដែលបានអនុវត្តកន្លងមក។

២-កំណត់រយៈពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីជូនដំណឹង ឬទម្រង់បែបបទច្រានចោលពាក្យបណ្តឹង ភាគីវិវាទមានសិទ្ធិប្តឹងជំទាស់នឹងការច្រានចោលនោះ។

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel : (855) 023 215 659-215 660 , Fax : (855) 023 215 277 , e-mail : im. c . lim. @ Camnet. Com. Kh

៣-ត្រូវពង្រឹងបន្ថែមទៀត ការជូនដំណឹងដល់ភាគីវិវាទនូវសិទ្ធិក្នុងការជ្រើសរើសជំនួយការភាគី ជាពិសេសត្រូវសហការជិតស្និទ្ធជាមួយសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តការងារនេះឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

៤-ត្រូវពង្រឹងបន្ថែមទៀតនូវការស៊ើបអង្កេត និង ការធ្វើសេចក្តីសន្និដ្ឋានលើសំណុំរឿងវិវាទនីមួយៗឲ្យបានច្បាស់លាស់មុននឹងសម្រេចធ្វើការច្រានចោល។ ពិសេសជាងនេះទៅទៀត បន្ទាប់ពីការច្រានចោលករណីបណ្តឹងណាមួយរួចហើយ គណៈកម្មការសុរិយោដីគ្រប់ថ្នាក់ត្រូវតែច្បាស់លាស់ថា ការសម្រេចច្រានចោលបណ្តឹងនោះត្រូវបានជូនដំណឹងឬបានប្រគល់ទម្រង់បែបបទច្រានចោលបណ្តឹងដោយផ្ទាល់ដល់គូភាគីវិវាទផងដែរ ។ រាល់ការជូនដំណឹង ឬ ការប្រគល់ ទទួលទម្រង់បែបបទច្រានចោលត្រូវមានឯកសារបញ្ជាក់ ដើម្បីតម្កល់ទុកក្នុងសំណុំរឿងផ្លូវការ ។

នាយកខុទ្ទកាល័យ ប្រធានគណៈកម្មការសុរិយោដីគ្រប់ថ្នាក់ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន ប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និង ប្រធានការិយាល័យវៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តសេចក្តីណែនាំបន្ថែមនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ



អ៊ឹម ឈុនលីម

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ
លេខ ០៤៩ ជនស/គសជ

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ក្ដ ឆ្នាំ២០១២

សេចក្តីណែនាំ
ស្តីពី
ការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាល និងគណៈកម្មការសុរិយោដី ពាក់ព័ន្ធនឹងវិវាទដីធ្លី ក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ

ដើម្បីអនុវត្តអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងការដោះស្រាយវិវាទដីធ្លី ដែលស្ថិតក្នុងសមត្ថកិច្ច របស់គណៈកម្មការរដ្ឋបាល និងគណៈកម្មការសុរិយោដី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិសូមធ្វើការណែនាំបន្ថែមអំពីការអនុវត្តនីតិវិធីក្នុងការដោះស្រាយវិវាទដីធ្លីដូចខាងក្រោម៖

១.ការពង្រឹងការអនុវត្តនីតិវិធីដោះស្រាយវិវាទរបស់គណៈកម្មការរដ្ឋបាល

១.១.គណៈកម្មការរដ្ឋបាលរាជធានី ខេត្ត ត្រូវកំណត់ឲ្យបានច្បាស់នូវតួនាទី និងភារកិច្ចរបស់មន្ត្រីទទួលខុសត្រូវក្នុងការដោះស្រាយវិវាទក្នុងតំបន់វិនិច្ឆ័យនីមួយៗ។

១.២.ការដោះស្រាយករណីវិវាទដីធ្លីនីមួយៗ ត្រូវមានការចូលរួមពីសមាជិកគណៈកម្មការរដ្ឋបាលនៅតាមតំបន់វិនិច្ឆ័យនីមួយៗ និងត្រូវចៀសវាង ការប្រគល់តួនាទីដោះស្រាយ ឬការសម្រេចច្រានចោល ឬការសម្រេចបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដី ជូនប្រធានក្រុមបច្ចេកទេស ឬមន្ត្រីប្រចាំការក្នុងអំឡុងពេលបិទផ្សាយ។

១.៣.គ្រប់សំណុំរឿងវិវាទទាំងអស់ ត្រូវកសាងឯកសារឲ្យបានត្រឹមត្រូវ ចៀសវាងព័ត៌មាន ឬឯកសារដែលទទួលបានមិនអាចយកជាការបាន។ ពិសេសគ្រប់ករណីវិវាទត្រូវព្យាយាមដោះស្រាយយ៉ាងតិចបំផុតឲ្យបានមួយដង មុននឹងគណៈកម្មការរដ្ឋបាលសម្រេចចាត់ការតាមមធ្យោបាយផ្សេងទៀត។

២.នីតិវិធីនៃការទទួល ស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹង

២.១.ក្នុងពេលអនុវត្តនីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ បុគ្គលទាំងឡាយដែលមានការជំទាស់អំពីការចុះបញ្ជីលើក្បាលដីណាមួយ អាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ចឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel: (855) 23 215 659-215 660, Fax: (855) 23 215 277, E-mail: im.c.lim.@camnet.com.kh

ទៅគណៈកម្មការរដ្ឋបាលនៃតំបន់វិនិច្ឆ័យ។ ពាក្យបណ្តឹងត្រូវធ្វើតាមទម្រង់បែបបទពាក្យបណ្តឹងរបស់គណៈកម្មការរដ្ឋបាល *(ទម្រង់បែបបទលេខ១)* ឬទម្រង់ផ្ទាល់ខ្លួនដែលមានខ្លឹមសារប្រហាក់ប្រហែល។

២.២.បន្ទាប់ពីទទួលបានពាក្យបណ្តឹង គណៈកម្មការរដ្ឋបាលត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដើម្បីពិនិត្យ ស្រាវជ្រាវ អំពីប្រវត្តិនៃករណីវិវាទឲ្យបានច្បាស់ *(ទម្រង់បែបបទលេខ២)* ហើយត្រូវព្យាយាមធ្វើការសម្រុះសម្រួលរកការព្រមព្រៀងគ្នា។ ប្រសិនបើគូភាគី មានការព្រមព្រៀងគ្នា គណៈកម្មការរដ្ឋបាលត្រូវធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទបញ្ចប់វិវាទ *(ទម្រង់បែបបទលេខ៣)* ។

២.៣.ចំពោះក្បាលដីវិវាទដែលការដោះស្រាយពុំបានជោគជ័យ គណៈកម្មការរដ្ឋបាលត្រូវបំពេញរបាយការណ៍សម្រុះសម្រួល ដោយរៀបរាប់អំពីលទ្ធផលនៃការដោះស្រាយ និងជំហរចុងក្រោយរបស់គូភាគី *(ទម្រង់បែបបទលេខ៤)* និងបំពេញទម្រង់បែបបទបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ *(ទម្រង់បែបបទលេខ៥)*។ ការបញ្ជូនសំណុំរឿងវិវាទត្រូវធ្វើឲ្យបានរួចរាល់ក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីតំបន់វិនិច្ឆ័យនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធត្រូវបានបញ្ចប់។

៣.ការបញ្ជូនសំណុំរឿងវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាល និងការដោះស្រាយរបស់គណៈកម្មការសុរិយោដី

៣.១.ករណីវិវាទដែលគណៈកម្មការរដ្ឋបាលមិនអាចសម្រុះសម្រួលរកការព្រមព្រៀងពីគូភាគីបាន ត្រូវបញ្ជូនសំណុំរឿងវិវាទនេះទៅគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនៃទីតាំងដីវិវាទ លើកលែងតែក្បាលដីវិវាទដូចបានកំណត់ក្នុងចំណុចទី ៤ នៃសេចក្តីណែនាំនេះ។

៣.២.បន្ទាប់ពីបានទទួលសំណុំរឿងវិវាទពីគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវចុះលេខសំណុំរឿងតាមលំដាប់លំដោយនៃកាលបរិច្ឆេទ ដូចពាក្យបណ្តឹងដែលបានប្តឹងផ្ទាល់ ទៅគណៈកម្មការសុរិយោដី និងត្រូវបន្តដោះស្រាយតាមនីតិវិធីកំណត់។

៣.៣.ករណីវិវាទដែលគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ មិនអាចដោះស្រាយបាន ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ដើម្បីបន្តដោះស្រាយមុននឹងបញ្ជូនមកគណៈកម្មការសុរិយោដីថ្នាក់ជាតិ តាមស្មារតីមាត្រា ១២ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

៣.៤.ក្នុងករណីដែលទទួលបានសំណុំរឿងច្រើនពីគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ អាចស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិតាមរយៈគណៈកម្មការសុរិយោដីរាជធានី ខេត្ត ដើម្បីពិនិត្យលទ្ធភាពបញ្ជូនក្រុមដោះស្រាយវិវាទដីធ្លីចល័តចុះជួយដោះស្រាយ ប្រសិនបើចំនួនមន្ត្រីមិនអាចឆ្លើយតបទាន់ពេលវេលា។

៣.៥.ចំពោះក្បាលដីវិវាទដែលនៅសេសសល់ក្នុងតំបន់ដែលបានបញ្ចប់ការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធមុនកាលបរិច្ឆេទនៃសេចក្តីណែនាំនេះ គណៈកម្មការរដ្ឋបាលរាជធានីខេត្ត ត្រូវធ្វើបញ្ជីរាយមុខឯកសារក្នុងសំណុំរឿងវិវាទនីមួយៗដោយមិនចាំ

បាច់ភ្ជាប់សំណុំរឿងវិវាទ ដើម្បីបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យលទ្ធភាពដោះស្រាយដូចមានចែងក្នុងចំណុច ៣.៤ (*ទម្រង់បែបបទលេខ៦*)។

៤. នីតិវិធីនៃការច្រានចោលពាក្យបណ្តឹងរបស់គណៈកម្មការរដ្ឋបាល

៤.១.គណៈកម្មការរដ្ឋបាលត្រូវបំពេញទម្រង់បែបបទច្រានចោលពាក្យបណ្តឹង បន្ទាប់ពីបានព្យាយាមធ្វើការដោះស្រាយពុំបានជោគជ័យ ចំពោះក្បាលដីវិវាទដែលធ្លាប់បានចុះបញ្ជីសុរិយោដីរួចហើយ ឬក្បាលដីវិវាទពាក់ព័ន្ធនឹងកិច្ចសន្យាទិញ លក់ ជួល បញ្ចាំ ការប្តឹងទាមទារបែងចែកមរតក ដូចបានកំណត់ក្នុងប្រការ ១ និងប្រការ ៤ នៃប្រកាសអន្តរក្រសួងលេខ ០២ ប្រក.រ.០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកំណត់សមត្ថកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿងវិវាទដីធ្លី ។ គណៈកម្មការរដ្ឋបាលមិនត្រូវបញ្ជូនសំណុំរឿងទៅគណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ទោះបីជាមានសំណូមពរពីគូភាគីវិវាទក៏ដោយ ព្រោះករណីវិវាទបែបនោះជាសមត្ថកិច្ចដោះស្រាយរបស់ស្ថាប័នតុលាការ។

៤.២.ការសម្រេចច្រានចោលពាក្យបណ្តឹងណាមួយរបស់គណៈកម្មការរដ្ឋបាលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់អំពីមូលហេតុនៃការច្រានចោលឲ្យបានច្បាស់លាស់ និងចុះហត្ថលេខាដោយប្រធានគណៈកម្មការរដ្ឋបាល *(ទម្រង់បែបបទលេខ៧)* ។

៤.៣.គណៈកម្មការរដ្ឋបាល ត្រូវផ្តាកជាបណ្តោះអាសន្ន នូវការអនុវត្តនីតិវិធីចុះបញ្ជីសុរិយោដី ឬចាត់វិធានការផ្សេងៗចំពោះក្បាលដីវិវាទរហូតដល់មានការដោះស្រាយចប់ជាស្ថាពរ។

ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត ប្រធានគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត ដែលមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានគណៈកម្មការសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវអនុវត្តតាមការកំណត់ខាងលើនេះ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលឹម

កន្លែងទទួល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-រដ្ឋបាលសាលារាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ
"ដើម្បីជូនជ្រាប"
-គណៈកម្មការសុរិយោដីរាជធានី/ខេត្ត/ក្រុង/ស្រុក-ខណ្ឌ
-គណៈកម្មការរដ្ឋបាលរាជធានី ខេត្ត
" ដើម្បីអនុវត្ត "
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ: ៦៣៤ ដនស/គសជ

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ ឫទ្ធា ឆ្នាំ ២០០៧

ជំរាបជូន

ឯកឧត្តម អភិបាល និងជាប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង

កម្មវត្ថុ : អំពីការប្រគល់សិទ្ធិជូន ឯកឧត្តម ប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង ក្នុងការស្រើបអង្កេត និងសម្រុះសម្រួលករណីវិវាទ ដែលគណៈកម្មការរដ្ឋបាលធ្វើការសម្រុះសម្រួលពុំបានជោគជ័យ ។

យោង : ស្មារតីអង្គប្រជុំ ថ្ងៃទី ២៣-០៥-០៧ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាប ឯកឧត្តមអភិបាល និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ជ្រាបថា ក្នុងពេលចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅក្នុងតំបន់វិនិច្ឆ័យ ករណីវិវាទមួយចំនួនត្រូវបានធ្វើការសម្រុះសម្រួល និងបញ្ចប់ទំនាស់ដោយគណៈកម្មការរដ្ឋបាល មួយចំនួនទៀតត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិព្រោះគូភាគីពុំឯកភាពគ្នាបង្កើតកិច្ចព្រមព្រៀងបញ្ចប់ទំនាស់នាពេលនោះ ។ គណៈកម្មការសុរិយោដីថ្នាក់ជាតិពិនិត្យឃើញថា សំណុំរឿងជាច្រើនដែលត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពីគណៈកម្មការរដ្ឋបាលនៃខេត្ត ក្រុង ធ្វើការចុះបញ្ជីដីជាប្រព័ន្ធ ជាសំណុំរឿងដែលពុំទាន់បានធ្វើការដោះស្រាយដោយគណៈ-កម្មការរដ្ឋបាលឱ្យបានគ្រប់គ្រាន់តាមនីតិវិធីនៅឡើយ គឺខ្វះខាតទាំងលើការស្រើបអង្កេតករណីទំនាស់ ទាំងលើការសំរុះសំរួល ។ ក្នុងលក្ខណៈនេះ គណៈកម្មការសុរិយោដីថ្នាក់ជាតិ ទន្ទឹមនឹងពុំមានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីធ្វើការវិនិច្ឆ័យបើកសវនាការថ្នាក់ជាតិ ក៏ពុំមានលទ្ធភាពដើម្បីចុះសិក្សាករណីទំនាស់ដោយផ្ទាល់បានឡើយ ។

អាស្រ័យហេតុនេះ ខ្ញុំសូមប្រគល់សិទ្ធិជូនឯកឧត្តមអភិបាល និងជាប្រធានគណៈកម្មការសុរិយោដីខេត្ត ក្រុង ដែលមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធអនុវត្តការស្រើបអង្កេត និងសំរុះសំរួលវិវាទក្នុងនាមគណៈកម្មការសុរិយោដីថ្នាក់ជាតិ រាល់ករណីវិវាទដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិបញ្ជូនមកគណៈកម្មការសុរិយោដីខេត្ត ក្រុង ។ ក្នុងករណីដែលការសំរុះសំរួលពុំអាចឈានដល់ការព្រមព្រៀងគណៈកម្មការសុរិយោដីខេត្ត ក្រុង ត្រូវបញ្ជូនសំណុំរឿងវិវាទដោយភ្ជាប់ជាមួយឯកសារពាក់ព័ន្ធទាំងអស់ត្រឡប់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិវិញ ដើម្បីបើកសវនាការសំរេចសេចក្តី ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម អភិបាល និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដែលមានការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ចាត់ឱ្យអនុវត្តចាប់ពីពេលនេះតទៅ ។

សូមឯកឧត្តមទទួលនូវការរាប់អានអំពីខ្ញុំ ។

ទេសរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ុម ឈុនលឹម

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-ឯកសារ-កាលប្បវត្តិ

Letter to all PMCS

អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ

Tel : (855) 023 215 659 - 215 660 , Fax : (855) 023 215 277, e-mail : im. c . lim. @ Camnet. Com. kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ: ១០៦៧ ដ.ន.ស/គសជ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៥

ជម្រាបជូន
- **ឯកឧត្តមអភិបាល នៃគណៈអភិបាល និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត**
- **ឯកឧត្តមប្រធានគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត**

កម្មវត្ថុ : ការដាក់ឲ្យអនុវត្តសេចក្តីណែនាំលេខ០២៩ដនស/គសជចុះថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការដ្ឋបាល និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ។

យោង :-អនុក្រឹត្យលេខ៤៦អនក្រ.បកចុះថ្ងៃទី៣១/០៥/២០០២ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី
-អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១/០៥/២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
-អនុក្រឹត្យលេខ៣៤ អនក្រ.បកចុះថ្ងៃទី ២០/០៤/២០០៦ ស្តីពីការកែប្រែមាត្រា៥និងមាត្រា២៨នៃអនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១/០៥/២០០២

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា កន្លងមកក្នុងពេលដំណើរការអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ មាននៅសល់ក្បាលដីវិវាទមួយចំនួនដែលមិនទាន់បានដោះស្រាយចប់នៅឡើយ។ ករណីនេះធ្វើឲ្យក្បាលដីវិវាទទាំងនោះត្រូវបានរក្សាទុក និងមិនអាចបន្តនីតិវិធីចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន។

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាលក្នុងពេលដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ក៏ដូចជាគណៈកម្មការសុរិយោដីថ្នាក់ជាតិ បានដាក់ឲ្យអនុវត្តសាកល្បងនូវសេចក្តីណែនាំលេខ ០២៩ដនស/គសជ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីរបស់គណៈកម្មការរដ្ឋបាលនិងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លីក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធក្នុងខេត្តចំនួន ៣ គឺខេត្តតាកែវ ខេត្តកំពង់ធំ និងខេត្តព្រៃវែង ជាលទ្ធផលឃើញថា បានបង្កើនប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីដោះស្រាយវិវាទដីធ្លីបានមួយកម្រិតថែមទៀត។

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel: (855) 23 215 659-215 660, Fax: (855) 23 215 277, E-mail: im.c.lim.@camnet.com.kh

អាស្រ័យហេតុនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ សម្រេចដាក់ឲ្យអនុវត្តនូវសេចក្តីណែនាំលេខ ០២៩ ដនស/គសជ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២ ខាងលើនៅគ្រប់រាជធានី ខេត្ត ចាប់ពីពេលនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោដីរាជធានី ខេត្ត និងប្រធានគណៈកម្មការរដ្ឋបាលគ្រប់រាជធានី ខេត្ត ត្រូវចាត់ចែងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម**ឯកឧត្តម** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អ៊ឹម ឈុនលឹម

គណៈកម្មការសុវិយោជី		ខេត្ត		ស្រុក		ឆ្នាំ		លែខ		
លេខសំណុំរឿង	គ.ស.ស.ខ									
លេខសំណុំរឿង	គ.ស.ខ.ក									
លេខសំណុំរឿង	គ.ស.ជ									

ទម្រង់បែបបទនៃពាក្យបណ្តឹង

ពត៌មានអំពីជើមបណ្តឹង				
ឈ្មោះជើមបណ្តឹង:	ថ្ងៃខែឆ្នាំកំណើត:	ប្រុស ☐ ស្រី ☐	សញ្ជាតិ:	មុខរបរ:
ឈ្មោះប្តី ឬ ប្រពន្ធ:		ចំនួនកូន:		

ទីលំនៅបច្ចុប្បន្ធរបស់ជើមបណ្តឹង					
ខេត្ត ក្រុង:	ស្រុក ខណ្ឌ:	ឃុំ សង្កាត់:	ភូមិ:	ផ្លូវលេខ:	ផ្ទះលេខ:

ទំហំ ព្រំប្រទល់ និងទីតាំងជីដែលប្តឹងទាមទារ

ទំហំ : ព្រំប្រទល់ : -ខាងជើង -ខាងត្បូង

-ខាងកើត -ខាងលិច

ស្ថិតនៅក្នុង ខេត្ត ក្រុង : ស្រុក ខណ្ឌ : ឃុំ សង្កាត់ : ភូមិ :

អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិករ របស់ភាគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាពត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១000.000 (មួយលាន) រៀល ដល់ ១០.000.000 (មួយលាន)រៀល ដល់ ១០.0000.000 (ដប់លាន) រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។

មាត្រា ២៦៤.

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដីត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ដល់ ៥.000.000 (ដប់លាន)រៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។
រាប់បញ្ចូលជាការរំលោភ ការផ្តល់ទិន្នន័យជាផ្លូវការខុស ការចេញប័ណ្ណកម្មសិទ្ធិខុស ការបិទបាំងហ៊ីប៉ូតែកឬបន្ទុកផ្សេងៗ ការបោះគោលព្រំដីខុសដោយចេតនា និងរាល់ការធ្វេសប្រហែសក្នុងការធ្វើលេខាចារិករលើឯកសារសុរិយោដី ។

ឧបសម្ព័ន្ធទី២៣

ព្រះរាជាណាចក្រកម្ពុជា

គណៈកម្មការសុរិយោដីរាជធានី-ខេត្ត ..... ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : .....

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីរាជធានី-ខេត្ត.....

-បានឃើញរាជក្រមលេខ នស.រកម ០៨០១.១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ. ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការសុរិយោដី

-បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក.ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៦ ស្តីពីការកែប្រែមាត្រា ៥ និងមាត្រា ២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្របក.ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

-បានឃើញប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពី គោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី

-បានឃើញប្រកាសលេខ.....ដនស/គសជចុះថ្ងៃទី.....ខែ.....ឆ្នាំ២០១០ស្តីពីការធ្វើប្រតិភូកម្មជូនអភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តដើម្បីធ្វើសេចក្តីសម្រេចលើករណីវិវាទដីធ្លីក្នុងយន្តការរបស់គណៈកម្មការសុរិយោដី

-បានឃើញសារាចរណែនាំលេខ.....ដនស/គសជ ចុះថ្ងៃទី.....ខែ.....ឆ្នាំ ស្តីពី របៀបរបបនៃការធ្វើសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី

-យោងតាមសំណុំរឿងវិវាទដែលបានបញ្ជូនមកពីគណៈកម្មការសុរិយោដីថ្នាក់ក្រុង-ស្រុក-ខណ្ឌ.....ដែលមិនអាចសម្រុះសម្រួលបញ្ចប់វិវាទដោយជោគជ័យជាលើកចុងក្រោយកាលពីថ្ងៃទី.....ខែ.....ឆ្នាំ ..... នៅគណៈកម្មការសុរិយោដីរាជធានី-ខេត្ត.....

-យោងកិច្ចប្រជុំនៅថ្ងៃទី.....ខែ.....ឆ្នាំ.....របស់គណៈកម្មការសុរិយោដីរាជធានី ខេត្ត..... ដើម្បីពិនិត្យសម្រេចលើ សំណុំរឿង វិវាទលេខ.....ចុះថ្ងៃទី.....ខែ.....ឆ្នាំ ដូចខាងក្រោមនេះ :

១. ការពិនិត្យអង្គហេតុ:

ក. អំពីភាគីវិវាទ :

ឈ្មោះរបស់ដើមបណ្តឹង_____ថ្ងៃខែឆ្នាំកំណើត_____

ភេទ_____សញ្ជាតិ_____ មុខរបរ_____

អាសយដ្ឋានរបស់ដើមបណ្តឹង:_____

_____

_____

_____

ឈ្មោះរបស់ចុងបណ្តឹង_____ថ្ងៃខែឆ្នាំកំណើត_____

ភេទ_____សញ្ជាតិ_____ មុខរបរ_____

អាសយដ្ឋានរបស់ចុងបណ្តឹង:_____

_____

_____

_____

ខ. អំពីវិវាទ: (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

_____

_____

_____

_____

_____

គ. សេចក្តីសង្ខេបអំពីវិវាទ:(ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

_____

_____

_____

ឃ. សេចក្តីសង្ខេបអំពីដំណើរការដោះស្រាយវិវាទ : (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

_____

_____

_____

_____

_____

_____

ង. សេចក្តីសន្និដ្ឋានទៅលើអង្គហេតុ: (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1) _____

_____

(2) _____

_____

(3) _____

_____

(4) _____

_____

(5) _____

_____

២. សេចក្តីសន្និដ្ឋានទៅលើអង្គច្បាប់ : (ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1) _____

_____

(2) _____

_____

(3) _____

_____

(4) _____

_____

(5) _____

_____

៣. សេចក្តីសំរេច:(ភ្ជាប់ទំព័របន្ថែមបើចាំបាច់)

(1) _____

_____

(2) _____

_____

(3) _____

_____

(4) _____

_____

(5) _____

_____

សេចក្តីសំរេចរបស់គណៈកម្មការសុរិយោដីរាជធានី-ខេត្ត.....នឹងចូលជាស្ថាពរ លើកលែងតែភាគីស្នើរសុំឱ្យគណៈកម្មការសុរិយោដីថ្នាក់ជាតិបើកសវនាការឡើងវិញក្នុងកំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីសម្រេចពីគណៈកម្មការសុរិយោដី ឬថ្ងៃដែលបានជូនដំណឹងអំពីសេចក្តីសម្រេចនេះ ។

.....: ថ្ងៃទី.....ខែ.....ឆ្នាំ.....

ប្រធានគណៈកម្មការសុរិយោដីរាជធានី\ខេត្ត.....

គណៈកម្មការសុរិយោដី		ខេត្ត		ស្រុក		ឆ្នាំ		លេខ		
លេខសំណុំរឿង	គ.ស.ស.ខ									
លេខសំណុំរឿង	គ.ស.ខ.ក									
លេខសំណុំរឿង	គ.ស.ជ									

ទម្រង់បែបបទស្នើសុំបើកសវនាការឡើងវិញ

ព័ត៌មានអំពីអ្នកស្នើសុំសវនាការឡើងវិញ (អតីតដើមបណ្តឹង☐ ឬចុងបណ្តឹង☐)				
ឈ្មោះអ្នកស្នើសុំ :	ថ្ងៃខែឆ្នាំកំណើត:	ប្រុស ☐ ស្រី ☐	សញ្ជាតិ:	មុខរបរ:
ឈ្មោះប្តី ឬ ប្រពន្ធ:		ចំនួនកូន:		
ទីលំនៅបច្ចុប្បន្នរបស់អ្នកស្នើសុំ				
រាជធានី ខេត្ត :	ក្រុង ស្រុក ខណ្ឌ:	ឃុំ សង្កាត់:	ភូមិ:	ផ្លូវលេខ: ផ្ទះលេខ:
ទីតាំង និងទំហំដីដែលមានវិវាទ				
រាជធានី ខេត្ត :	ក្រុង ស្រុក ខណ្ឌ:	ឃុំ សង្កាត់:	ភូមិ:	ផ្លូវលេខ: ផ្ទះលេខ:
ទំហំដីវិវាទ :				

ព័ត៌មានអំពីតាគីម្ខាងទៀត (អតីតដើមបណ្តឹង☐ ឬចុងបណ្តឹង☐) (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)	
ឈ្មោះ :	ទីលំនៅបច្ចុប្បន្ន/ លេខទូរស័ព្ទ/:
១.	
២	

សេចក្តីអធិប្បាយចុងក្រោយរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)	
យោងសេចក្តីសម្រេចលេខ	
១.មិនសុខចិត្តលើសេចក្តីសម្រេចទាំងមូល	☐
២.មិនសុខចិត្តលើសេចក្តីសម្រេចត្រង់ចំណុច	ទី១☐-ទី២☐-ទី៣☐-ទី៤☐-ទី៥☐
៣.ផ្សេងៗ	

ឧបសម្ព័ន្ធ ទី ២៩

ឯកសារអំណះអំណាងថ្មីបន្ថែមប្រសិនជាមាន (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)	
១.	៤.
២.	៥.
៣.	៦.

សំណូមពរដោះស្រាយ ឬដំហរដោះស្រាយរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)
១.
២.
៣.
៤.
៥.

កាលបរិច្ឆេទ:...../...../.....

ស្លាមេដៃរបស់អ្នកស្នើសុំបើកសវនាការឡើងវិញ

កាលបរិច្ឆេទ: ____/____/____

ហត្ថលេខារបស់មន្ត្រីទទួលពាក្យបណ្តឹង

បានឃើញ

កាលបរិច្ឆេទ : ...../...../.....

ប្រធានគណៈកម្មការសុរិយោដី

កំណត់សំគាល់ :

-អ្នកស្នើសុំបើកសវនាការឡើងវិញអាចប្រើប្រាស់ទម្រង់បែបបទផ្សេងៗទៀតបាន ប៉ុន្តែត្រូវដាក់បញ្ចូលពត៌មានខាងលើនេះ

-អ្នកស្នើសុំបើកសវនាការឡើងវិញត្រូវផ្តិតមេដៃ និងចុះកាលបរិច្ឆេទនៅថ្ងៃដែលខ្លួនបានដាក់ពាក្យបណ្តឹងនៅចំពោះមុខមន្ត្រីទទួលពាក្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរដ្ឋបាល.....
លេខសម្គាល់ក្បាលដី.....

ទម្រង់បែបបទពាក្យបណ្តឹង[1]

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....អាយុ.....ឆ្នាំ សញ្ជាតិ.....មុខរបរ.....
ប្តីឬប្រពន្ធឈ្មោះ.....ចំនួនកូន.....អាស័យដ្ឋានសព្វថ្ងៃ.....
.....
ទីតាំងដីវិវាទ.....មានទំហំប្រមាណ.....។

សូមគោរពជូន

លោកប្រធានគណៈកម្មការរដ្ឋបាលរាជធានី ខេត្ត.....

សូមមានព្រាប ៖

កម្មវត្ថុ៖ ប្តឹងទាមទារ.....
ពីឈ្មោះ.....អាយុ.....ឆ្នាំ.....មុខរបរ.....
អាស័យដ្ឋានសព្វថ្ងៃ.....
ទូរស័ព្ទលេខ.....
រឿងដំណើររឿងវិវាទមានដូចតទៅ (សូមភ្ជាប់ឯកសារបន្ថែមប្រសិនបើចាំបាច់)
.....
.....
.....
.....
.....
.....
.....
.....
.....
.....

ឯកសារអំណះអំណាង (ដើមបណ្តឹង) (ថតចម្លងដើម្បីដាក់បញ្ចូលក្នុងសំណុំរឿងវិវាទ)

១.	៤.
២.	៥.
៣.	៦.

សាក្សីរបស់ដើមបណ្តឹង (ចម្លើយទាំងឡាយបញ្ចូលក្នុងសំណុំរឿងវិវាទ)

ឈ្មោះ	ព័ត៌មានសម្រាប់ទាក់ទង (អាស័យដ្ឋាន លេខទូរស័ព្ទ)

ទទួលដោយ៖..... .....ថ្ងៃទី.....ខែ.....ឆ្នាំ.....
កាលបរិច្ឆេទ៖..... ស្នាមមេដៃ ឬហត្ថលេខារបស់ដើមបណ្តឹង
ហត្ថលេខាអ្នកទទួល៖

---

១. **សំគាល់៖** ដើមបណ្តឹងអាចប្រើប្រាស់ទម្រង់បែបបទផ្សេងទៀតបាន ប៉ុន្តែត្រូវដាក់ព័ត៌មានខាងលើនេះ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរដ្ឋបាល.....
លេខសម្គាល់ក្បាលដី.....

កំណត់ហេតុវិវាទនៅវាល

១.ព័ត៌មានអំពីភាគី ☐.ដើមបណ្តឹង ☐.ចុងបណ្តឹង

ឈ្មោះ.....ភេទ.....អាយុ.....ឆ្នាំ សញ្ជាតិ.....មុខរបរ.....
ទីលំនៅបច្ចុប្បន្ន:.....
លេខទូរស័ព្ទ:.....

២.ព័ត៌មានក្បាលដី: **ទំហំដីវិវាទ**.....☐.ទាំងអស់ ☐.មួយផ្នែក

សេចក្តីអធិប្បាយរបស់ភាគី (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)

ជំហររបស់ភាគី (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)

ភស្តុតាងរបស់ភាគី (សូមថតចម្លង និងភ្ជាប់ជាមួយកំណត់ហេតុនៅវាល)

១	_____	៤	_____
២	_____	៥	_____
៣	_____	៦	_____

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ថ្ងៃទី...../...../.....
ហត្ថលេខា និងឈ្មោះអ្នកធ្វើកំណត់ហេតុ

ឈ្មោះ: និងស្នាមមេដៃ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរដ្ឋបាល.....

លេខសម្គាល់ក្បាលដី.....

កំណត់ហេតុវិវាទនៅវាល

ព័ត៌មានអំពីសាក្សី ☐.ដើមបណ្តឹង ☐.ចុងបណ្តឹង

ឈ្មោះ.....ភេទ.....អាយុ.....ឆ្នាំ សញ្ជាតិ.....មុខរបរ.....

ទីលំនៅបច្ចុប្បន្ន:.....

លេខទូរស័ព្ទ:.....

ចម្លើយរបស់សាក្សី (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ថ្ងៃទី...../...../.....

ឈ្មោះ និងស្នាមមេដៃរបស់សាក្សី

ហត្ថលេខា និងឈ្មោះអ្នកធ្វើកំណត់ហេតុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់បែបបទបញ្ចប់វិវាទ

ព័ត៌មានអំពីវិវាទ					
ប្រភេទទំនាស:					
ទីតាំងនៃដីដែលមានវិវាទ					
រាជធានី ខេត	ក្រុង ស្រុក ខណ្ឌ	ឃុំ សង្កាត	ភូមិ	ផ្លូវលេខ	ផ្ទះលេខ

ព័ត៌មានអំពីដើមបណ្តឹង					
ឈ្មោះដើមបណ្តឹង:		ភេទ :		ថ្ងៃខែឆ្នាំកំណើត:	
ទីលំនៅបច្ចុប្បន្នរបស់ដើមបណ្តឹង					
រាជធានី ខេត្ត	ក្រុង ស្រុក ខណ្ឌ	ឃុំ សង្កាត	ភូមិ	ផ្លូវលេខ	ផ្ទះលេខ

ព័ត៌មានអំពីចុងបណ្តឹង					
ឈ្មោះចុងបណ្តឹង:		ភេទ :		ថ្ងៃខែឆ្នាំកំណើត:	
ទីលំនៅបច្ចុប្បន្នរបស់ចុងបណ្តឹង					
រាជធានី ខេត្ត	ក្រុង ស្រុក ខណ្ឌ	ឃុំ សង្កាត	ភូមិ	ផ្លូវលេខ	ផ្ទះលេខ

សេចក្តីអធិប្បាយអំពីកិច្ចព្រមព្រៀង (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)

ឯកសារភ្ជាប់មកជាមួយ	
១.	៤.
២.	៥.
៣.	៦.

ស្នាមមេដៃ និងឈ្មោះរបស់ភាគីវិវាទ

ភាគីដើមបណ្តឹង ភាគីចុងបណ្តឹង

កាលបរិច្ឆេទ:...../...../.....

ប្រធានគណៈកម្មការរដ្ឋបាល

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរដ្ឋបាល .....

លេខសម្គាល់ក្បាលដី.....

ឡាយការណ៍សម្រុះសម្រួល

ព័ត៌មានអំពីវិវាទ					
ទំនាស់រវាងដើមបណ្តឹងឈ្មោះ			និងចុងបណ្តឹងឈ្មោះ		
ប្រភេទដីវិវាទ៖			ទំហំដីវិវាទ៖		
ទីតាំងនៃដីដែលមានវិវាទ					
រាជធានី ខេត្ត	ក្រុង ស្រុក ខណ្ឌ	ឃុំ សង្កាត់	ភូមិ	ផ្លូវលេខ	ផ្ទះលេខ

ខ្លឹមសារសង្ខេបនៃវិវាទ (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)

ខ្លឹមសារសង្ខេបអំពីជំហរដើមបណ្តឹងដែលប្រកាន់យក (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)

ខ្លឹមសារសង្ខេបអំពីជំហរចុងបណ្តឹងដែលប្រកាន់យក (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)

យោបល់របស់គណៈកម្មការរដ្ឋបាល ឬអង្គសម្រុះសម្រួល (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)

ឯកសារភ្ជាប់មកជាមួយ	
១.	៤.
២.	៥.
៣.	៦.

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

អ្នកថ្វើបាយការណ៍

បានឃើញ និងឯកភាព

.....ថ្ងៃទី...../...../.....

ប្រធានគណៈកម្មការរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទម្រង់បែបបទច្រានចោលពាក្យបណ្តឹង

ទម្រង់បែបបទច្រានចោលពាក្យបណ្តឹង ត្រូវតែបំពេញជាលាយលក្ខ័ណអក្សរ ដោយយោងទៅតាមតម្រូវការនៃច្បាប់។
ទម្រង់នេះត្រូវបំពេញដោយប្រធានគណៈកម្មការរដ្ឋបាលដែលទទួលវិវាទនោះ។

ព័ត៌មានអំពីជនជាប់ចោទ					
ឈ្មោះដើមបណ្តឹង៖			ភេទ៖	ថ្ងៃខែឆ្នាំកំណើត៖	
ឈ្មោះចុងបណ្តឹង៖			ភេទ៖	ថ្ងៃខែឆ្នាំកំណើត៖	
ទីតាំងនៃដីដែលមានវិវាទ					
រាជធានី ខេត្ត	ក្រុង ស្រុក ខណ្ឌ	ឃុំ សង្កាត	ភូមិ	ផ្លូវលេខ	ផ្ទះលេខ
ប្រភេទដីទំនាស់៖					

មូលហេតុនៃការច្រានចោលពាក្យបណ្តឹង (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)

ឯកសារអំណះអំណាង (សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចំបាច់)	
១.	៤.
២.	៥.
៣.	៦.

កាលបរិច្ឆេទ _____/_____/_____

ប្រធានគណៈកម្មការរដ្ឋបាល
ហត្ថលេខា និងត្រា

ទម្រង់បែបបទលេខ ៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរដ្ឋបាល.....

លេខ..... .....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ទម្រង់បែបបទបញ្ជូនសំណុំរឿងវិវាទ

គណៈកម្មការរដ្ឋបាលរាជធានី/ខេត្ត.....សូមបញ្ជូនករណីវិវាទក្នុងតំបន់វិនិច្ឆ័យចំនួន.....ករណី ដែលមានខ្លឹមសារលំអិតនៅខាងក្រោម ជូនគណៈកម្មការសុរិយោសុរិយោដី.....ដើម្បីពិនិត្យដោះស្រាយ។

(សូមភ្ជាប់ទំព័របន្ថែមប្រសិនបើចាំបាច់)

ល.រ	ឈ្មោះភាគី	តំបន់វិនិច្ឆ័យ	អយមុខលិខិត	ចំនួន	បាលឧទ្ទូល	សេចក្តីផ្សេងៗ
១						
២						
៣						
៤						

សម្គាល់៖ បញ្ជីឯកសារនេះ បញ្ចប់ត្រឹមលេខរៀងទី.....មានចំនួន .....ច្បាប់ និង .....សន្លឹក។

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

អ្នកទទួល

ប្រធានគណៈកម្មការរដ្ឋបាល

ហត្ថលេខា និងត្រា

ទម្រង់បែបបទលេខ ៦

គណៈកម្មការរដ្ឋបាល.....

តំបន់ឯកិនិច្ឆ័យឃុំ.....ស្រុក.....

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ជីស្ថិតិសុំណុំរឿងវិវាទក្នុងតំបន់ឯកិនិច្ឆ័យ

ល.រ	កាលបរិច្ឆេទទទួលពាក្យបណ្តឹង	អំពីតាគីវិវាទ		អំពីអត្តសញ្ញាណក្បាលដី			ការដោះស្រាយ (គូសសញ្ញាណ ✓)		ផ្សេងៗ
		ដើមបណ្តឹង	ចុងបណ្តឹង	ក្បាលដីលេខ	ទំហំដី	ទីតាំងស្ថិតនៅភូមិ	ធ្លាប់សម្រុះសម្រួល	មិនធ្លាប់សម្រុះសម្រួល	
១									
២									
៣									
៤									
៥									
៦									
៧									
៨									
៩									
១០									
១១									
១២									

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

អ្នកធ្វើតារាង

បានឃើញ និងឯកភាព

.....ថ្ងៃទី.....ខែ.....ឆ្នាំ.....

ប្រធានគណៈកម្មការរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ការប្រែងសំណួរ ចម្លើយ ពាក់ព័ន្ធនឹងការងាររបស់ គណៈកម្មការសុរិយោដី

ឆ្នាំ ២០០៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សូមគោរពជូន

ឯកឧត្តមរដ្ឋមន្ត្រី

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

និងជាប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ

យើងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមគោរពជូនឯកឧត្តមនូវកម្រងសំណូរ និងចម្លើយដែលបានលើកឡើងនៅក្នុងវគ្គសិក្សាបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់កណ្តាលចំនួន ១២នាក់ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១០-២១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដោយមានសំណូមពរសូមឱ្យមានការសម្រេចឯកភាពនូវចម្លើយរួមមួយដើម្បីយកទៅបណ្តុះបណ្តាលនៅថ្នាក់ក្រោម យើងខ្ញុំក៏បានរៀបចំសរសេរនូវចម្លើយតាមសំណូមពររបស់សិក្ខាកាមទៅនឹងសំណូរទាំងអស់នោះ ។ យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅក្នុងការដែល ឯកឧត្តមផ្តល់នូវការណែនាំ និងសម្រេចនូវចម្លើយចំពោះសំណូរទាំងនោះ ។

យើងខ្ញុំបានប្រើប្រាស់នូវអក្សរកាត់ និងពាក្យដើម្បីសម្គាល់មួយចំនួន ដូចជា ៖

១. ប័ណ្ណ = ប័ណ្ណសម្គាល់សិទ្ធិទាំងឡាយណា ទោះបីជាប័ណ្ណភោគៈ ឬប័ណ្ណកម្មសិទ្ធិក៏ដោយដែលចេញឱ្យប្រើប្រាស់ចាប់តាំងពីឆ្នាំ ១៩៨៩ ដោយនាយកដ្ឋានសុរិយោដី សាលាក្រុងភ្នំពេញ ឬក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនថាកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ។

២. ដីដែលបានចុះបញ្ជីសុរិយោដី = គឺដីដែលមានប័ណ្ណ

យើងខ្ញុំបានរៀបចំនូវសំណូរ និងចម្លើយទាំងអស់ទៅតាមប្រធានបទ ។ លេខដែលនៅក្នុងវង្វង់ក្រចក បន្ទាប់ពីសំណូរនីមួយៗ គឺជាលេខនៃកម្រងសំណូរទាំងអស់ដែលប្រមូលបាននៅក្នុងវគ្គបណ្តុះបណ្តាលដែលពុំទាន់បានបែងចែកទៅតាមប្រធានបទនៅឡើយ។ ហើយនៅក្នុងករណីខ្លះ សំណូរដែលមានភាពប្រហាក់ប្រហែលគ្នាត្រូវបានគេបញ្ចូលជាសំណូរតែមួយ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

សូមគោរពជូនពរសុខភាពល្អ និងជ័យជំនះគ្រប់ភារកិច្ច ។

ភ្នំពេញ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៣

សំណួរដែលទាក់ទងនឹងយុត្តាធិការ

១. តើគណៈកម្មការសុរិយោដីគ្រប់ជាន់ថ្នាក់ មានយុត្តាធិការយ៉ាងដូចម្តេច ?

ចម្លើយ :- ជាទូទៅគណៈកម្មការសុរិយោដីមានយុត្តាធិការលើវិវាទដីធ្លីទាំងឡាយដែលមិនទាន់ បានចុះបញ្ជីសុរិយោដីរវាងភោគីនឹងភោគី (មាត្រា ៤៧នៃច្បាប់ ភូមិបាលឆ្នាំ ២០០១) ។ ក្នុងច្បាប់នេះដែរ ជំពូកទី ៤ បានពិពណិនាអំពីភោគី ។ មាត្រា ៣ មាត្រា ៦ និង មាត្រា ១៨ នៃអនុក្រឹត្យលេខ ៤៧ បានពន្យល់អំពីវិវាទដីធ្លីទាំងនេះ ដែលកើតនៅក្នុង តំបន់វិនិច្ឆ័យ និងនៅក្រៅតំបន់វិនិច្ឆ័យ ។ វិវាទដីធ្លីទាំងឡាយណាដែលនៅក្រៅតំបន់ វិនិច្ឆ័យ ឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ វិវាទ ដីធ្លី ទាំងឡាយណាដែលនៅក្នុងតំបន់វិនិច្ឆ័យ ហើយមិនអាចត្រូវបានសម្រុះសម្រួល ដោយគណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិតែម្តង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុង មានសិទ្ធិត្រឹមតែសម្រុះ សម្រួលវិវាទប៉ុណ្ណោះ ។ គណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចសម្រុះសម្រួលវិវាទ និងសម្រេចលើវិវាទនោះ ។

២. តើគណៈកម្មការសុរិយោដីមានយុត្តាធិការលើដីវិវាទដែលមានឯកសារដីធ្លីចុះបញ្ជីមុនឆ្នាំ ១៩៨៩ ដែរ ឬទេ ?

ចម្លើយ :- គណៈកម្មការសុរិយោដី មានយុត្តាធិការពេញលេញលើវិវាទដីធ្លីប្រភេទនេះ ។ ពីព្រោះថា ទើបតែនៅថ្ងៃទី ២៩-៣០ មេសា ១៩៨៩ រដ្ឋសភាជាតិកម្ពុជាបានធ្វើ វិសោធនកម្មរដ្ឋធម្មនុញ្ញ ដោយអនុញ្ញាតឱ្យមានសិទ្ធិឯកជនលើដីធ្លី (មាត្រា ១៥ និងមាត្រា ១៧នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៨៩) និងសេចក្តីណែនាំ លេខ ០៣ សណន (ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៨៩) របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។ បន្ទាប់មកទៀត ទើបចាប់ផ្តើមបង្កើតនាយកដ្ឋានសុរិយោដី ដើម្បីចុះបញ្ជីសុរិយោដី ។ មុនពេលនោះ ពុំទាន់មានប័ណ្ណសម្គាល់សិទ្ធិលើដីធ្លីទេ បើរាប់ គឺចាប់តាំងពីឆ្នាំ ១៩៧៥ មកទល់ឆ្នាំ ១៩៨៩ បានសេចក្តីថា នៅមុនខែ មេសា ឆ្នាំ ១៩៨៩ ឬមុនបង្កើតនាយកដ្ឋានសុរិយោដី ដីពុំទាន់ត្រូវបានចុះបញ្ជីសុរិយោដីទេ ។ ហេតុដូច្នេះហើយ ដីដែលមានការកត់ត្រា

ផ្សេងៗមុនពេលបង្កើតនាយកដ្ឋានសុរិយោដីដែលណែនាំដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅឆ្នាំ ១៩៨៩ មិនអាចចាត់ទុកថា ជាដីដែលបានចុះបញ្ជីសុរិយោដីទេ ។

៣. លិខិតឆ្លើយតបទៅនឹងសំណើសុំកាន់កាប់ដីដែលធ្វើនៅភ្នំពេញ អាចចាត់ទុកថា ជាដីចុះបញ្ជីសុរិយោដីដែរឬទេ ?

ចម្លើយ :- លិខិតឆ្លើយតបទៅនឹងសំណើសុំកាន់កាប់ដីដែលធ្វើនៅភ្នំពេញ មិនអាចចាត់ទុកថា ដីនោះជាដីចុះបញ្ជីសុរិយោដីបានទេ ។ ដីដែលចាត់ទុកថា បានចុះបញ្ជីសុរិយោដីត្រឹមត្រូវ គឺដីដែលបានចុះបញ្ជីសុរិយោដី និងចេញប័ណ្ណសម្គាល់សិទ្ធិតាមការណែនាំជំនាញដោយអតីតនាយកដ្ឋានសុរិយោដី ឬដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

៤. តើគណៈកម្មការសុរិយោដីមានយុត្តាធិការលើដីដែលជាសម្បត្តិសាធារណៈរបស់រដ្ឋដែរឬទេ ? សូមកំណត់ឱ្យបានច្បាស់អំពីដីសាធារណៈរបស់រដ្ឋ ។

ចម្លើយ :- ដីសាធារណៈរបស់រដ្ឋ គឺជាដីទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា ១៥នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។ បច្ចុប្បន្ន មិនទាន់មានមូលដ្ឋានផ្លូវច្បាប់ណាផ្សេងទៀត ដើម្បីកំណត់ថា ដីណាជាដីសាធារណៈរបស់រដ្ឋនោះទេ ។ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (មាត្រា ១៣ ទ.១ នៃអនុក្រឹត្យលេខ ៤៧) និងថ្នាក់ជាតិ មានយុត្តាធិការលើវិវាទដីសាធារណៈរបស់រដ្ឋ បើសិនជាដីនោះមិនទាន់ចុះបញ្ជីសុរិយោដី ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ មិនមានយុត្តាធិការលើវិវាទដីសាធារណៈរបស់រដ្ឋឡើយ ទោះបីដីនោះមិនទាន់បានចុះបញ្ជីសុរិយោដីក្តី ។

៥.តើវាមានភាពខុសប្លែកពីគ្នាដែរឬទេរវាងដីរបស់រដ្ឋដែលនៅក្នុងបញ្ជីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដីសាធារណៈរបស់រដ្ឋដែលមានចែងនៅក្នុងមាត្រា ១៥នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ?

ចម្លើយ :- បទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ៣០ បប. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តម្រូវឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំឱ្យបានរួចរាល់នូវបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋ ហើយបញ្ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ។ បញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋនោះ រួមមាន ទាំងទ្រព្យសាធារណៈ និងទ្រព្យឯកជនរបស់រដ្ឋ ។ ចំណែកឯ

មាត្រា ១៥នៃច្បាប់ភូមិបាលឆ្នាំ ២០០១ គ្របដណ្តប់តែទៅលើដីសាធារណៈ របស់រដ្ឋ ប៉ុណ្ណោះ។

បញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋនៃស្ថាប័នដទៃទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ដូចជា បញ្ជីដែលធ្វើឡើងនៅក្នុងអំឡុងពេល UNTAC ជាដើម មិនបានបង្កើតឱ្យមានការចុះបញ្ជីសុរិយោដីឡើយ ។ ហេតុដូច្នេះ មិនមានការរាំងស្ទះអ្វីដល់យុត្តាធិការរបស់គណៈកម្មការសុរិយោដីទេ ។

៦. ទោះបីជាច្បាប់ភូមិបាលមាត្រា ១៥ បានរាយនូវប្រភេទដីដែលជាដីសាធារណៈរបស់រដ្ឋក៏ដោយ ក៏ច្បាប់នោះមិនបានកំណត់អំពីព្រំប្រទល់ដីទាំងនោះច្បាស់លាស់នៅឡើយ ។ ជាឧទាហរណ៍ ក្នុងមាត្រានោះបានរាប់បញ្ចូលដីត្រើយសមុទ្រជាដីសាធារណៈរបស់រដ្ឋ ប៉ុន្តែមិនបានកំណត់ថា តើនៅទីណាត្រឹមណាជាដែនកំណត់ព្រំប្រទល់ទេ ? រាជរដ្ឋាភិបាលកំពុងតែធ្វើការដោះស្រាយបញ្ហានេះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីព្រំប្រទល់នៃដីទាំងនោះ ប៉ុន្តែមិនទាន់បានបញ្ចប់សព្វគ្រប់នៅឡើយ ។ ការដឹងនូវព្រំប្រទល់ដីទាំងនោះឱ្យបានច្បាស់លាស់ គឺមានសារៈសំខាន់ណាស់ក្នុងការសម្រេចយុត្តាធិការរបស់គណៈកម្មការសុរិយោដី ។ ការខ្វះខាតមិនបានកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់យ៉ាងនេះ អាចនាំឱ្យមានការពិបាកក្នុងការសម្រេចយុត្តាធិការរបស់គណៈកម្មការសុរិយោដីឬទេ ?

<u>ចម្លើយ</u> :- ការខ្វះខាតមិនបានកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ មិននាំឱ្យមានការពិបាកក្នុងការសម្រេចយុត្តាធិការរបស់គណៈកម្មការសុរិយោដីទេ ។ ដីរាបណាដី និងទឹកទាំងឡាយណាដែលមិនបានចុះបញ្ជីសុរិយោដី គឺគណៈកម្មការសុរិយោដីមានយុត្តាធិការលើវិវាទដីប្រភេទនោះទាំងអស់ ។ ប៉ុន្តែ នៅពេលដែលមានសំណួរទាក់ទងនឹងសិទ្ធិទៅលើដីនោះ ទើបការកំណត់ព្រំប្រទល់មិនបានច្បាស់លាស់ ចោទជាបញ្ហា ។

នៅពេលមានវិវាទទាក់ទងទៅនឹងដីរបស់រដ្ឋ គណៈកម្មការសុរិយោដីត្រូវតែស៊ើបអង្កេតឱ្យបានច្បាស់លាស់ថា ដីនោះជាដីឯកជន ឬដីសាធារណៈរបស់រដ្ឋ ។ បើសិនដីនោះ ជាដីសាធារណៈរបស់រដ្ឋ ហើយទម្រាំតែរាជរដ្ឋាភិបាលសម្រេចជាគោលការណ៍លើបញ្ហានេះ គណៈកម្មការសុរិយោដីគួរតែធ្វើតាមការណែនាំដូចខាងក្រោម ដើម្បីឱ្យមានភាពច្បាស់លាស់ និងឯកភាពគ្នាជាបណ្តោះអាសន្ន ៖

ក. <u>ព្រៃឈើ</u>

គណៈកម្មការសុរិយោដីត្រូវតែចុះធ្វើការស៊ើបអង្កេតដោយផ្ទាល់ ដើម្បីដឹងថា ដីនោះជាដីព្រៃតដែរឬទេ ?

ខ. ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន ឬបណ្តែតបាន

ទាំងនេះ គឺជាផ្លូវទឹកទាំងឡាយណាដែលទន្លេ ឬខ្សែទឹកផ្សេងៗជាដើមដែលតែងតែហូរកាត់ជាទៀងទាត់ ក្នុងរយៈពេលមធ្យមនៃរដូវដែលមានទឹកជំនន់ ឬរដូវវស្សាក្នុងឆ្នាំនីមួយៗ ។

គ. បឹងធម្មជាតិ

ទាំងនេះ គឺជាដីទាំងឡាយណាដែលគ្របដណ្តប់ដោយទឹកជាទៀងទាត់ក្នុងរយៈពេលមធ្យមនៃរដូវដែលមានទឹកជំនន់ ឬរដូវវស្សាក្នុងឆ្នាំនីមួយៗ ។

ឃ. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន ឬបណ្តែតបាន

ច្រាំងទន្លេចាប់ផ្តើមនៅទីដែលដីចាប់ផ្តើមជ្រាលទេរយ៉ាងខ្លាំងទៅកាន់ទន្លេ ។

ង. ត្រើយសមុទ្រ

ត្រើយសមុទ្រ គឺជាទីកន្លែងណាដែលងើបចេញជាមធ្យមពីសមុទ្រ ។ បើបើសិនជាមានឆ្នេរខ្សាច់ ព្រំប្រទល់នៃត្រើយសមុទ្រ គឺជាទីកន្លែងដែលចាប់ផ្តើមមានរុក្ខជាតិដុះ និងដាំបាន ។

ច. ដីផ្លូវសាធារណៈ

នៅពេលបច្ចុប្បន្ននេះ មានការណែនាំតែមួយគត់ដែលទាក់ទងនឹងទទឹងផ្លូវសាធារណៈ គឺប្រការ ៨នៃសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល លេខ ០៦ ប្រកចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី បានចែង ដូចខាងក្រោមនេះ ៖

- ផ្លូវជាតិដែលមានលេខមួយខ្ទង់ ដូចជា ២-៣-៦-៧ ចម្ងាយ២៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ លើកលែងតែផ្លូវជាតិលេខ ១-៤-៥ កំណត់ចម្ងាយ ៣០ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។
- ផ្លូវជាតិដែលមានលេខ ២ខ្ទង់ ដូចជា លេខ ១១-២២-៦៤-៧៨ ចម្ងាយ ២៥ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។
- ផ្លូវខេត្តចម្ងាយ ២០ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។
- ផ្លូវឃុំចម្ងាយ ១៥ ម៉ែត្រពីសងខាងអ័ក្សផ្លូវ ។

ការកំណត់ចំណីផ្លូវនេះ មិនយកមកអនុវត្តក្នុងទីប្រជុំជនទេ ។

៧. តើគណៈកម្មការសុរិយោដីមានយុត្តាធិការទៅលើវិវាទ ដែលភាគីម្ខាងជារដ្ឋបានដកហូតដីឯកជនរបស់បុគ្គលសម្រាប់គម្រោងជាសាធារណៈណាមួយ ឬរឿងក្តីប្រភេទណាមួយក៏ដោយដែលមានភាគីម្ខាងទៀតជារដ្ឋ ?

ចម្លើយ :- គណៈកម្មការសុរិយោដី មិនមានយុត្តាធិការលើវិវាទដែលរដ្ឋធ្វើការដកហូតដីសម្រាប់គម្រោងសាធារណៈឡើយ ។ វិវាទបែបនេះ ត្រូវតែបានដោះស្រាយដោយគណៈកម្មការមួយដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល ។ នៅពេលដែលរដ្ឋ ត្រូវការជម្លៀសប្រជាជនចេញពីដីរបស់រដ្ឋ គណៈកម្មការសុរិយោដីមានយុត្តាធិការ បើសិនជាភាគីដើមបណ្តឹងប្តឹងទាមទារកម្មសិទ្ធិលើអចលនវត្ថុតាមលទ្ធកម្មពិសេសនៃភោគៈ ដូចដែលមានចែងក្នុងជំពូកទី ៤នៃច្បាប់ ភូមិបាល។ ទោះបីយ៉ាងណាក៏ដោយ ក៏គណៈកម្មការសុរិយោដីគ្មានយុត្តាធិការទេ បើសិនជា ដើមបណ្តឹងគ្រាន់តែផ្អែកទៅលើការព្រមព្រៀងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ជាមួយនឹងអាជ្ញាធរអំពីការអនុញ្ញាតឱ្យកាន់កាប់ដីនោះ ដោយហេតុថា អាជ្ញាធរអាចបញ្ឈប់ការកាន់កាប់ដីនោះបាន ។

៨. មាត្រា ២០ និងមាត្រា ២១នៃច្បាប់ ភូមិបាលបានចែងថា អចលនវត្ថុជាដី និងជាសំណង់ដែលមាននៅក្នុង និងក្រៅបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនា មិនអាចក្លាយទៅជាទ្រព្យសម្បត្តិឯកជនរបស់បុគ្គលណាមួយឡើយ ។ មិនមានន័យមន័យឱ្យបានច្បាស់លាស់ទាក់ទងនឹងទីតាំងក្រៅបរិវេណវត្តទេ ហើយភាគច្រើនមិនទាន់បានចុះបញ្ជីសុរិយោដីនៅឡើយ ទោះបីជាយថាហេតុ ដីប្រភេទនេះនឹងត្រូវតែបានចុះបញ្ជីសុរិយោដីក៏ដោយ ។ តើគណៈកម្មការសុរិយោដីមានយុត្តាធិការលើទ្រព្យវត្តប្រភេទនេះដែរឬទេ ?

ចម្លើយ :- គណៈកម្មការសុរិយោដី មានយុត្តាធិការលើវិវាទទាមទារដីដែលជាទ្រព្យវត្តនេះ បើសិនជា ដីនោះមិនទាន់ត្រូវបានចុះបញ្ជីសុរិយោដីនៅឡើយទេ ។ ប្រសិនជាដីនោះត្រូវបានចុះបញ្ជីរួចហើយ នោះគណៈកម្មការសុរិយោដីមិនមានយុត្តាធិការទេ ។

៩. មាត្រា ២៦នៃច្បាប់ ភូមិបាល បានចែងថា សហគមន៍ជនជាតិដើមភាគតិចនឹងមានកម្មសិទ្ធិលើដីដែលគេកំពុងរស់នៅ និងធ្វើកសិកម្ម ។ ដោយផ្អែកតាមមាតិកាទី ៦នៃច្បាប់ ភូមិបាល និងអនុក្រឹត្យទាំងឡាយដែលពាក់ព័ន្ធ ពួកគេនឹងត្រូវទទួលបានឯកសារសម្គាល់សិទ្ធិលើដីទាំង នោះរួមទាំងការ

កំណត់ព្រំប្រទល់ផង ។ ហើយឯកសារទាំងនេះ នឹងក្លាយជាប័ណ្ណមួយប្រភេទបន្ថែមទៀតនៃ បញ្ជីសុរិយោដី ។ ទម្រាំតែដល់ពេលចេញប័ណ្ណទាំងនេះ តើត្រូវសម្រេចយ៉ាងដូចម្តេចដើម្បីឱ្យដឹងថា ដីទាំងនោះនៅទីណាពិតប្រាកដ ?

<u>ចម្លើយ</u> :- មិនមានការណែនាំដ៏ជាក់ច្បាស់ណាមួយលើបញ្ហានេះទេ ក្រៅពីគណៈកម្មការសុរិយោដី ។ ហេតុនេះ ត្រូវតែធ្វើការស៊ើបអង្កេតឱ្យបានប្រយ័ត្នប្រយែង ដូចដែលមានចែងនៅក្នុងមាត្រា ២៥នៃច្បាប់ ភូមិបាល ស្តីពីការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ។

១០. តើដីសម្បទានអាចកំណត់ថា ជាដីដែលបានចុះបញ្ជីសុរិយោដីហើយឬទេ ?

<u>ចម្លើយ</u> :- ផ្អែកតាមមាត្រា ៥៣នៃច្បាប់ ភូមិបាល បានតម្រូវឱ្យចុះបញ្ជីសុរិយោដីនូវដីសម្បទាន ។ ហេតុនេះ ដីសម្បទានគឺជាដីដែលបានចុះបញ្ជីសុរិយោដី ដែលគណៈកម្មការសុរិយោដីមិនមានយុត្តាធិការលើវិវាទនេះទេ ។

១១. ដីសម្បទានមានពាក់ព័ន្ធនឹងប្រជាជនមួយចំនួន ខ្លះមានប័ណ្ណ ខ្លះគ្មានប័ណ្ណ តើឯតនៅក្រោមយុត្តាធិការណា ?

<u>ចម្លើយ</u> :- គ្មានយុត្តាធិការរបស់គណៈកម្មការសុរិយោដីទេ នៅពេលដែលដីនោះជាដីចុះបញ្ជីសុរិយោដី ។

១២. តើដីដែលបានបាត់បង់ដោយការប្រើអំពើហឹង្សា មុនច្បាប់ភូមិបាលចូលជាធរមាន ឬមុនការបង្កើតគណៈកម្មការសុរិយោដី តើភាគីម្ចាស់ដីដែលបាត់បង់ដីនោះមានសិទ្ធិដាក់ពាក្យប្តឹងមកគណៈកម្មការសុរិយោដីដើម្បីទាមទារដីនោះបានដែរឬទេ ?

<u>ចម្លើយ</u>:-បើសិនជាដីនោះជាដីដែលមិនទាន់ចុះបញ្ជីសុរិយោដីគណៈកម្មការសុរិយោដីមានយុត្តាធិការលើរឿងក្តីនោះ ។

បើសិនជាដីនោះជាដីដែលបានចុះបញ្ជីសុរិយោដីរួចហើយគណៈកម្មការសុរិយោដីមិនអាចទទួលយករឿងក្តីនោះបានទេ ។

១៣.ដីទំនាស់ជាប់ព្រំគ្នាដែលមានព្រំប្រទល់មិនច្បាស់លាស់ ។ ដីមួយមានប័ណ្ណដីមួយគ្មានប័ណ្ណ ។

ពេលវិវាទកើតឡើងត្រង់ចំណុចព្រំប្រទល់ដែលមិនច្បាស់លាស់នោះ តើគណៈកម្មការសុរិយោដីមានយុត្តាធិការដែរឬទេ ?

<u>ចម្លើយ</u> :- បើសិនជា មិនច្បាស់ថា ដីនោះមានប័ណ្ណ ឬគ្មានប័ណ្ណ យោងតាមប្រការ ១៩នៃប្រកាស លេខ ១១២ គណៈកម្មការសុរិយោដីត្រូវសម្រេចថា ខ្លួនមានយុត្តាធិការ ។ គណៈកម្មការសុរិយោដីត្រូវទទួលរឿងក្តីនោះ ហើយធ្វើការស៊ើបអង្កេត បើឃើញថា គណៈកម្មការសុរិយោដីមិនមានយុត្តាធិការលើវិវាទនោះទេ ទើបសម្រេចច្រានចោលវិវាទនោះជាក្រោយ យោងតាមប្រការ ១៧នៃប្រកាស ១១២ ។ នៅក្នុងជម្លោះព្រំប្រទល់ដូច្នេះ គណៈកម្មការសុរិយោដីត្រូវតែព្យាយាមដើម្បីសម្រេចឱ្យដឹងថា អ្នកប្តឹងមានប័ណ្ណ ឬគ្មានប័ណ្ណ ។ បើសិនជាអ្នកគ្មានប័ណ្ណជាដើមបណ្តឹងនោះជាយុត្តាធិការរបស់គណៈកម្មការសុរិយោដី ។ បើសិនជា អ្នកមានប័ណ្ណជាដើមបណ្តឹងវិញនោះ មិនមែនជាយុត្តាធិការរបស់គណៈកម្មការសុរិយោដីទេ ។

១៤. ដីដែលស្ថិតនៅតំបន់ព្រំប្រទល់រដ្ឋបាលមិនច្បាស់លាស់ តើគួរកំណត់យុត្តាធិការយ៉ាងដូចម្តេច ?

<u>ចម្លើយ</u> :- បើសិនជា ដីនោះឋិតនៅក្នុងស្រុក ២ផ្សេងគ្នានៃខេត្តតែមួយ នោះគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។

បើសិនជា ដីវិវាទឋិតនៅក្នុងខេត្តផ្សេងគ្នា នោះគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងបញ្ជូនទៅថ្នាក់ជាតិ ។ ទម្រង់បែបបទនៃការបញ្ជូនសំណុំរឿងត្រូវភ្ជាប់ជាមួយនឹងព័តិមានដែលទាក់ទងនឹងវិវាទ និងសំណើនៃការដោះស្រាយវិវាទ ។

១៥. ករណីដែលភាគីទំនាស់មកប្តឹងថា ដីនោះជាដីគ្មានប័ណ្ណទេ តែក្រោយការស៊ើបអង្កេតឃើញថា ដីនោះ មានប័ណ្ណដែលបានលក់ត១គ្នាជាច្រើនលើកច្រើនសាណាស់មកហើយ ។ តើយើងត្រូវបន្តដោះស្រាយ ឬបង្វែអទៅតុលាការ ?

<u>ចម្លើយ</u> :- នៅគ្រប់ករណីដែលថា គណៈកម្មការសុរិយោដីធ្វើការស៊ើបអង្កេតទៅឃើញថា ជាដី

ដែលបានចុះបញ្ជីសុរិយោដីរួចហើយ គណៈកម្មការសុរិយោដីត្រូវច្រានចោលបណ្តឹងនោះ ហើយ ឈប់ដំណើរការដោះស្រាយវិវាទនោះ។

១៦. តើគណៈកម្មការសុរិយោដី មានយុត្តាធិការលើវិវាទដែលភាគីម្ខាងមិនមានសញ្ជាតិខ្មែរដែរឬទេ ?

(មិនទាន់មានចម្លើយ)

១៧. សូមចែងអំពីការកំណត់រយៈពេលនៃសិទ្ធិប្តឹងនៅក្នុងវិវាទដីធ្លីឱ្យបានច្បាស់ ។

ចម្លើយ :- រហូតមកដល់ពេលនេះ ពុំមានច្បាប់ណាមួយដែលចែងអំពីពេលកំណត់នៃការដាក់ពាក្យប្តឹងវិវាទដីធ្លីទៅតុលាការទេ ។ ដូចគ្នានេះដែរ ការដាក់ពាក្យប្តឹងមកគណៈកម្មការសុរិយោដីក៏មិនមានពេលកំណត់ទេ (មានករណីលើកលែងមួយនៅក្នុងមាត្រា ៣៣ នៃច្បាប់ ភូមិបាល ដែលទាក់ទងទៅនឹងការដកហូតយកដីធ្លីដោយការរំលោភអំណាច ឬដោយអំពើហឹង្សាពីសំណាក់អាជ្ញាធរ ដីនោះត្រូវបង្វែរមកជាដីរបស់រដ្ឋវិញដោយប្រកាសនៃការដកហូតរបស់រដ្ឋពីជនដែលរំលោភនោះ ។ ជនរងគ្រោះ ត្រូវប្តឹងដើម្បីទាមទារសិទ្ធិលើដីនោះវិញ ក្នុងអំឡុងពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសដកហូតដោយរដ្ឋ ។ បើហួសពីពេលនេះ ភាគីរងគ្រោះមិនអាចប្តឹងបានទេ ហើយដីនោះក៏មិនអាចក្លាយជាកម្មវត្ថុនៃការកាន់កាប់ថ្មីទៀតដែរ) ។

យុត្តាធិការរបស់គណៈកម្មការសុរិយោដី យុត្តាធិការរបស់តុលាការ

១៨. បើសិនជាភាគីមួយបានទទួលការដោះស្រាយនៅតុលាការរួចហើយ ប៉ុន្តែភាគីមិនអស់ចិត្ត នឹងសេចក្តីសម្រេចនោះ បើសិនជាភាគីនោះប្តឹងមកគណៈកម្មការសុរិយោដី តើគណៈកម្មការសុរិយោដីទទួលយកឬទេ ?

ចម្លើយ :- នៅក្នុងករណីបែបនេះ គណៈកម្មការសុរិយោដីមិនអាចទទួលយករឿងក្តីនោះបានទេ ។

១៩. បើសិនជា រឿងវិវាទនោះឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ប៉ុន្តែភាគីទាំងសងខាងបានព្រមព្រៀងគ្នាប្តឹងទៅតុលាការជំនួសឱ្យការប្តឹងមកគណៈកម្មការសុរិយោដីវិញ ។ តើភាគីទាំង ២ អាចធ្វើដូច្នេះបានដែរឬទេ ?

ចម្លើយ :- មាត្រា ៤៧ នៃច្បាប់ ភូមិបាលតម្រូវឱ្យជម្លោះទាំងឡាយណាដែលឋិតនៅវែក្រោមយុត្តាធិការ

របស់គណៈកម្មការសុរិយោដីត្រូវតែចូលមកគណៈកម្មការសុរិយោដី មិនមានជម្រើសណាផ្សេងទៀតទេ ។ ភាគីវិវាទ អាចប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ នៅក្នុងករណីមានការបដិសេធមិនព្រមធ្វើការសម្រុះសម្រួល រឿងក្តីក៏ត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ភាគីទាំងសងខាង អាចធ្វើការបដិសេធមិនព្រមធ្វើការសម្រុះសម្រួលម្តងទៀត ។ ប៉ុន្តែ នៅពេលដែលរឿងក្តីត្រូវបានបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ បើសិនជា ពួកគេនៅតែបដិសេធមិនព្រមធ្វើការសម្រុះសម្រួល នោះការសម្រេចសេចក្តីនឹងត្រូវធ្វើឡើងចំពោះរឿងក្តីនោះ អ្នកដែលចាញ់អាចប្តឹងទៅតុលាការបាន ។

២០. បើសិនជា វិវាទមួយមិនឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដីទេ ប៉ុន្តែភាគីទាំងសងខាងព្រមព្រៀងគ្នាប្តឹងទៅគណៈកម្មការសុរិយោដីជំនួសឱ្យតុលាការ ។ តើអាចបានឬទេ ?

<u>ចម្លើយ</u> :- អង្គហេតុដែលបង្ហាញថា វិវាទមិនឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី បណ្តឹងមិនអាចត្រូវបានផ្លាស់ប្តូរតាមតែចំណង់ចំណូលចិត្តរបស់ភាគីបានទេ ។

២១.តើភាគីអាចប្តឹងទៅគណៈកម្មការសុរិយោដីផង និងទៅតុលាការផងក្នុងពេលតែមួយបានដែរឬទេ ?

<u>ចម្លើយ</u> :- មិនអាចទេ ។ បើសិនជា ឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី នោះវិវាទនោះត្រូវតែប្តឹងមកគណៈកម្មការសុរិយោដី ទោះបីមានភាគីណាមួយប្តឹងទៅតុលាការក៏តុលាការមិនទទួលពាក្យប្តឹងឡើយ ។ វិវាទមួយមិនអាចត្រូវបានប្តឹងមកគណៈកម្មការសុរិយោដីផង ឬ /និងតុលាការផងក្នុងពេលតែមួយបានទេ ។

២២. បន្ទាប់ពីការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ បើសិនជា មានភាគីមួយណាមិនសុខចិត្តហើយប្តឹងទៅតុលាការ តើតុលាការមួយណាដែលមានយុត្តាធិការដើម្បីដោះស្រាយវិវាទនេះ ?

(មិនទាន់មានចម្លើយ)

២៣. តើត្រូវធ្វើដូចម្តេចក្នុងការផ្ទេរសំណុំរឿងពីតុលាការមកឱ្យគណៈកម្មការសុរិយោដីវិញ ក្នុងករណីដែលសំណុំរឿងទាំងនោះឋិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ?

<u>ចម្លើយ</u> : សំណុំរឿងវិវាទដែលស្ថិតនៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ប៉ុន្តែភាគីបានប្តឹងទៅតុលាការ ហើយតុលាការកំពុងចាត់ការសំណុំរឿងនោះ តុលាការត្រូវបន្ត និងបញ្ចប់ការដោះស្រាយវិវាទ ។ ចំពោះករណីនេះ តុលាការអាចសំណូមពរមកក្រសួងរៀបចំដែនដី នគរូប-

នីយកម្ម និងសំណង់ បំភ្លឺផ្នែកបច្ចេកទេសសុរិយោដី ។ បន្ទាប់ពីការចេញប្រកាសអន្តរក្រសួងរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ តុលាការខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលបណ្តឹងពាក់ពន្ធ័នឹងវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជីសុរិយោដី ។

បណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់

២៤. តើធ្វើដូចម្តេចដើម្បីទទួលបានអន្តរាគមន៍ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ដូចជា ប៉ូលីសឱ្យមានប្រសិទ្ធភាពដើម្បីការពារ ឬទប់ស្កាត់អំពើហឹង្សានៅក្នុងអំឡុងពេលមានបណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់ បន្ទាប់ពីទទួលបានពាក្យប្តឹងដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ឬក្នុងការអនុវត្តសេចក្តីសម្រេច (សេចក្តីសម្រេចបណ្តោះអាសន្ន ឬសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ) ?

<u>ចម្លើយ</u> :- មាត្រា ២៦៣នៃច្បាប់ ភូមិបាលបានចែងទាក់ទងទៅនឹងការផាកពិន័យ និងទណ្ឌកម្ម ខាងផ្នែករដ្ឋបាលដល់អាជ្ញាធរមានសមត្ថកិច្ច ដូចតទៅ " អាជ្ញាធរមានសមត្ថកិច្ចដែលព្រងើយកន្តើយ ឬបណ្តោយឱ្យសាមញ្ញជនប្រព្រឹត្តដោយរំលោភសិទ្ធិរបស់កម្មសិទ្ធិការរបស់ភោគី ឬរបស់អ្នកកាន់កាប់ដោយសន្តិភាព ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.000.000 (មួយលានរៀល) ដល់ ១0. 000.000 (ដប់លានរៀល) និងត្រូវទទួលទោសរដ្ឋបាលថែមទៀត ។ វិធានការមួយដ៏ប្រសើរ ដើម្បីអនុវត្តមាត្រាខាងលើគឺប្រកាសអន្តរក្រសួងរបស់ក្រសួងរៀងចំដែនដី នគរូបនីយកម្ម និងសំណង់ជាមួយក្រសួងមហាផ្ទៃ ។ ប្រកាសអន្តរក្រសួងនេះត្រូវមានចែងអំពីវិធានការបន្ទាប់ពីបានទទួលពាក្យប្តឹង ៖

- គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវជូនដំណឹងដល់អភិបាលស្រុក ខណ្ឌ
- ក្នុងសេចក្តីជូនដំណឹងរបស់គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌដែលបានបិទផ្សាយ

ជាមួយពាក្យប្តឹងត្រូវមានខ្លឹមសារបង្គាប់បញ្ជាឱ្យគូភាគីរក្សាស្ថានភាពកាន់កាប់នៅដដែល (មិនត្រូវសាងសង់ ឬព័ទ្ធរបង មិនត្រូវឈូសឆាយ ឬចាក់ដីបំពេញ មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យគូភាគី ...)

- ជនណារំលោភបទបញ្ជានេះ ត្រូវទប់ស្កាត់ជាបន្ទាន់

- អាជ្ញាធរមូលដ្ឋាន (ឃុំ សង្កាត់ ស្រុក ខណ្ឌ) ត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានបទបញ្ជានេះ ។

២៥. តើគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុងអាចចេញសេចក្តីសម្រេចបណ្តោះអាសន្ន ដើម្បីបញ្ឈប់អំពើហឹង្សានៅពេលមានបណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់ដែរឬទេ ?

<u>ចម្លើយ</u> :-គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងថ្នាកខេត្តក្រុង មិនអាចចេញសេចក្តីសម្រេចបណ្តោះអាសន្នដើម្បីបញ្ឈប់អំពើហឹង្សានៅពេលមានបណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់បានទេ ។ យោងតាមប្រការ ៣៩ នៃប្រកាស លេខ ១១២ មានតែគណៈកម្មការសុរិយោដីថ្នាក់ជាតិទេ ដែលអាចចេញសេចក្តីសម្រេចបណ្តោះអាសន្តបាន ។

២៦. បើសិនជា ករណីបន្ទាន់កើតមានបន្ទាប់ពីគណៈកម្មការសុរិយោដីចាប់ផ្តើមរឿងក្តី តើយ៉ាងដូចម្តេចទៅវិញ ?

<u>ចម្លើយ</u> :- សៀវភៅនីតិវិធីបានចែងថា បណ្តឹងសុំឱ្យធ្វើអន្តរាគមន៍ជាបន្ទាន់ អាចធ្វើឡើងគ្រប់ពេល ទោះបីជាក្រោយពេលគណៈកម្មការសុរិយោដីចាប់ផ្តើមដំណើរការរឿងក្តីហើយក៏ដោយ ដើម្បីការពារផលប្រយោជន៍របស់ភាគីដែលរងការគំរាមកំហែង ។ គណៈកម្មការសុរិយោដីនឹងចេញសេចក្តីសម្រេចបណ្តោះអាសន្ន ដើម្បីរក្សាស្ថេរភាពរហូតមានការសើបអង្កេតនិងសេចក្តីសម្រេច ។

សំណួរដែលទាក់ទងនឹងនីតិវិធី

២៧. តើដើមបណ្តឹងអាចផ្ញើពាក្យប្តឹង តាមអ្នកផ្សេងមកគណៈកម្មការសុរិយោដីបានដែរឬទេ ?

<u>ចម្លើយ</u> :- ប្រការ ៤នៃប្រកាស ១១២បានចែងថា "បុគ្គលដែលប្តឹងទាមទារជាកម្មសិទ្ធិករ ឬភោគីនៃដីត្រូវដាក់ពាក្យប្តឹង លើកលែងតែជននោះជាអសមត្ថជន ។ ក្នុងករណីនេះ អ្នកតំណាងស្របច្បាប់របស់ជននោះ អាចដាក់ពាក្យប្តឹងក្នុងនាមជននោះបាន ។

២៨. លក្ខណៈវិនិច្ឆ័យដែលអាចក្លាយជាសាក្សីមានអ្វីខ្លះ ?

<u>ចម្លើយ</u>:- សាក្សីគឺជាជនដែលដឹង បានឮ ឬបានឃើញរឿងមួយដោយផ្ទាល់ទាក់ទងទៅនឹងវិវាទណាមួយ មិនមែនគ្រាន់តែដឹងឮតាមរយៈជនផ្សេងទៀតទេ ។ សាក្សីក៏ត្រូវអាស្រ័យ

ផងដែរថា តើអ្វីដែលយើងចង់ដឹងពីវិវាទណាមួយនោះ ? ជាញឹកញាប់ សាក្សីនៅក្នុង គណៈកម្មការសុរិយោដីគឺត្រូវតែមានសារៈសំខាន់ក្នុងការជួយឱ្យដឹងថា តើអ្នកណាជាអ្នក កាន់កាប់ដីនោះ ហើយនៅពេលណា ? ជាទូទៅ គណៈកម្មការសុរិយោដីគួរតែសម្តាសគ្រប់ សាក្សីដែលភាគីបានផ្តល់ឱ្យ(សូមមើលប្រការ ១៤ និងប្រការ ១៥នៃប្រកាស ១១២) ។ សាក្សីត្រូវតែជា នីតិជន មានសមត្ថភាព និងមិនជាប់ខ្សែលោហិតជាមួយភាគី ។

២៩. បណ្តឹងដែលប្រជាពលរដ្ឋប្តឹងមកគណៈកម្មការសុរិយោដី ហើយគណៈកម្មការបានចម្លងខ្លឹមសារនៃ បណ្តឹងនោះដាក់ក្នុងទម្រង់បែបបទជាផ្លូវការនៃពាក្យប្តឹង ដោយពុំមានស្នាមមេដៃរបស់ដើមបណ្តឹង ។ តើគេអាចយកទម្រង់បែបបទជាផ្លូវការនៃពាក្យប្តឹង ដែលពុំមានស្នាមមេដៃរបស់ដើមបណ្តឹងនេះ ទៅបិទផ្សាយបានដែរឬទេ ?

<u>ចម្លើយ</u> :- ទម្រង់បែបបទជាផ្លូវការនៃពាក្យប្តឹងដែលពុំមានស្នាមមេដៃរបស់ដើមបណ្តឹង អាចត្រូវ បានយកទៅបិទផ្សាយដោយបិទភ្ជាប់ជាមួយគ្នានឹងពាក្យប្តឹងដើមដែលមានស្នាមមេដៃ របស់ដើមបណ្តឹងនោះតែម្តង (យោងប្រការ ៥នៃប្រកាស ១១២ ដើមបណ្តឹងអាច សរសេរទម្រង់បែបបទពាក្យប្តឹងដោយខ្លួនឯងបាន) ។ សេចក្តីជូនដំណឹងនៃពាក្យប្តឹង ត្រូវបានរៀបចំដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ។ បញ្ហាមិនមែននៅត្រង់ ស្នាមមេដៃនោះទេ ប៉ុន្តែ នៅត្រង់ត្រាជាផ្លូវការរបស់គណកម្មការសុរិយោដីដើម្បីឱ្យ ការបិទផ្សាយមានលក្ខណៈជាផ្លូវការ ។

៣០.នៅពេលដែលមានកំណត់ពេលវេលាសម្រាប់បញ្ចប់កិច្ចការអ្វីមួយ តើគេគួរប្រើពាក្យថាឧទាហរណ៍ "៥ថ្ងៃ" ឬ" ៥ថ្ងៃនៃថ្ងៃធ្វើការ" ?

<u>ចម្លើយ</u>:- ប្រការ ៧នៃប្រកាស ១១២ បានចែងអំពីកំណត់ពេលវេលានៃការបិទផ្សាយពាក្យប្តឹង ដោយប្រើពាក្យថា " ៥ថ្ងៃនៃថ្ងៃធ្វើការ " ហើយបានចែងបន្តនៅវាក្យខណ្ឌបន្ទាប់អំពី រយៈពេលនៃការឆ្លើយតបចំពោះបណ្តឹង " ៣០ថ្ងៃ " ។ គំនិតនេះគឺថា កាលបរិច្ឆេទ ដែលមានរយៈពេលខ្លី គួររាប់តែថ្ងៃ ធ្វើការ ដោយប្រើពាក្យ " ៥ ថ្ងៃនៃ ថ្ងៃធ្វើការ " តែបើកាលបរិច្ឆេទដែលមានរយៈពេលវែង គួររាប់បញ្ចូលទាំងថ្ងៃសម្រាក ផងដែរ ដោយប្រើពាក្យជាឧទាហរណ៍ " ៣០ថ្ងៃ " ។ ធ្វើដូចនេះ ដើម្បីឱ្យកាលបរិច្ឆេទដែល មានរយៈពេលខ្លីមានពេលគ្រប់គ្រាន់ ហើយកាលបរិច្ឆេទដែលមានរយៈពេលវែងកុំឱ្យ

កាន់តែវែងថែមទៀត ។

៣១. កិច្ចប្រជុំរដ្ឋបាល កិច្ចប្រជុំរបស់គណៈកម្មការសុរិយោដី និងកិច្ចប្រជុំសម្រុះសម្រួលខុសគ្នាបែបណា ?

<u>ចម្លើយ</u> :- *កិច្ចប្រជុំរដ្ឋបាល* គឺជាកិច្ចប្រជុំដែលមាននៅគ្រប់ជាន់ថ្នាក់នៃគណៈកម្មការសុរិយោដីក្នុងអំឡុងពេលដោះស្រាយរឿងក្តី ។ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីរៀបចំដំណើរការរឿងក្តី ដោយពឹងផ្អែកទៅលើរឿងក្តីនោះឯតក្នុងដំណាក់កាលណា ។ ជាទូទៅកិច្ចប្រជុំនេះពាក់ព័ន្ធទៅនឹង ការសម្រេចអំពីយុត្តាធិការ ការសម្រេចថា តើរឿងក្តីនោះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់លើ ដោយមិនចាំបាច់មានការសម្រុះសម្រួល ការជ្រើសរើសអ្នកសម្រុះសម្រួល ការលើកឡើងអំពីវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ ការពន្យល់អំពីនីតិវិធីនៃការដោះស្រាយវិវាទដល់ភាគី និងកំណត់ពេលវេលាសម្រាប់ធ្វើការសម្រុះសម្រួល ។ល។

កិច្ចប្រជុំរបស់គណៈកម្មការសុរិយោដី គឺជាកិច្ចប្រជុំ ដែលគណៈកម្មការសុរិយោដីគ្រប់ជាន់ថ្នាក់ រៀបចំឡើងដើម្បីគោលបំណងណាមួយ ។

កិច្ចប្រជុំសម្រុះសម្រួល គឺជាកិច្ចប្រជុំ ដែលមានគោលបំណងសម្រាប់សម្រុះសម្រួលតែប៉ុណ្ណោះ ។

៣២ តើពាក្យថា "កិច្ចប្រជុំរដ្ឋបាល" គួរតែប្រើពាក្យថ្មីដើម្បីជៀសវាងកុំឱ្យមានការច្រឡំគ្នាជាមួយ "កិច្ចប្រជុំរបស់គណៈកម្មការរដ្ឋបាល" ឬទេ ?

<u>ចម្លើយ</u> :- នៅក្នុងអនុក្រឹត្យលេខ ៤៧ មិនបានប្រើពាក្យថា "កិច្ចប្រជុំរដ្ឋបាល" ទេ ។ ប៉ុន្តែប្រការ ៣១ ទ.១ នៃប្រកាសលេខ ១១២ បានចែងថា "ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទសម្រាប់ការសម្រុះសម្រួលជំហានដំបូង ឬការសម្រុះសម្រួលជំហានទី ២ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងនឹងភាគីវិវាទ ។" និងប្រការ ៣១ ទ.៣ នៃប្រកាសលេខ ១១២ បានចែងថា "ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋបាលដំបូង ភាគីវិវាទត្រូវលើកសំណើ និងការ ជំទាស់ចំពោះវិវាទអំពីផលប្រយោជន៍ប្រសិនបើមាន ។" ហេតុដូច្នេះ ត្រូវតែរក្សាពាក្យ "កិច្ចប្រជុំរដ្ឋបាល" ដដែល ។

៣៣. តើរយៈពេលនៃកិច្ចប្រជុំរដ្ឋបាលត្រូវកំណត់បែបណា ?

ចម្លើយ :- បើសិនជា រឿងក្តីរបស់គណៈកម្មការសុរិយោដីភាគច្រើនរវាង២ភាគីនៅលើដីវិវាទតែមួយកន្លែង ហើយគឺពិតជានៅក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដីប្រាកដមែន និងក្រោយពេលដែលគណៈកម្មការសុរិយោដីបានពន្យល់អំពីនីតិវិធីនៃការដោះស្រាយវិវាទដល់ភាគីបានច្បាស់លាស់ហើយនោះ កិច្ចប្រជុំរដ្ឋបាលភាគច្រើនគួរតែមានរយៈពេលប្រហែលជាមួយម៉ោងប៉ុណ្ណោះ ។

៣៤. តើកិច្ចប្រជុំរដ្ឋបាលត្រូវតែប្រព្រឹត្តឡើងនៅពេលណា ?

ចម្លើយ :-ប្រការ ២០នៃប្រកាសលេខ ១១២ បានចែងថា " បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតមិនតិចជាង ៣០ថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹងអំពីបណ្តឹងបានបិទផ្សាយ ដូចមានចែងក្នុងប្រការ ៧នៃប្រកាសនេះ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវរៀបចំប្រជុំគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដើម្បីសម្រេចលើដំណើរការសម្រុះសម្រួលវិវាទ (ក្រោយមកក្នុងប្រការនេះបានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចប្រជុំនេះគឺជាកិច្ចប្រជុំរដ្ឋបាល) ។ ឃ្លា និងពាក្យពេចន៍នៃប្រការ ២០នេះ ជាភាសាខ្មែរ និងអង់គ្លេសមានន័យដូចគ្នា ។ គឺមានន័យថា កិច្ចប្រជុំរដ្ឋបាលត្រូវរង់ចាំ ២លក្ខខណ្ឌ ៖

- ឱ្យការស៊ើបអង្កេតបញ្ចប់សិន
- រង់ចាំឱ្យរយៈពេល ៣០ថ្ងៃកន្លងហួសសិន បន្ទាប់ពីថ្ងៃបិទផ្សាយសេចក្តីជូនដំណឹងនៃពាក្យប្តឹង ។

ប្រការ ១០នៃប្រកាសលេខ ១១២បានចែងថា "ការស៊ើបអង្កេតត្រូវចាប់ផ្តើមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ បានទទួលពាក្យប្តឹង "។ ប្រកាសលេខ ១១២មិនបាននិយាយថា តើការស៊ើបអង្កេតត្រូវបញ្ចប់នៅពេលណាទេ ? ស្បៃវៀកនីតិវិធី ជំពូកទី ៩ វគ្គទី ៩បាននិយាយថា " ការស៊ើបអង្កេតត្រូវតែបញ្ចប់ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលចាប់ផ្តើម បើមិនដូច្នោះទេ លុះត្រាតែមានកាលៈទេសៈលើកលែងដែលធ្វើឱ្យមានការអូសបន្លាយពេល ។ ប្រការ ៧ នៃប្រកាសលេខ ១១២ នេះដែរ បានចែងថា "ក្នុងរយៈពេល ៥ ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យប្តឹង គណៈកម្មការសុរិយោដីថ្នាក់

ស្រុក ខណ្ឌ ត្រូវបិទ ផ្សាយពាក្យប្តឹងនោះរួមជាមួយនឹងសេចក្តីជូនដំណឹងអំពីបណ្តឹង" ។

៣៥.តើការកោះប្រជុំរដ្ឋបាលគួរតែធ្វើឡើងប៉ុន្មានលើក បើកោះលើកទី ១ លើកទី២នៅតែមិនចូលរួម?

<u>ចម្លើយ</u> :- ការកោះប្រជុំរដ្ឋបាលគួរតែធ្វើឡើងឱ្យបាន ៣លើក ។

៣៦.បើសិនជាភាគីមិនមកចូលរួមតាមការអញ្ជើញរបស់គណៈកម្មការសុរិយោដី តើមាននីតិវិធីបែបណាដើម្បីដោះស្រាយទេ ?

<u>ចម្លើយ</u> :-បើសិនជា ភាគីដើមបណ្តឹងមិនមកចូលរួមតាមការអញ្ជើញរបស់គណៈកម្មការសុរិយោដីទេ ហើយបើ គណៈកម្មការសុរិយោដីប្រាកដថា គាត់ត្រូវបានគេជូនដំណឹងហើយ និងពុំមានការគំរាមកំហែងណាមួយជាហេតុផលសម្រាប់ការអាក់ខាននេះទេ គណៈកម្មការសុរិយោដីគួរតែឈប់ដំណើរការករណីវិវាទនេះ ។

បើសិនជា ភាគីចុងបណ្តឹងមិនមកចូលរួមតាមការអញ្ជើញរបស់គណៈកម្មការសុរិយោដីទេ ហើយបើ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងខេត្ត ក្រុង ប្រាកដថា ចុងបណ្តឹងត្រូវបានគេជូនដំណឹងហើយ និងពុំមានការគំរាមកំហែងណាមួយជាហេតុផលសម្រាប់ការអាក់ខាននេះទេ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ និងខេត្ត ក្រុងត្រូវតែប្រកាសអំពីការមិនអាចធ្វើការសម្រុះសម្រួលលើករណីវិវាទនេះ ហើយត្រូវតែបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់លើ ។ បើទៅដល់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយភាគីចុងបណ្តឹងនៅតែមិនចូលរួមទៀត ហើយបើគណៈកម្មការសុរិយោដីថ្នាក់ជាតិប្រាកដថា ចុងបណ្តឹងនោះត្រូវបានគេជូនដំណឹងហើយ និងពុំមានការគំរាមកំហែងណាមួយជាហេតុផលសម្រាប់ការអាក់ខានទេ នោះគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវតែសម្រេចករណីវិវាទនេះ ដោយអវត្តមានចុងបណ្តឹង ។

៣៧.បើសិនជាសមាជិកអាជ្ញាកណ្តាលបានឈប់ពីដំណើរការវិវាទហើយមិនអាចមកតាមការអញ្ជើញរបស់គណៈកម្មការសុរិយោដី ដោយលើកមូលហេតុថា គ្មានសោហ៊ុយគ្រប់គ្រាន់ក្នុងការធ្វើដំណើរ តើគួរចេញសោហ៊ុយឱ្យគាត់ទេ ហើយអ្នកណាជាអ្នកចំណាយ ?

<u>ចម្លើយ</u> :- ការប្រជុំនៅតែអាចប្រព្រឹត្តទៅបាន ទោះបីជាសមាជិកអាជ្ញាកណ្តាលមួយចំនួនមិនបានចូលរួមក៏ដោយ កុំឱ្យតែកិច្ចប្រជុំនោះជាកិច្ចប្រជុំសម្រុះសម្រួល ហើយសមាជិកអាជ្ញាកណ្តាល

ន.ម.ត.ក.-ន/ឱ.ភ.

ដែលមិនបានចូលរួមនោះឋិតក្នុងចំណោមសមាសភាពនៃកិច្ចប្រជុំសម្រុះសម្រួលដែរ ។

៣៨. យោងទៅតាមមាត្រា ៧នៃអនុក្រឹតលេខ ៤៧ "គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវពន្យល់អំពីនីតិវិធីដល់ភាគីវិវាទ ហើយត្រូវសួរថា តើគេយល់ព្រមចំពោះការដោះស្រាយតាមរយៈការសម្រុះសម្រួលទៅតាមនីតិវិធីទាំងនេះឬទេ" ។ តើមានរឿងអ្វីកើតឡើង ប្រសិនបើ ភាគីវិវាទបដិសេធមិនធ្វើតាមនីតិវិធីនេះ ?

<u>ចម្លើយ</u> :- ការសម្រុះសម្រួលអាចធ្វើទៅបាន ប្រសិនបើ វាជាការស្ម័គ្រចិត្តឱ្យធ្វើ ។ ប្រសិនបើ ភាគីវិវាទមួយបដិសេធចំពោះការសម្រុះសម្រួល នោះគឺគ្មានដំណើរការសម្រុះសម្រួលទេ ហើយក៏គ្មានដំណោះស្រាយដែរ ។ ប្រសិនបើ ភាគីវិវាទបដិសេធការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នោះករណីវិវាទនេះត្រូវតែបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ។ ប្រសិនបើ នៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង មានការបដិសេធទៀត ករណីវិវាទនេះត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ប្រសិនបើ នៅគណៈកម្មការសុរិយោដីថ្នាក់ជាតិនៅតែមានការបដិសេធទៀត នោះគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើសេចក្តីសម្រេចចំពោះករណីវិវាទនេះ ។

មាត្រា ១១នៃអនុក្រឹត្យលេខ ៤៧ ចែងចំពោះគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌថា "ប្រសិនបើ មិនអាចឈានទៅដល់ដំណោះស្រាយទេនោះ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវដាក់ករណីវិវាទនេះអមជាមួយនីងរបាយការណ៍សម្រុះសម្រួលជាលាយលក្ខណ៍អក្សរជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង" ។

មាត្រា ១៦នៃអនុក្រឹត្យនេះដែរ ចែងចំពោះគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងថា "ប្រសិនបើមិនអាចឈានទៅដល់ដំណោះស្រាយទេនោះ គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងត្រូវដាក់ករណីវិវាទនេះអមជាមួយនីងរបាយការណ៍សម្រុះសម្រួលជាលាយលក្ខណ៍អក្សរជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ" ។ នៅក្នុងស្ថានភាពដែលមិនឈានទៅដល់ដំណោះស្រាយបាន ដោយសារតែភាគីវិវាទមួយ ឬច្រើនបដិសេធការចូលរួម សម្រុះសម្រួលរបាយការណ៍សម្រុះសម្រួលត្រូវសរសេរយ៉ាងសាមញ្ញ ។

៣៩. តើគណៈកម្មការសុរិយោដីផ្តល់សេចក្តីជូនដំណឹងដល់ភាគីវិវាទដែលមិនរស់នៅតំបន់នេះយ៉ាងដូចម្តេច?

<u>ចម្លើយ</u> :- វាជាការទទួលខុសត្រូវរបស់គណៈកម្មការសុរិយោដីក្នុងការស្វែងរក និងផ្តល់សេចក្តីជូនដំណឹងដល់គ្រប់ភាគីទាំងអស់ អំពីពាក្យប្តឹងដែលត្រូវបានដាក់ប្តឹង ឬអំពីការប្រជុំ។ល។ ប្រសិនបើ មានករណីវិវាទមួយនៅកម្រិតគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ហើយភាគីម្ខាងរស់នៅស្រុក ខណ្ឌមួយផ្សេងទៀត នោះគណៈកម្មការសុរិយោដីដែលដោះស្រាយករណីវិវាទនេះអាចបញ្ជូនពាក្យប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌដែលនៅក្នុងស្រុក ខណ្ឌរបស់ចុងបណ្តឹង ។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌទី ២ អាចផ្តល់ពាក្យប្តឹងនេះដល់ភាគីនោះ ។ ឱ្យតែគណៈកម្មការសុរិយោដីដឹងពីកន្លែងរស់នៅរបស់ភាគី នោះគេនឹងមានវិធីសម្រាប់ទាក់ទងនឹងភាគីនោះបានមិនខាន ។

៤០. ប្រការ ២៦ នៃប្រកាស ១១២ ចែងថា ការព្រមព្រៀងសម្រុះសម្រួលត្រូវបិទផ្សាយជាសាធារណៈនៅលើដីដែលមានវិវាទក្នុងរយៈពេល ១៤ ថ្ងៃ ដើម្បីឱ្យមានការបញ្ជេញមតិ។" តើមានអ្វីកើតឡើងនៅពេលមានការបញ្ជេញមតិ ?

<u>ចម្លើយ</u> :- ពីព្រោះការព្រមព្រៀងសម្រុះសម្រួល គឺជាប្រភេទនៃកិច្ចសន្យា វាអាចត្រូវបានកែប្រែប្រសិនបើភាគីទាំងអស់យល់ព្រម។ វាអាចកើតមានឡើងដែលថា ជនដែលបានអានសេចក្តីព្រមព្រៀងសម្រុះសម្រួលដែលបិទផ្សាយជាសាធារណៈនឹងជូនដំណឹងអំពីកំហុសនៅក្នុងសេចក្តីព្រមព្រៀងសម្រុះសម្រួលនេះ ឬអាចគិតឃើញអំពីចំណុចបន្ថែមទៀតដើម្បីបញ្ចូលនៅក្នុងសេចក្តីព្រមព្រៀងនេះ ។ ប្រសិនបើ សំណូមពរឱ្យមានការកែប្រែសេចក្តីព្រមព្រៀងនេះត្រូវបានលើកឡើងនៅក្នុងអំឡុងពេល ១៤ ថ្ងៃភាគីទាំងអស់ និងអ្នកសម្រុះសម្រួលអាចគិតពិចារណាទៅលើសំណូមពរនេះ ហើយប្រសិនបើពួកគេទាំងអស់គ្នាយល់ស្រប គេអាចធ្វើការកែប្រែសេចក្តីព្រមព្រៀងនេះបាន ។



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

@all rights reserved